**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គោលដៅនៃការស្ទង់មតិរបស់គំរោងបណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងការទប់ស្កាត់ ការប្រើប្រាស់ថ្នាំជក់ ២០០៥

## ឯកសារណែនាំសំរាប់ មន្ត្រីសំភាសន៍ និងមន្ត្រីត្រួតពិនិត្យ

**វិទ្យាស្ថានជាតិស្ថិតិ/អង្គការ ADRA TCLT ភ្នំពេញ**

## មាតិកា

I. ជំពូក ១ ទំព័រ

សេចក្តីផ្តើម..........................................................................................................៣-៩

II. ជំពូក ២

តួនាទីរបស់អ្នកសំភាសន៏ និងមន្ត្រីត្រួតពិនិត្យ..........................................................................១០-១៣

III. ជំពូក ៣

វិធានការទូទៅសំរាប់ធ្វើការសំភាសន៏...............................................................................១៤-១៨

IV. ជំពូក ៤

ទំរង់ការនៃការចុះបញ្ជី និងការសំភាសន៏.............................................................................១៩

V. ជំពូក ៥

ទស្សនះ និង និយមន័យសំខាន់ៗ.....................................................................................២០-២៥

VI. ជំពូក ៦

បញ្ជីសំរង់គ្រួសារនៅក្នុងភូមិ (TCLT ទំរង់ ១)....................................................................២៦-៣៨

VII. ជំពូក ៧

កំរងសំណួរគ្រួសារ ( ទជឡទ ទំរង់ ២)..............................................................................៣៩-៩១

# ជំពូក 1

## សេចក្តីផ្តើម

ជំពូកនេះពិពណ៌នាអំពីការស្ទង់មតិរបស់គំរោងបណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងការទប់ស្កាត់ការប្រើប្រាស់ថ្នាំជក់ ២០០៥ ( TCLT 2005 ) នឹងពន្យល់អំពីគោលបំណង និងគោលដៅរបស់វា ។ ជំពូកនេះក៏សិក្សាផងដែរនូវចំណុចសំខាន់ៗមួយចំនួនរបស់ការអង្កេតដូចជទំហំនឹងវិសាលភាពបញ្ជីសំណួរគំរោង និងទំហំនៃការជ្រើសរើសសំណាកគំរូ ។

### 1.1 ការពិពណ៌នាទូទៅនៃការអង្កេត

ការអង្កេតថ្នាក់ជាតិអំពីភាពជាអ្នកដឹកនាំក្នុងការទប់ស្កាត់ការប្រើប្រាស់ថ្នាំជក់ ២០០៥ ( TCLT 2005 ) គឺជាការអង្កេតប្រចាំឆ្នាំលើកទី 2 នៅប្រទេសកម្ពុជាដែលលើកទីមួយគឺជាការអង្កេតលើការជក់បារី ។ ការអង្កេតនេះគឺជាការអង្កេតទូទាំងប្រទេសដែលមានសំណាកគំរូអង្កេតភូមិ និងក្រុមគ្រួសារបានជ្រើសរើសក្នុងទូទាំងប្រទេសនៅកម្ពុជាដែលមាន10710ប្រធានបទដែលមានអាយុ18ឆ្នាំឡើងទៅ។ ការអង្កេតនេះបានអនុវត្តន៏ក្នុងផ្នែកនៃគំរោង"បណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងការទប់ស្កាត់ការប្រើប្រាស់ថ្នាំជក់ ២០០៥" ។ គំរោងនេះបានឧបត្ថម្ភដោយសកលវិទ្យាល័យឡូម៉ាលីនដា សហរដ្ឋអាមេរិកសហការណ៏ជាមួយADRA ប្រទេសកម្ពុជា។ កាលបរិឆ្ឆេទកំនត់ដោយកម្មវិធី (TCLT) បានធ្វើកិច្ចសន្យាស្តីពីការប្រើប្រាស់ពេលវេលាក្នុងផ្នែកប្រមូលទិន្នន័យដោយវិជ្ជាស្ថានជាតិស្ថិតិ និងទទួលបន្ទុកធ្វើការអង្កេតនិងសហប្រតិបត្តិការណ៏ជាមួយនិស្សិត និងបុគ្គលិករបស់កម្មវិធី TCLT ។

គោលបំណងសំខាន់នៃការអង្កេត TCLT ២០០៥ គឺប្រមូលពតិមានសំខាន់ៗពីភូមិ និងក្រុមគ្រួសារតំណាងអំពីទិន្នន័យនិងចំណុចផ្សេងៗនៃស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រជារាស្រ្តមានលក្ខណៈប្រែប្រួលនៃភាពរាលដាលនៃការប្រើប្រាស់ថ្នាំជក់របស់ប្រជាជកម្ពុជា។ អាស្រ័យហេតុនេះដំណើរការអង្កេត និងការប្រមូលទិន្នន័យនេះមានផលប្រយោជន៏នឹងជាគន្លឹះអ្នកស្រាវជ្រាវអំពីថ្នាំជក់ដើម្បីសិក្សានិងបទពិសោធន៏នៃការផ្លាស់ប្តូរវិធីសាស្រ្តស្រាវជ្រាវនិងជំហានទីមួយៗរបស់បច្ចេកទេស។ ទិន្នន័យដែលប្រមូលបានអាចផ្តល់លទ្ធផលប្រសើរនិងសុក្រិតដែលមានលក្ខណៈទូលំទូលាយរបស់អាំងឌីការទ័រនៃកំរិតនៃការរាលដាលរបស់ថ្នាំជក់តាមតំបន់ភូមិសាស្រ្តខុសៗគ្នា និងក្នុងកំរិតសេដ្ឋកិច្ច និងសង្គមផ្សេងៗគ្នា។ ទិន្នន័យទាំងនេះនឹងជួយដល់ការតាមដានវិភាគនូវបញ្ហានៃការជក់បារីការយល់ដឹងនិងផលប៉ះពាល់នៃការជក់បារីការអង្កេតនេះ នឹងជួយផ្តល់នូវមធ្យោបាយប្រកបដោយវិសាលភាពធំធេងនិងទិសដៅនៃការវិភាគពីការជក់បារីតាមដាននូវភាពរាលដាលនៃការជក់បារីនៅក្នុងប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៏ឬបង្កើននូវយុទ្ធសាស្រ្តគោលនយោបាយជាតិស្តីពីការប្រើប្រាស់ថ្នាំជក់។ បញ្ជីសំណួរនឹងត្រូវយកមកសំភាសន៏សំរាប់ការអង្កេតនេះទំរង់១ (តារាងសំណួរសំរង់គ្រួសារនៅក្នុងភូមិ) ទំរង់ 2 (តារាងសំណួរសំខាន់ៗ ) និងសេចក្តីណែនាំពីផ្សេងទៀត និងប្រើសំរាប់មន្រ្តីសំភាសន៏,ផ្នែកកែច្នៃទិន្នន័យ មន្រ្តីត្រួតពិនិត្យ និងអ្នកដាក់លេខកូដ។

## 1.2 គោលដៅនៃការស្ទង់មតិរបស់គំរោងបណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងការទប់ស្កាត់ការប្រើប្រាស់ ថ្នាំជក់ ២០០៥

**គោលដៅទូទៅ :**

គោលដៅសំខាន់ៗមួយចំនួនមានដូចតទៅ :

I. ទំព័រមុខ

II. ប្រមូលពតិមានអំពីស្ថានភាពប្រជាសាស្ត្រ

III. ប្រមូលទិន្នន័យអំពីការប្រើប្រាស់ថ្នាំជក់រួមបញ្ចូលការជក់បារី ការចុកថ្នាំ, ការជក់ខ្សៀ និងអាយុនៃការចាប់ផ្តើមជក់បារី មូលហេតុក្នុងការចាប់ផ្តើម ឬបន្តប្រើប្រាស់ថ្នាំជក់។

IV. ប្រមូលពតិមានអំពីការយល់ដឹងនិង ឥរិយយាបទនៃការប្រើប្រាស់ថ្នាំជក់រួមមានចំណេះដឹងនឹងឥរិយាបទអំពីឥទ្ធិពលដែលមានគ្រោះថ្នាក់របស់បារី ឥរិយយាបទនៃការប្រើប្រាស់ថ្នាំជក់នៅក្នុងសហគមន៍ ឥរិយយាបទអំពីគោនយោបាយប្រឆាំងនឹងការជក់បារី និង ឥរិយយាបទអំពីការញៀនបារី ។

V. ប្រមូលពតិមានអំពីការជក់បារីមិនផ្ទាល់ ។

VI. ប្រមូលទិន្នន័យអំពីការឈប់ជក់បារី។

VII របៀបរបបនៃការរស់នៅរួមមានមនុស្សមាត្រវិទ្យារបបអាហារ,ស្ថានភាពសុខភាពបច្ចុប្បន្នការស្វែងរកសេវាកម្មសុខាភិបាល សុខភាពស្ត្រី ។

VIII. ប្រពន្ធ័ផ្សព្វផ្សាយពិតមាន

IX. សំនួរបន្ថែម

## 1. 3 ការសំងាត់នៃពតិមាន

គ្រប់ពតិមានទាំងអស់ដែលប្រមូលបានពីគំរោងបណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងការទប់ស្កាត់ការប្រើប្រាស់ថ្នាំជក់២០០៥ ពីប្រធានភូមិ ឬអ្នកតំណាងភូមិ និងពីក្រុម គ្រួសារគំរូត្រូវបានរក្សាជាការសំងាត់បំផុតហើយប្រើប្រាស់សំរាប់តែគោលដៅស្ថិតិក្នុងការធ្វើផែនការសេដ្ឋកិច្ចនិងសង្គមកិច្ចប៉ុណ្ណោះ។ ពតិមានដែលបានផ្តល់ដោយបុគ្គលណាមួយនឹងមិនត្រូវយកមកប្រើប្រាស់ដើម្បីប្រឆាំង នឹងបុគ្គលនោះវិញឡើយ ដូចជា បញ្ហាពន្ធដារការស៊ើបអង្កេតឬក៏ក្នុងគោលបំណងស្របច្បាប់ដ៏ទៃទៀត ។

## 1.4 ទំហំ និងវិសាលភាព

ទំហំនៃការអង្កេតមានលទ្ធភាពគ្រប់គ្រាន់សមស្របទៅនឹងគោលដៅដូចបានជំរាបជូនខាងលើ ។ សំណាកគំរូចៃដន្យមានចំនួន10710គ្រួសារសំរាប់ប្រមូលទិន្នន័យតាមរយៈប្រជាជនដែលមានអាយុ 18 ឆ្នាំឡើងជ្រើសរើសចំនួនគ្រួសារ 6254 គ្រួសារ 434 មណ្ឌលអង្កេតនិងគ្របដណ្តប់ដើម្បីប្រមូលទិន្នន័យតាមរយៈផ្នែកសំខាន់ៗពីរនៃសំណួរគឺទំរង់1 និងទំរង់ 2 ។ ក្រៅអំពី 434 ភូមិគំរូមាន 64 ជាតំបន់ទីប្រជុំជន ។ 370 ភូមិ និងត្រូវគ្របដណ្តប់ នៅទីជនបទ ។ ចំនួន 11 គ្រួសារ និង

ត្រូវជ្រើសរើសចេញពីភូមិគំរូនីមួយៗ នៅទីប្រជុំជន និង 15 គ្រួសារចេញ ពីភូមិគំរូនៅជនបទ ។ នៅតារាងខាងក្រោមបានបង្ហាញនូវចំនួនភូមិដែលត្រូវដកចេញតាមខេត្តនីមួយៗ ។ ចំនួន17តំបន់ត្រូវបានពិចារណាបែងចែកជាផ្នែកៗក្នុងការអង្កេតត្រូវបានលើកគំរោងគ្របដណ្តប់គ្រួសារឯកជនទាំងអស់ រួមទាំងគ្រួសារដែលមានសមាជិកតែម្នាក់ផងដែរ ។ មនុស្សរស់នៅក្នុងគ្រួសារសាប័នដូចជាបន្ទាយទាហាន ពន្ធនាគារ មន្ទីរពេទ្យ និងផ្ទះសំណាក់ និងត្រូវបានដកចេញ ។មួយផ្នែកធំនៃឯកសារណែនាំសំរាប់អ្នកសំភាសន៍ នឹងត្រូវបានទុកសំរាប់ណែនាំដល់ការបំពេញទំរង់ទាំងនោះ ។ TCLT ទំរង់ 1 នឹងត្រូវបំពេញសំរាប់ចុះបញ្ជីគ្រួសារក្នុងភូមិតំណាងនីមួយៗ(ឬផ្នែកនៃភូមិតំណាង) ដែលបានជ្រើសរើសដោយចៃដន្យសំរាប់គោលបំណងនៃការអង្កេត ។ ទំរង់នេះក៏នឹងប្រើប្រាស់សំរាប់ជ្រើសរើស 11 គ្រួសារដោយចៃដន្យពីភូមិនីមួយៗ (ឬផ្នែកនៃភូមិដែរ ) ។មាតិកានៃបញ្ជីសំណួរអំពីភូមិ ( ទំរង់ និងទំរង់ 2 ) ត្រូវបានបង្ហាញដូចខាងក្រោមសំរាប់ប្រមូលពតិមានពីភូមិតំណាងនីមួយៗតាមរយៈបញ្ជីសំណួរនេះ :

ទំរង់ 1 : ការចុះបញ្ជីគ្រួសារ

ទំរង់ 2 : សំណួរចំបង

**I. ទំព័រមុខ ( TCLT )**

**II.ប្រជាសាស្ត្រនៃគ្រួសារ :** អាយុ ភេទ ស្ថានភាពអាពាហ៍ពិពាហ៍ (បើមាន) ជនជាតិ អក្ខរភាព និងការចូលរួមក្នុងការសិក្សាអប់រំ ,មុខរបរ និងចំណូល (សំនួរពីលេខ ១ ទៅ ១៩) ។

III.ការប្រើប្រាស់ថ្នាំជក់ដែលមានអាយុពី 10 ឆ្នាំឡើងទៅ : សកម្មភាពបច្ចុប្បន្នក្នុងរយៈ

ការជក់បារី ( (សំនួរពីលេខ ២០ ទៅ ៣៦) ។

ការចុកឬទល់ថ្នាំ ( (សំនួរពីលេខ ៣៧ ទៅ ៤៧) ។

ការជក់ខ្សៀ ( (សំនួរពីលេខ ៤៨ ទៅ ៦០) ។

អាយុនៃការចាប់ផ្តើមជក់លើកដំបូង ( សំនួរពីលេខ ៦១ ទៅ ៦៤)

ហេតុផលនៃការចាប់ផ្តើមជក់(សំនួរពីលេខ ៦៥ ទៅ៦៦) សួរពីហេតុផលចំពោះការផ្តើមជក់ និង ត្រូវបន្តជក់និងក្លាយជាអ្នកជក់បារី ។

**IV. ចំណេះដឹង និងឥរិយាបទនៃការប្រើប្រាស់ថ្នាំជក់**

យល់ដឹងថាជក់បារីនាំអោយប៉ះពាល់សុខភាព(សំនួរពីលេខ ៦៧ ទៅ ៧១)

- ឥរិយាបទនៃការជក់បារី (សំណួរ ៧២ ) ។
- ឥរិយាបទ នៃការជះឥទ្ធិពលទៅដល់សង្គមពីការជាក់បារី (សំនួរពីលេខ ៧៣ ទៅ ៧៤)
- ឥរិយាបទនៃគោលនយោបាយប្រឆាំងនិងការជក់បារី ( សំនួរពីលេខ ៧៥ ទៅ ៧៦)

- តំរិយាបទពីការជក់និងញៀនបារី ( រួមមាន 6 សំណួរ )

**V.** ការជក់បារីមិនផ្ទាល់

**VI.** ការឈប់ជក់

**VII.** របៀបរបបនៃការរស់នៅ :

មនុស្សមាត្រវិទ្យា ( សំនួរលេខ ៨៩-៩០)

របបអាហារ( ៩១)

ស្ថានភាពសុខភាពបច្ចុប្បន្ន ( សំនួរលេខ ៩២-៩៥)

- ការស្វែងរកសេវា សុខាភិបាល ( សំនួរលេខ ៩៦)

- សុខភាពស្ត្រី ( សំនួរលេខ ៩៧-៩៨)

កុមាររស់នៅក្នុងគ្រួសារ

VIII. ប្រពន្ធ័ផ្សព្វផ្សាយពិតមាន ( សំនួរលេខ ៩៩-១០១)

IX. **សំនួរបន្ថែម ( សំនួរលេខ ១០២)**

1.5 **ជ្រើសរើសគំរូនឹង ទំហំគំរូ**

ទជឡទ ២០០៥ គឺជាការអង្កេតក៏រិតជាតិដែលមានគំរូចំនួនមនុស្ស 10710 នាក់ ដែលមានអាយុពី 18 ឆ្នាំឡើងទៅ ។ លទ្ធផលនៃការប៉ាន់ស្មានរបស់អង្កេតនៃបណ្ដាខេត្តមួយចំនួនដូចជា ( បន្ទាយមានជ័យ, កំពង់ចាម, កំពង់ឆ្នាំង, កំពង់ស្ពឺ, កំពង់ធំ, កណ្ដាល កោះកុង ភ្នំពេញ, ព្រៃវែង, ពោធិសាត់, ស្វាយរៀង និងតាកែវ)និង 5 ក្រុមរបស់ខេត្តមានដូចតទៅ :

1. បាត់ដំបង និងក្រុមប៉ៃលិន
2. កំពត, ក្រុងព្រះសីហនុ និងក្រុងកែប
3. ក្រចេះ , ព្រះវិហារ និងស្ទឹងត្រែង
4. មណ្ឌលគីរី និងរតនះគីរី
5. ឧត្ដរមានជ័យ និងសៀមរាប

គំរូមេត្រូវបានអភិវឌ្ឍន៍ឆ្នាំ1998 ដោយវិជ្ជាស្ថានជាតិស្ថិតិក្នុងការផ្ដល់នូវការធ្វើគំរោងជ្រើសរើសគំរូចំពោះTCLT គំរូមេនេះ បានមកពីការធ្វើជំរឿនប្រជាជនទូទៅឆ្នាំ 1998 និងមាន 600 ភូមិជ្រើសចេញ ប្រូបាប៊ីលីតេ សមាមាត្រទៅនឹងចំនួនគ្រួសារ និងភូមិត្រូវបានចុះបញ្ជីជាមួយនិងចំនួនសរុបរបស់ប្រជាជនទាំងអស់និងចំនួនទីកន្លែងអង្កេត ($EA_s$) គ្រួសារនិងមណ្ឌល ។កន្លែងធ្វើអង្កេតត្រូវបានបង្កើតឡើងនៅពេលដែលក្រុមគូសផែនទីក្នុងការរៀបចំធ្វើជំរឿនឆ្នាំ1998 ។

កន្លែងធ្វើអង្កេតនៅក្នុងភូមិមួយត្រូវមានប្រជាជនរស់នៅប្រហែល110គ្រួសារ ។ ចំនួនភូមិត្រូវក្នុងគំរូមេ និងផែនទីដែលបង្ហាញពីព្រំប្រទល់និងអ្វីៗដែលភូមិនោះមាន ។ គំរូនៃការអង្កេត TCLT គឺជាស្រទាប់នៃការជ្រើសរើសគំរូក្នុងបីដំណាក់កាល ។ ដូចជាគំរូមេស្រទាប់ត្រូវបានបំពេញដោយស្រទាប់ៗដោយឡែករាល់របាយការណ៍ដែលមាននៅទីប្រជុំជន និងជនបទ ។ ចំនួនគំរូជ្រើសដោយចៃដន្យពីគ្រប់ស្រទាប់ ។ គំរូមេមានចំនួនភូមិតូចៗនៅតាមបណ្តាខេត្ត។ ចំពោះហេតុផលនេះ ចំនួនភូមិបន្ថែមយើងនឹងជ្រើសពីគំរោងរបស់ជំរឿន ក្នុងការសំណើនៃការជ្រើសរើសនៅតាមបណ្តាខេត្តទាំងនេះ ។ នៅក្នុងជំហានទី1 434 ភូមិ ត្រូវជ្រើសជាមួយប្រូបាប៊ីលីតេដែលមានសមាមាត្រទៅនឹងចំនួនភូមិ ។ 434 ភូមិនេះ 49 ត្រូវបានជ្រើសចេញពីគំរោងរបស់ជំរឿន 1998 ។ ជំហានទី 2 មួយ EA ត្រូវបានមកពីការជ្រើសរើសពីគំរូមេ ដូចនេះមួយEAបានយកពីចំណោមភូមិទាំង 49 ដែលជ្រើសពីគំរោងរបស់ជំរឿន 1998 ដែលបានកែលំអ ។ការចុះបញ្ជីគ្រួសារមួយត្រូវមាននៅក្នុង $EA_s$ដែលបានជ្រើសទាំងអស់នៃគ្រួសារដើម្បីធ្វើគំរោងនៃការជ្រើសរើសគ្រួសារនៅក្នុងជំហានទី3 ។

ក្នុងបណ្តាក្រុមទាំង 5 នៃបណ្តាខេត្តដែលត្រូវជ្រើសរើសមាននៅក្នុងតារាងខាងក្រោម :

| ល.រ | ស្រទាប់ | តំបន់ | | | | សរុប | |
|---|---|---|---|---|---|---|---|
| | | ប្រជុំជន | | ជនបទ | | | |
| | | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនភូមិ | ចំនួនគ្រួសារ |
| 1 | ខេត្តបន្ទាយមានជ័យ | 4 | 44 | 22 | 330 | 26 | 374 |
| 2 | ខេត្តកំពង់ចាម | 1 | 11 | 25 | 375 | 26 | 286 |
| 3 | ខេត្តកំពង់ឆ្នាំង | 2 | 22 | 24 | 360 | 26 | 382 |
| 4 | ខេត្តកំពង់ស្ពឺ | 2 | 22 | 24 | 360 | 26 | 382 |
| 5 | ខេត្តកំពង់ធំ | 3 | 33 | 23 | 345 | 26 | 378 |
| 6 | ខេត្តកណ្តាល | 1 | 11 | 25 | 375 | 26 | 386 |
| 7 | ខេត្តកោះកុង | 5 | 55 | 20 | 300 | 25 | 355 |
| 8 | ក្រុងភ្នំពេញ | 13 | 143 | 11 | 165 | 24 | 308 |
| 9 | ខេត្តព្រៃវែង | 1 | 11 | 24 | 360 | 25 | 371 |
| 10 | ខេត្តពោធិសាត់ | 3 | 33 | 22 | 330 | 25 | 363 |
| 11 | ខេត្តស្វាយរៀង | 1 | 11 | 25 | 375 | 26 | 386 |
| 12 | ខេត្តតាកែវ | 1 | 11 | 25 | 375 | 26 | 386 |
| | | | | | | | |
| 13 | ខេត្តបាត់ដំបង | 4 | 44 | 21 | 315 | 25 | 359 |
| | ក្រុងប៉ៃលិន | 1 | 11 | 0 | 0 | 1 | 11 |
| | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 14 | ខេត្តកំពត | 1 | 11 | 18 | 270 | 19 | 281 |
| | ក្រុងព្រះសីហនុ | 5 | 55 | 0 | 0 | 5 | 55 |
| | ក្រុងកែប | 1 | 11 | 0 | 0 | 1 | 11 |
| | | | | | | | |
| 15 | ខេត្តក្រចេះ | 4 | 44 | 11 | 165 | 15 | 209 |
| | ខេត្តព្រះវិហារ | 1 | 11 | 5 | 75 | 6 | 86 |
| | ខេត្តស្ទឹងត្រែង | 1 | 11 | 3 | 45 | 4 | 56 |
| | | | | | | | |
| 16 | ខេត្តមណ្ឌលគិរី | 1 | 11 | 5 | 75 | 6 | 86 |
| | ខេត្តរតនៈគិរី | 3 | 33 | 16 | 240 | 19 | 273 |
| | | | | | | | |
| 17 | ឧត្តរមានជ័យ | 1 | 11 | 2 | 30 | 3 | 41 |
| | សៀមរាប | 4 | 44 | 19 | 285 | 23 | 329 |
| សរុប | | 64 | 704 | 370 | 5550 | 434 | 6254 |

ចំណាំថា : យើងជ្រើស 11 គ្រួសារពីគំរូភូមិនៅទីប្រជុំជន និង 15 គ្រួសារនៅទីជនបទ នៅគ្រប់ស្រទាប់ទាំងអស់111

## 1.6 ការជ្រើសរើសតំបន់អង្កេត (ភូមិ)

ភូមិគំរូត្រូវបានជ្រើសរើសដោយឡែកពីគ្នា។ ចំពោះរាល់ស្រទាប់ការជ្រើសរើសជាប្រព័ន្ធរង្វង់គំរូ (CSS) ជាមួយប្រូបាប៊ីលីតេនៃការដាក់បញ្ចូលជាសមាមាត្រទៅនិងទំហំ(PPS) ។ វិធីសាស្ត្រនៃការជ្រើសរើសត្រូវបានអនុវត្តន៍បន្ទាប់ពីការរៀបចំភូមិរាល់ស្រទាប់ដោយយោងទៅលើ ខេត្ត.ក្រុង.ស្រុក (ខ័ណ្ឌ) និង ឃុំ (សង្កាត់) ដើម្បីទាញយកផលប្រយោជន៍នៃការរៀបចំទាំងស្រុង ។ ការជ្រើសរើសត្រូវធ្វើតាមប្រព័ន្ធកុំព្យូទ័រ ។

## 1.7- ការជ្រើសរើសតំបន់អង្កេត

តំបន់អង្កេតនីមួយៗត្រូវបានជ្រើសរើសចេញពីភូមិតំណាងនីមួយៗតាមវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ ។

## 1.8- ការជ្រើសរើសគ្រួសារ

សំរាប់ភូមិតំណាងនីមួយៗ ដំណើរការចុះបញ្ជីនឹងត្រូវអនុវត្តហើយបំពេញក្នុងទំរង់ 1 ។ ហើយភូមិនីមួយៗ ត្រូវបានគេកំណត់តំបន់អង្កេត (EA) នៅលើផែនទីហើយជាស្រេច។ ចំនួនតំបន់អង្កេតច្រើន ឬតិចរបស់ភូមិនីមួយៗ គឺវាអាស្រ័យទៅលើទំហំ( ចំនួនគ្រួសារ) របស់ភូមិនោ ។តំបន់អង្កេតមួយក្នុងចំណោមតំបន់អង្កេតទាំងអស់ត្រូវបានជ្រើសរើស

ដោយចៃដន្យ ហើយចុះបញ្ជីគ្រប់គ្រួសារទាំងអស់ដែលមាននៅតែក្នុងតំបន់ដែលបានជ្រើសរើសប៉ុណ្ណោះ។ នីតិវិធី និង ការណែនាំសំរាប់ការរៀបចំចុះបញ្ជីគ្រប់គ្រួសារទាំងអស់ក្នុងភូមិឬតំបន់អង្កេត និងណែនាំសំរាប់ជ្រើសរើសតំបន់ណាមួយ ដោយចៃដន្យបើចាំបាច់ ត្រូវបានពិពណ៌នាលំអិតក្នុងជំពូក 6 : បញ្ជី សំរង់គ្រួសារនៅក្នុងភូមិ (TCLT ទំរង់1) ។

គ្រួសារតំណាងនឹងត្រូវជ្រើសរើសពីបញ្ជីសំរង់គ្រួសារសំរាប់ភូមិ ឬតំបន់ដែលបានជ្រើសរើស ។ ក្នុងគ្រប់តំបន់ នីមួយៗ ត្រូវជ្រើសរើស 10 គ្រួសារពីភូមិ ឬ តំបន់នៅទីប្រជុំជន និង 20គ្រួសារពីភូមិ ឬតំបន់នៅជនបទ នីមួយៗតាម របៀបជ្រើសរើសសំណាក់គំរូតាមប្រព័ន្ធវង្វង់ជាមួយ នឹងលេខចាប់ផ្តើមដោយចៃដន្យ ។ ចន្លោះឃ្លាតសំរាប់ជ្រើស សំណាកគំរូ ត្រូវស្មើនឹងចំនួនគ្រួសារសរុបដែលបានចុះបញ្ជីចែកនឹង 10 ហើយលុបក្បៀសរួចខិតទៅលេខគត់ណាដែលជិត ជាងគេ។ការណែនាំលំអិតបន្ថែមអំពីរបៀបជ្រើសរើសគ្រួសារតំណាង នឹងផ្តល់អោយក្នុង ជំពូក 6 អំពីការចុះបញ្ជីគ្រួសារ ក្នុងភូមិដែលទាក់ទងទៅនឹងទំរង់ 1 ។

# ជំពូក ២
## តួនាទីរបស់អ្នកសំភាសន៍

គុណភាពទិន្នន័យពឹងផ្អែកជាសំខាន់ទៅលើបុគ្គលដែលជាអ្នកប្រមូលទិន្នន័យគឺអ្នកសំភាសន៍ ។ ដូច្នេះការយល់ព្រមអោយអ្នកមាននាទីជាអ្នកសំភាសន៍ គឺត្រូវការអោយអ្នកអនុវត្តអោយបានត្រឹមត្រូវ និងប្រាកដក្នុងចិត្តថាពតិមានដែលអ្នកបានប្រមូល គឺពិតជាត្រឹមត្រូវអនុវត្តបានពេញលេញតាមការបណ្តុះបណ្តាល និងការពិភាក្សានៅក្នុងវគ្គបំពាក់បំប៉នអ្នកសំភាសន៍។ ក្នុងនាមជាអ្នកសំភាសន៍ អ្នកត្រូវដើរតួនាទីជាចំបងក្នុងការអនុវត្តនៃប្រតិបត្តិការអង្កេត។ ការងាររបស់អ្នកត្រូវឱ្យអ្នកមានភាពឆ្លាតវៃក្នុងការជួបជាមួយប្រជាជនដោយប្រុងប្រយ័ត្ន និងទទួលខុសត្រូវរក្សាការសម្ងាត់នូវគ្រប់ពតិមានទាំងអស់របស់បុគ្គលគ្រួសារនិងភូមិព្រមទាំងបណ្តាគ្រឹះស្ថានដែលអ្នកទទួលបាននៅពេលធ្វើសំភាសន៍។ ដូច្នេះការងាររបស់អ្នក គឺមានសារៈសំខាន់ណាស់ ។

ជំពូកនេះនឹងរៀបរាប់លំអិតអំពីតួនាទីភារៈកិច្ច និងភាពទទួលខុសត្រូវច្បាស់លាស់របស់អ្នកសំភាសន៍នៅក្នុងការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ( TCLT 2004-2005) ។

### 2.1- ការចាត់តាំងមន្ត្រីសំភាសន៍

អ្នកសំភាសន៍ម្នាក់អ្នកត្រូវតែបន្តរៀនសូត្រ និងអនុវត្តឱ្យបានពេញលេញនូវការងារសំភាសន៍តាម ស្ថានភាពការងារជាក់ស្តែងដែលបានចាត់តាំង ។ អ្នកត្រូវប្រើប្រាស់ប័ណ្ណសំគាល់ខ្លួនមួយដែលបានអនុញ្ញាតដោយរដ្ឋអំណាចក្នុងដំណាក់ការនៃប្រតិបត្តិការអង្កេតដោយភ្ជាប់ប័ណ្ណសំគាល់នេះតាមខ្លួនជានិច្ចពេលចុះបំពេញការងារ ។ ប័ណ្ណសំគាល់ខ្លួននេះត្រូវបង្ហាញទៅអ្នកឆ្លើយដើម្បីបញ្ជាក់ពីអត្តសញ្ញាណ គោលបំណង និងជាមធ្យោបាយបើកផ្លូវសំរាប់ធានានូវការសហការល្អរវាងភាគីទាំងពីរ ។

### 2.2- ភារៈកិច្ច និងការទទួលខុសត្រូវរបស់អ្នកសំភាសន៍

អ្នកសំភាសន៍ត្រូវទទួលខុសត្រូវក្នុងការបំពេញពតិមានក្នុងតារាងសំណួរទម្រង់ 1 និងតារាងសំណួរ ទំរង់ 3 ដោយសួរទៅអ្នកឆ្លើយ ចំណែកតារាងសំណួរទំរង់ 4 និង 5 ត្រូវបំពេញដោយគ្រួសារផ្ទាល់ និងមានការណែនាំពីអ្នកសំភាសន៍ ។ ម្យ៉ាងទៀតបើសិនជាអ្នកត្រួតពិនិត្យអវត្តមាន អ្នកសំភាសន៍អាចជួយបំពេញពតិមានក្នុងបញ្ជីសំណួរសំរាប់ភូមិទៀត( តារាងសំណួរទំរង២) ។

ជាអ្នកសំភាសន៍ម្នាក់អ្នកត្រូវបានសង្ឃឹមថាអ្នកអាចធ្វើការងាររបស់អ្នកបានយ៉ាងល្អបំផុត ។ អ្នកត្រូវតែប្រមូលពតិមានអោយបានត្រឹមត្រូវយោងទៅតាមសេចក្តីណែនាំ ។ អ្នកត្រូវប្រមូលទិន្នន័យពតិមានសំខាន់ៗ ដូចខាងក្រោមនេះ :

1-សួរសំណួរឱ្យបានត្រឹមត្រូវតាមការពិភាក្សានៅក្នុងសេចក្តីណែនាំនេះ

2-កត់ចូលតាមចំលើយច្បាស់លាស់ដែលអ្នកឆ្លើយបានផ្តល់ឱ្យអ្នក និង

3-ត្រួតពិនិត្យមើលលើចម្លើយនីមួយៗ អោយបានសមស្របហើយស៊ីគ្នា និងចម្លើយដទៃទៀត ។

អ្នកត្រូវតែប្រុងប្រយ័ត្នដោយយកចិត្តទុកដាក់បំផុតទៅលើការងារនីមួយៗនេះ ។បើអ្នកអាចធ្វើបាន ដូច្នេះវានឹងនាំអោយការងារអង្កេតទទួលបានជោគជ័យ ។ ភារៈកិច្ចជាមូលដ្ឋានរបស់អ្នកជាអ្នកសំភាសន៏មានដូចតទៅ :

1-ប្រសិនបើភូមិតំណាងមានទំហំធំត្រូវបែងចែកវាជាប្លុកឬជាផ្នែកហើយជ្រើសរើសយកមួយ ឬផ្នែកតាមវិធីចៃដន្យ បន្ទាប់ពីបានរៀបចំផែនទីព្រាងរបស់ភូមិដែលបានបំពេញគ្រប់ផ្នែកទាំងអស់ ។

2-រៀបចំផែនទីលំអិតរបស់ភូមិ ឬប្លុក ឬផ្នែកដោយបង្ហាញអំពីអគា និងគ្រួសាររួចចុះបញ្ជីគ្រប់លំនៅដ្ឋាន និងគ្រួសារទាំងអស់ដែលមាននៅក្នុងភូមិតំណាង ឬផ្នែកដោយប្រើតារាងសំនួរ TCLT ទំរង់ រួចហើយប្រគល់ទំរង់ដែលបានចុះបញ្ជីរួច និងផែនទីទាំងអស់ទៅឱ្យអ្នកត្រួតពិនិត្យរបស់អ្នកបន្ទាប់ពីបានបំពេញការងារក្នុងភូមិរួចមក ។

3-ធ្វើការសំភាសន៏ឱ្យបានត្រឹមត្រូវនូវគ្រប់គ្រួសារទាំងអស់នៅក្នុងភូមិ ឬផ្នែកដោយប្រើប្រាសតារាងសំណួរគ្រួសារ TCLT ទំរង់ ២ ។

4-ប្រគល់តារាងសំនួរគ្រប់ទំរង់ទាំងអស់ពិសេសតារាងសំនួរទំរង់ ១ និង ២ ទៅអោយអ្នកត្រួតពិនិត្យ និងចូលរួមប្រជុំតាមការកំណត់របស់ត្រួតពិនិត្យ ។

ដើម្បីអនុវត្តអោយបានពេញលេញតាមភារៈកិច្ចជាមូលដ្ឋានទាំងនោះ អ្នកសំភាសន៏ត្រូវអនុវត្តដូចតទៅ :

1-ចូលរួមក្នុងវគ្គបំពាក់បំប៉នសំរាប់អ្នកសំភាសន៏ ដើម្បីយល់បាននូវខ្លឹមសារអត្ថន័យនិងការណែនាំអំពីការដឹកនាំការអង្កេត TCLT 2005 ។

2-ប្រើប្រាស់ឯកសារណែនាំសំរាប់អ្នកសំភាសន៏ សំរាប់នាំផ្លូវនៅពេលដែលមានការសង្ស័យអំពីខ្លឹមសារ ឬការណែនាំផ្សេងៗ ។

3-បំពេញគ្រប់ទំរង់ TCLT 2005 ទាំងអស់ឱ្យបានពេញលេញនិងច្បាស់លាស់ ។

4-ត្រួតពិនិត្យការងាររបស់អ្នក ដើម្បីបំពេញឱ្យបានគ្រប់គ្រាន់ សមស្រប ស៊ីគ្នា និងសរសេរច្បាស់ៗ ដែលអាចអានបាន ។ល។ បើសិនជាអ្នកមើលឃើញថាវាមានភ្លេចចោលកន្លែងខ្លះ ឬភាពមិនស៊ីគ្នាដែលមិនអាចកែតម្រូវបានតាមពត៌មានផ្សេងៗទៀតក្នុងបញ្ជីសំណួរ សូមចុះទៅសាកសួរដល់គ្រួសារឡើងវិញដើម្បីយកពត៌មានតាមតម្រូវការ ។

5-ត្រូវរក្សាការសម្ងាត់បំផុតចំពោះពត៌មានទាំងអស់ដែលប្រមូលបានដោយមិនត្រូវបង្ហាញទៅអោយអ្នកណាម្នាក់ក្រៅពីអ្នកត្រួតពិនិត្យ និងមន្ត្រីផ្តល់សិទ្ធិរបស់វិជ្ជាស្ថានជាតិស្ថិតិ ។

6-រៀបចំរាល់ឯកសារដែលទាក់ទង របាយការណ៏និងតារាងសំណួរគ្រប់ទំរង់ទាំងអស់ដែលបានបំពេញរួចរៀងរាល់ចុងសប្តាហ៏ហើយប្រគល់ទៅអោយអ្នកត្រួតពិនិត្យដែលបានចាត់តាំងត្រឹមត្រូវ ។

**2-4- ការផ្គត់ផ្គង់សំភារៈ**

បន្ទាប់ពីការបំពាក់បំប៉នរួចមក ជាបឋមនៃការចុះសំភាសន៍ អ្នកត្រួតពិនិត្យនឹងផ្តល់ឱ្យអ្នកនូវទំរង់បញ្ជីសំណួរសំរាប់ការអង្កេតលិខិតរដ្ឋបាលនិងសំភារៈផ្គត់ផ្គង់ដែលអ្នកត្រូវការសំរាប់ការងាររបស់អ្នក ។ ក្រោយពីទទួលបានសំភារៈទាំងនោះអ្នកត្រូវពិនិត្យមើលថាតើសំភារៈទាំងនោះត្រឹមត្រូវឬទេ និងត្រួតពិនិត្យផ្នែកខ្លះនៃទំរង់នីមួយៗដែលអ្នកត្រួតពិនិត្យត្រូវបំពេញមុនពេលប្រគល់ឱ្យអ្នកសំភាសន៍ ថាតើអ្នកត្រួតពិនិត្យមានបានបំពេញហើយឬនៅ ។ បញ្ជីត្រួតពិនិត្យខាងក្រោមរៀបរាប់អំពីទំរង់បញ្ជីសំណួររបស់ការអង្កេត និងសំភារៈផ្គត់ផ្គង់ ។ អ្នកត្រូវដឹងអំពីរបៀបប្រើប្រាស់របស់វា និងរបៀបបំពេញពតិមានដូចមាននៅក្នុងជំពូកបន្តទៅទៀត ។

1 បញ្ជីឈ្មោះភូមិតំណាង ( រួមមានឈ្មោះឃុំ ស្រុក ខេត្ត )ដែលបានបែងចែកទៅឱ្យអ្នក សំភាសន៍និងអ្នកត្រួតពិនិត្យ ។

2 TCLT តារាងទំរង់ ១-តារាងសំណួរបញ្ជីរគ្រួសារនៅក្នុងភូមិ

3 TCLT តារាងទំរង់ ២-តារាងសំណួរភូមិ

4 ឯកសារណែនាំសំរាប់អ្នកសំភាសន៍

5 ប័ណ្ណសំគាល់ខ្លួន

6 សំភារៈប្រដាប់ប្រដាសំរាប់សំភាសន៍ រួមមាន : ប៊ិច ខ្មៅដៃ ជ័រលប់ ប្រដាប់ចិតខ្មៅដៃ ក្រដាស់ ក្រដាស់ខ្នាតវែងធំ ប្រដាប់គិតលេខ កាបូបស្ពាយ អង្រឹង អាវភ្លៀង មួក មុង ចានវាស់បាយ ទឹកពិសោធន៍ ជាតិអំបិលអ៊ីយ៉ូត ជញ្ជីងថ្លឹង ម៉ែត្រវាស់កំពស់ ។ ល ។ អ្នកត្រូវតែប្រគល់ត្រឡប់មកវិញទាំងអស់នូវឯកសារណែនាំសំរាប់អ្នកសំភាសន៍ ប័ណ្ណសំគាល់ខ្លួនតារាងសំណួរ ទាំងអស់ដែលបានបំពេញរួចជញ្ជីងថ្លឹងនិងម៉ែត្រវាស់កំពស់តាមការចាត់តាំងការងាររបស់អ្នក ។

**2-3- ការទំនាក់ទំនងជាមួយអ្នកត្រួតពិនិត្យ**

ភាពសមរម្យមួយនៃតួនាទីរបស់អ្នកសំភាសន៍ គឺត្រូវតែយល់អំពីការទំនាក់ទំនងជាមួយអ្នកត្រួតពិនិត្យ ។ ជាទូទៅអ្នកត្រួតពិនិត្យម្នាក់ៗ ត្រូវបានចាត់តាំងអោយត្រួតពិនិត្យលើអ្នកសំភាសន៍ច្រើនក្នុងរយៈពេលចុះអនុវត្តតាមមូលដ្ឋាន ។ ភារៈកិច្ចជាចំបងនិងការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យម្នាក់ក្នុងទំនាក់ទំនងការងារជាមួយ
អ្នកសំភាសន៍មានដូចតទៅ :

អ្នកត្រួតពិនិត្យរបស់អ្នកទទួលខុសយ៉ាងពេញលេញដល់គ្រប់អ្នកសំភាសន៍ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួនដែលបានធ្វើការចុះបញ្ជី និងធ្វើការសំភាសន៍តាមកាលកំណត់ ។ អ្នកត្រួតពិនិត្យមានផែនការ និងចាត់តាំងការងារនៅក្នុងតំបន់ត្រួតពិនិត្យរបស់ខ្លួន ហើយពិនិត្យមើលថាអ្វីៗត្រូវបាន ដឹកនាំដោយមានប្រសិទ្ធិ ភាព និងពេញលេញ ។

អ្នកត្រួតពិនិត្យរបស់អ្នកត្រូវពិនិត្យមើលការងារអ្នកសំភាសន៍ដែលបានធ្វើដើម្បីឱ្យដឹងច្បាស់ថាអ្នកបានធ្វើការងាររបស់អ្នកបានរួចរាល់ត្រឹមត្រូវនិងបានអនុវត្តតាមដំណើរការល្អដែលវិទ្យាស្ថានជាតិស្ថិតិ(NIS)បានដាក់ចុះ ។ អ្នកត្រួត

ពិនិត្យនឹងពិនិត្យមើលគ្រប់បញ្ជីសំណួរទាំងអស់ដែលអ្នកបានបំពេញរៀងរាល់ចុងសប្តាហ៍ ។ អ្នកត្រូវតែបង្ហាញនិងប្រគល់ការងាររបស់អ្នកទៅឱ្យអ្នកត្រួតពិនិត្យហើយ រាយការណ៍ទៅឱ្យគាត់អំពីដំណើរការនៃការងាររបស់អ្នកហើយចៀសវាងធ្វើនូវកំហុសដដែលម្តងទៀត ។

1. ដោយគាត់មានមុខងារជាអ្នកត្រួតពិនិត្យគាត់នឹងចុះពិនិត្យមើលទីតាំងសំភាសន៍ដែលបានប្រគល់ឱ្យអ្នកដើម្បីពិនិត្យមើលថាតើអ្នកបានធ្វើការចុះបញ្ជីក្នុងទីតាំងរបស់អ្នកបានត្រឹមត្រូវ និងពេញលេញដែរឬទេ។ គាត់នឹងធ្វើការសង្កេតពេលអ្នកកំពុងធ្វើការសំភាសន៍ជាមួយអ្នកឆ្លើយមួយចំនួន ។ គាត់ នឹងធ្វើការសាកសួរឡើងវិញចំពោះគ្រួសារខ្លះដែលអ្នកបានធ្វើការសំភាសន៍រួចផងដែរ ដើម្បីពិនិត្យមើលថាពត៌មានដែលអ្នកបានកត់ចូលនោះវាត្រឹមត្រូវដែរឬទេ ។

2. អ្នកត្រួតពិនិត្យនឹងផ្តល់អោយអ្នកនូវគ្រប់សំភារៈចាំបាច់ទាំងអស់បញ្ជីសំណួរ ។ល ។ ពេលអ្នកបំពេញការសំភាសន៍ចប់ភ្លាម អ្នកត្រូវតែប្រគល់ត្រឡប់មកវិញគ្រប់សំភារៈដែលបានប្រើប្រាស់ទាំងអស់ទៅ ឱ្យគាត់វិញ ។ បើមិនដូច្នេះទេ អ្នកមិនត្រូវបានទទួលនូវប្រាក់ឧបត្ថម្ភបញ្ចប់ការងាររបស់អ្នកឡើយ ។

3. អ្នកត្រួតពិនិត្យត្រូវភ្ជាប់ទំនាក់ទំនងរវាងអ្នកនិងមន្ត្រីជាន់ខ្ពស់នៃវិទ្យាស្ថានជាតិស្ថិតិ (NIS) ។ គាត់ នឹងណែនាំដល់អ្នកតាមសេចក្តីណែនាំរបស់មន្ត្រីនៅវិទ្យាស្ថានជាតិស្ថិតិ ហើយអ្នកត្រូវប្រាប់គាត់អំពីបទពិសោធន៍នៃការលំបាកផ្សេងៗ ។ អ្នកត្រូវសុំមតិពីគាត់ឱ្យបានញឹកញាប់អំពីរបៀបដោះស្រាយបញ្ហានៅមូលដ្ឋាន ។ គាត់ជួយអ្នកក្នុងការទំនាក់ទំនងជាមួយប្រធានភូមិ មេឃុំ និងបណ្តាអ្នកតំណាងរបស់ភូមិ ។

4.អ្នកត្រូវសហការជាមួយអ្នកត្រួតពិនិត្យដើម្បីអោយដឹងពីកម្មវិធីនិងការណាត់ជួបអ្នក ក្នុងការចុះត្រួត ពិនិត្យមើលការងាររបស់អ្នក ។ល ។

## ជំពូក ៣

## វិធានការទូទៅសំរាប់ធ្វើការសំភាសន៏

សំរាប់ការអង្កេត TCLT 2005គ្រួសារនឹងត្រូវបានធ្វើការសំភាសន៏ដោយក្រុមអ្នកសំភាសន៏ ។ អ្នកសំភាសន៏ត្រូវសំភាសន៏ចំនួន6គ្រួសារនៅទីប្រជុំជន និង 7 គ្រួសារនៅទីជនបទក្នុងមួយថ្ងៃ ។ ប្រសិនបើ មេគ្រួសារ និងប្តី ឬប្រពន្ធរបស់គ្រួសារ ឬអ្នកទាំងពីរជាអ្នកឆ្លើយអ្នកសំភាសន៏ទាំងពីរនាក់ ។

### 3-1 វិធានការសំរាប់ធ្វើសំភាសន៏

### អ្នកដែលត្រូវធ្វើសំភាសន៏ជាមួយ

+ចំពោះតារាងសំណួរ 1 ធ្វើការចុះបញ្ជីគ្រួសារដែលមាននៅភូមិ អ្នកសំភាសន៏ត្រូវធ្វើការចុះបញ្ជីគ្រួសារគូសផែនទី និងជ្រើសរើសគ្រួសារគំរូដោយខ្លួនឯងតាមការណែនាំនៅក្នុងសៀវភៅណែនាំរបស់អ្នកសំភាសន៏ ។ កិច្ចការទាំងនេះ និងសហការណ៏ជាមួយប្រធានភូមិ ឬអ្នកតំណាងនៅក្នុងភូមិ ។

+ចំពោះតារាងសំណួរទំរង់ ២ ដែលជាសំណួរចាំបាច់នៅក្នុងគ្រួសារ អ្នកសំភាសន៏ត្រូវដើរពីផ្ទះមួយទៅផ្ទះមួយដើម្បីធ្វើការជាមួយរាល់សមាជិកឬសួរផ្ទាល់ជាមួយអ្នកដែលអាចផ្តល់ពតិមានបាន ចំពោះសំណួរទាំងឡាយ ។ ជាពិសេសមេគ្រួសារ( ប្តីឬប្រពន្ធ)ដែលមានលទ្ធភាពបំផុតចំពោះការឆ្លើយមានសំណួរខ្លះយកល្អត្រូវសួរគ្រប់សមាជិកដោយផ្ទាល់ ។

### របៀបដឹកនាំការសំភាសន៏

ការទទួលបាននូវពតិមានច្បាស់លាស់ពេញលេញនៃការអង្កេត TCLT 2005 គឺជាទិសដៅចំបងនៃដំណើរការប្រមូលទិន្នន័យ ។ ជាអ្នកសំភាសន៏មួយរូប អ្នកត្រូវធ្វើការងារនេះដោយភាពសមរម្យនៅគ្រប់ពេលវេលា ប៉ុន្តែនៅព្រមពេលជាមួយគ្នានេះដែរអ្នកត្រូវព្យាយាមធ្វើអោយអ្នកឆ្លើយមានជំនឿទុកចិត្តនិងរក្សាការសំងាត់ ។ ដើម្បីទទួលបានជោគជ័យអ្នកត្រូវមានទំនាក់ទំនងល្អប្រសើរ ។

ការណែនាំដើម្បីធ្វើសំភាសន៏មានដូចខាងក្រោម :

1-សូមឧទ្ទេសនាមខ្លួនឯង

អ្នកជងនឹងមានប្រតិកម្មចំពោះលោកអ្នកតាមរូបភាពផ្សេងៗ ។ ទោះបីយ៉ាងណាក៏លោកអ្នកត្រូវរក្សានូវភាពរួសរាយរាក់ទាក់និងគួរសមជានិច្ច ។ សូមព្យាយាមញញឹមជានិច្ច ។ ត្រូវរៀបចំគ្រប់ប្រភេទសំណួរទាំងអស់ និងទទួលបានចំលើយអោយបានត្រឹមត្រូវ ។ សូមកុំប្រកែក ឬតវ៉ាជាមួយអ្នកឆ្លើយអោយសោះ ។ សូមព្យាយាមរក្សាភាពស្ងាត់ស្ងៀមនឹងធឹង បើទោះអ្នកឆ្លើយខឹងសម្បារ ដោយសារតារាងសំណួរវែងក៏ដោយ ឬដោយសារ មូលហេតុផ្សេងទៀត ។

២-ត្រូវមានភាពសមរម្យ

សំដែងនូវភាពសមរម្យដោយស្លៀកពាក់ស្អាតបាតមិនរយីករយាក ។ មនុស្សមួយចំនួនអោយតំលៃទៅអ្នកដទៃលើសំលៀកបំពាក់ ហើយគេអាចមិនបើកទ្វារអោយអ្នកដែលមានលក្ខណៈរយីករយាក និងគ្មានសណ្តាប់ធ្នាប់ ។

៣-ត្រូវចេះគួរសម

ការឧទ្ទេសនាមខ្លួនឯងគឺមានសារៈសំខាន់ ។ អ្នកត្រូវធ្វើការឧទ្ទេសនាមដោយនិយាយដូចខាងក្រោម នេះ : ជំរាបសួរ ខ្ញុំឈ្មោះ (ឈ្មោះរបស់អ្នក) ជាអ្នកសំភាសន៍នៃវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ ។ នេះជាអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំបច្ចុប្បន្ននេះយើងខ្ញុំកំពុងធ្វើការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារឆ្នាំ 2003-2004 នៅទូទាំងប្រទេស។ ដោយមានការជួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា និង ធនាគារពិភពលោក ខ្ញុំសូមថ្លែងអំណរគុណជានិច្ចចំពោះការចូលរួមឆ្លើយនូវសំណួរក្នុងពេលនេះ។ យើងខ្ញុំសូមធានាថា រាល់ចំលើយទាំងអស់របស់លោកអ្នកនឹងត្រូវរក្សាជាសំងាត់បំផុត ។

៤-សូមពន្យល់ពីគោលបំណងនៃការអង្កេត

មានពេលខ្លះចាំបាច់ត្រូវពន្យល់ពីគោលបំណងនៃការអង្កេត ដើម្បីទទួលបាននូវកិច្ចសហការពីអ្នកដែលយើងបានធ្វើការជាមួយ ។

៥-សូមអាន និងសួរតាមសំណួរដែលមាននៅក្នុងតារាងសំណួរ ។ ការណែនាំមួយចំនួនមានសរសេរនៅខាងលើតារាងសំរាប់កត់ត្រាទិន្នន័យក្នុងតារាងសំណួរ ឬសរសេរក្នុងរង្វង់ក្រចកនៅក្បាលបង្គោល ។ អ្នកសំភាសន៍ត្រូវតែយកចិត្តទុកដាក់មើលអោយសព្វគ្រប់នៅក្នុងតារាងសំណួរ ។

៦-សួរគ្រប់សំណួរទាំងអស់ដែលមាននៅក្នុងតារាងសំណួរ។ មិនត្រូវសន្មត់ចំលើយណាមួយដោយខ្លួនឯងទេទោះបីអ្នកគិតថាអ្នកដឹងចំលើយរបស់សំណួរនោះក្តី ។ ជួនកាលអ្វីដែលអ្នកបានគិតនោះវាអាចមិនមែនជាចំលើយត្រឹមត្រូវរបស់គេទេ ។

៧-បើអ្នកមិនយល់សំណួរទីមួយអ្នកត្រូវអានក្នុងសេចក្តីណែនាំ

បន្ទាប់មកត្រូវសួរទៅអ្នកត្រួតពិនិត្យរបស់អ្នកដើម្បីអោយយល់កាន់តែច្បាស់ (បើចាំបាច់) ។

៨-ត្រូវធ្វើការស្ទាបស្ទង់បើសិនជាចំលើយរបស់គេមិនសមស្របឬមិនពេញចិត្ត ។ មិនត្រូវទទួលយកនូវចំលើយមិនត្រឹមត្រូវនោះទេ ។ បើចំលើយរបស់គេមិនសមស្រប ឬមិនត្រឹមត្រូវអ្នកត្រូវស្ទាបស្ទង់ពតិមានបន្ថែម ។ អ្នកអាចធ្វើតាមវិធីដូចខាងក្រោម :

ក-សួរសំណួរឡើងវិញ ជជីកសួរសំណួរដដែលជាច្រើនដង ដើម្បីជួយអោយអ្នកឆ្លើយអាចផ្តល់នូវចំលើយតាមការរំលឹកនូវការចងចាំរបស់គាត់ ។

ខ-សូមពន្យល់នូវខ្លឹមសាររបស់សំណួរ (បើចាំបាច់)ពីព្រោះមានពាក្យបច្ចេកទេសឬពាក្យពិបាកខ្លះដែលត្រូវការពន្យល់ឡើងវិញជាពាក្យសំរាយ ។

គ-សួរសំរាប់ការប៉ាន់ស្មានមួយបើសមស្រប ។ បើអ្នកឆ្លើយមិនអាចនឹកឃើញឧទាហរណ៍ ដូចជាថ្ងៃ កំណើត និងអាយុរបស់ម្តាយគាត់សូមព្យាយាមសួរសំណួរប៉ាន់ស្មានដើម្បីអោយអ្នកឆ្លើយធ្វើការគណនា ។

៩-សូមថ្លែងអំណរគុណចំពោះអ្នកឆ្លើយ

ជានិច្ចជាកាល សូមព្យាយាមចាកចេញពីអ្នកឆ្លើយក្នុងអារម្មណ៏រីករាយចំពោះការអង្កេត ។ " សូមថ្លែងនូវការដឹងគុណចំពោះកិច្ចសហការរបស់គាត់ ឧទាហរណ៏ និយាយថា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើនចំពោះ បង ពូ មីង លោក យាយ លោកតា ដែលបានចំណាយពេលវេលាក្នុងការឆ្លើយសំណួរ " ។

១០-ក្រោយពីធ្វើសំភាសន៏ចប់គ្រួសារនីមួយៗ

អ្នកត្រូវត្រួតពិនិត្យមើលឡើងវិញនូវពត៌មានដែលអ្នកបានកត់ចូល តើបានត្រឹមត្រូវឬទេ ចៀសវាងភ្លេចរំលងចោល ឬចំលើយមិនស៊ីគ្នា ។

របៀបសួរសំណួរ

ក្នុងពេលសួរសំណួរ សូមធ្វើតាមវិធានការដូចខាងក្រោម :

ក-សួរគ្រប់សំណួរទាំងអស់ដែលមាននៅក្នុងតារាងសំណួរដោយប្រើពាក្យអោយបានត្រឹមត្រូវតាមសំណួរ ។ ការប្តូរពាក្យវាអាចប្តូរន័យរបស់សំណួរហើយម្យ៉ាងទៀតចំលើយក៏អាចប្តូរ ។ សំណួរទាំងអស់ត្រូវបានសរសេរឡើងតាមលំដាប់ដោយមានការប្រុងប្រយ័ត្នបំផុតដើម្បីទទួលបាននូវពត៌មានពិតតាមតម្រូវការរបស់ការវិភាគ ។ សំណួរទាំងអស់ត្រូវបានធ្វើការសាកសួរសាកល្បងនៅពេលធ្វើសំភាសន៏អ្នកមិនត្រូវបង្រួមសំណួរ ឬក៏ខិតខំធ្វើអោយសំណួរច្បាស់ឬក៏ងាយស្រួលសំរាប់ឆ្លើយទេ ។ បើសិនជាអ្នកឆ្លើយសួរអ្នកអោយបញ្ជាក់សំណួរនោះ គឺជាការល្អសំរាប់ផ្តល់ពត៌មានបន្ថែមប៉ុន្តែត្រូវបញ្ជាក់ទៅតាមឯកសារណែនាំនេះប៉ុណ្ណោះ ។ ប្រសិនបើអ្នកឆ្លើយគេ មិនអាចឆ្លើយបានសំណួរណាមួយអ្នកត្រូវកត់បញ្ចូលលេខកូដ" មិនដឹង"សំរាប់បញ្ជាក់ថា "គ្មានចំលើយ " ទៅក្នុងទីតាំងចំហដែលបានផ្តល់ ។ មិនត្រូវកត់បញ្ចូលលេខកូដ "0" ( សូន្យ ) សំរាប់ពត៌មានដែលអ្នកឆ្លើយមិនអាចឆ្លើយបានដោយសារកាលៈទេសៈណាមួយឡើយ ។

ខ-សូមសួរសំណួរតាមលំដាប់លំដោយក្នុងតារាងសំណួរ ។ មិនត្រូវរំលងចោលសំណួរណាមួយផ្នែកណាមួយឬមុខទំនិញណាមួយក្នុងតារាងសំណួរទេ លើកលែងតែមានការណែនាំថាអោយធ្វើ ដូច្នេះ ។

គ-មិនត្រូវអានចំលើយជាលេខកូដទៅអោយអ្នកឆ្លើយទេលើកលែងតែមានការណែនាំអោយធ្វើដូច្នេះ ។ អ្នកសំភាសន៏ត្រូវតែគិតស្វែងយល់ជ្រើសយកលេខកូដដែលសមស្របបំផុតជាមួយចំលើយដែលបានផ្តល់ដោយអ្នកឆ្លើយ ។ បើសិនជាគ្មានលេខកូដសមស្របទេ អ្នកសំភាសន៏ត្រូវប្រើលេខកូដដែលបញ្ជាក់ "ផ្សេងៗទៀត" ហើយកត់បញ្ចូលចំលើយនៅទីតាំងចំហដែលបានផ្តល់ ។ អ្នកសំភាសន៏មិនត្រូវអានលេខកូដចំលើយឬបង្ហាញអោយអ្នកឆ្លើយស្តាប់និងឃើញហើយអោយគេជ្រើសយកចំលើយមួយណានោះទេ លើកលែងតែមានការណែនាំអោយធ្វើដូច្នេះ ។ ការអង្កេតបានរៀបចំឡើងដើម្បីទទួលនូវពត៌មានពីអ្នកឆ្លើយមិនមែនរៀបចំដើម្បីផ្តល់ពត៌មានទៅអ្នកឆ្លើយទេ ។ វាមានសារៈសំខាន់ណាស់ដែលថាអ្នកសំភាសន៏យកចិត្តដាក់ស្តាប់ចំលើយដើម្បីធ្វើអោយការអង្កេតទទួលបានជោគជ័យ និងទទួលបាននូវការពិត និងជំនឿទុកចិត្តរបស់អ្នកឆ្លើយ ។ ក្នុងស្ថានភាពលើកលែងមួយពេលដែលឃើញថាអ្នកឆ្លើយហាក់បីដូចជាមិនអាចមានគំនិតនឹងឆ្លើយ

តបនូវសំណួរណាមួយអ្នកសំភាសន៍អ្នកអាចផ្តល់ជាលេខកូដចំលើយខ្លះដល់គាត់ដើម្បីជាគំនិត ប៉ុន្តែនេះជាការលើកលែងមួយនៃវិធានការ ។

ឃ-ផ្ទៀងផ្ទាត់គ្រប់ទំព័រទាំងអស់នៃតារាងសំណួរដែលរាប់ ។ លេខទំព័រស្ថិតនៅផ្នែកខាងស្តាំដៃនៃជ្រុង ទំព័រនីមួយៗ ។

ង-មិនត្រូវសួរសំណួររបៀបដឹកនាំបញ្ហាឡើយ ព្រោះវាហាក់ដូចជាអោយយោបល់អោយឆ្លើយទៅតាមបំណងប្រាថ្នារបស់អ្នកសួរ ។ ការសួរសំណួរបញ្ហាអ្នកឆ្លើយគិតនិងជឿជាក់ថាចំលើយតាមសំណួមពរនេះ គឺជាចំលើយត្រឹមត្រូវមួយ។ ឧទាហរណ៍ សំណួរដឹកនាំបញ្ហា : តើអ្នកជាមេគ្រួសាររបស់ មេគ្រួសារនេះ ? ឧទាហរណ៍ សំណួរបញ្ហាមួយទៀត : តើអ្នកបានប្រើអង្ករអស់ 10 គីឡូក្រាមនៅសប្តាហ៍មុនមែនទេ ?

ច- ត្រូវមានភាពអព្យាក្រិត្យចំពោះកម្មវត្ថុនៃការសំភាសន៍ ។ ជាធម្មតាមនុស្សភាគច្រើនតែងតែមាន ភាពសមរម្យជាពិសេសជាមួយភ្ញៀវដោយរៀបចំគំរិយាបទទៅតាមការគិតរបស់ពួកគេដែលធ្វើអោយភ្ញៀវ
យល់ថាពួកគេបានទទួលដោយរាក់ទាក់ ។ មិនត្រូវបង្ហាញចេញនូវភាពភ្ញាក់ផ្អើលណាមួយ ឬក៏សាកល្បងលេងជាមួយនឹងចំលើយដែលបានផ្តល់ដោយអ្នកឆ្លើយ ។ បើសិនជាអ្នកឆ្លើយសួរយោបល់ពីអ្នក អ្នកមិនត្រូវប្រាប់គាត់នូវអ្វីដែលអ្នកបានគិតដោយខ្លួននោះទេ។ អ្នកគួរពន្យល់នូវគោលបំណងនៃការអង្កេត គឺដើម្បីទទួលនូវអ្វីដែល អ្នកឆ្លើយបានគិតនិងឆ្លើយនូវសំណួរទាំងអស់ក្នុងតារាងសំណួរ ។ អ្នកមិនត្រូវពិភាក្សាអំពីទស្សនៈខ្លួនអ្នកផ្ទាល់ ជាមួយនឹងអ្នកឆ្លើយទេរហូតដល់ការ សំភាសន៍បានបញ្ចប់ ។ ត្រូវចងចាំថា : ទោះបីជាអ្នកកំពុងធ្វើការសំភាសន៍ ហើយស្ថិតក្នុងគ្រប់ការប្រុងប្រយ័ត្នគ្រប់ពេលអ្នកត្រូវនៅស្តាប់នូវអ្វីដែលអ្នកឆ្លើយបានឆ្លើយពីសំណួរមួយទៅសំណួរមួយ ។ អ្នកត្រូវតាំងខ្លួនជាអ្នកជំនាញខាងស្តាប់ ហើយចៀសវាងការព្យាយាមណែនាំ ឬ"ដឹកនាំ"អ្នកឆ្លើយអោយឆ្លើយនូវចំលើយពិសេសណាមួយ ។

ឆ- សូមប្រកាន់យកនូវការសំភាសន៍តាមដំណើរការធម្មតា។ ចៀសវាងការពិភាក្សាសំណួរវែងអន្លាយជាមួយអ្នកឆ្លើយ។ បើសិនជាអ្នកទទួលបាននូវចំលើយអ្វីដែលមិនទាក់ទង ឬស្មុគ្រស្មាញសូមកុំទាន់កាត់ស្មានភ្លាម អ្នកត្រូវស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីដែលអ្នកឆ្លើយបាននិយាយបើនៅតែមិនយល់សូម សួរសំណួរនេះសារជាថ្មីម្តងទៀត ។

ណ- បញ្ចប់ការកត់ត្រាសំណួរមួយអោយបានត្រឹមត្រូវ មុននឹងចូលទៅសួរសំណួរបន្ទាប់ ។

### 3-2 របៀបកត់ត្រាចំលើយចូលក្នុងតារាងសំណួរ TCLT

សូមប្រើខ្មៅដៃក្នុងការកត់ត្រាចំលើយចូលក្នុងតារាង TCLT ។ មិនត្រូវប្រើខ្មៅដៃពណ៌ ឬក៏ប៊ិចទេ ពីព្រោះពេលមានកំហុសក្នុងការសរសេរចំលើយចូលវាមានការលំបាកក្នុងការលុបចេញ ។ សូមប្រើជ័រលុបសំរាប់លុបចំលើយខុសមិនត្រូវសរសេរជាន់ពីលើកំហុសឡើយ ។ សូមសរសេរអោយបានច្បាស់ងាយអាន ។ បន្ទាប់ពីសំភាសន៍ចប់ភ្លាមសូមពិនិត្យមើលពីដើមឡើងវិញដើម្បីអោយច្បាស់ថាចំលើយទាំងអស់សរសេរច្បាស់អាចអានបាន ។ អ្នកត្រូវបំពេញតារាងសំណួរក្នុងពេលសំភាសន៍ជាក់ស្តែង ។ អ្នកមិនត្រូវសរសេរចំលើយលើក្រដាស់ផ្សេងដោយទុកចាំផ្ទេរចំលើយនេះចូតារាងសំណួរនៅពេលក្រោយឡើយ ឬមួយក៏អ្នកមិនត្រូវកត់ត្រាចំលើយក្នុងខួរក្បាលរបស់អ្នកហើយចាំបំពេញចូលក្នុងតារាងសំណួរ

ក្រោយការចាកចេញពីផ្ទះរបស់គេទេ។ កំរិតកំណត់ភាគច្រើនបានផ្ដល់អោយជាមួយនឹងចំលើយដែលមានលេខកូដទំនាក់ទំនងរបស់វា។ សូមគូសរង្វង់ក៏កត់លេខកូដចូលតាមចំលើយដែលបានឆ្លើយ ។កំរិតកំណត់ផ្សេងតម្រូវអោយសរសេរចូល។ កត់ត្រាចូលនូវចំលើយច្បាស់លាស់ ។ កត់ដោយសង្ខេបខ្លីៗតែច្បាស់លាស់សូមដាក់សញ្ញា (8) សំរាប់គ្រប់ចំលើយណាដែលនៅមានមន្ទិលសង្ស័យដល់អ្នកផ្ទៀងផ្ទាត់ និងដែលត្រូវពន្យល់ឬកំណត់សំគាល់នៅផ្នែកខាងក្រោមនៃទំព័រ ។

**៣-៤** របៀបត្រួតពិនិត្យបញ្ជីសំណួរបំពេញរួច

បន្ទាប់ពីការសំភាសន៍នីមួយៗ ចប់ត្រូវមើលឡើងវិញភ្លាមនូវសន្លឹកចុះតារាងគ្រួសារហើយនឹងតារាងសំណួរ ។ នេះមានន័យថាមើលគ្រប់ការកត់បញ្ចូលទាំងអស់តើអាចមើលច្បាស់ និងមានអត្ថន័យពេញលេញដែលសមស្របស៊ីគ្នាទៅនឹងសំណួរទាំងអស់ឬទេ ។ ត្រួតពិនិត្យមើលគ្រប់សំណួរទាំងអស់មុននឹងប្រគល់ទៅអោយអ្នក ត្រួតពិនិត្យនិងមុនពេលចាកចេញពីភូមិ ។ ទោះបីនៅពេលក្រោយអង្កេតហើយអ្នកនៅមានការសង្ស័យលើចំលើយណាមួយអ្នកត្រូវទទួលយកនូវចំលើយនោះ ប៉ុន្តែសូមសរសេរកំណត់សំគាល់ឬសរសេរការពន្យល់ដើម្បីបង្ហាញភាពងាយស្រួលដល់អ្នកត្រួតពិនិត្យក្នុងការត្រួតពិនិត្យតារាងសំណួរឡើងវិញ ។

# ជំពូក 4

## ទំរង់ការនៃការចុះបញ្ជី និងការសំភាសន៍

ជំពូកនេះរៀបរាប់អំពីទំរង់ TCLT ដែលបានប្រើប្រាស់ជាចំបងនៅពេលចុះធ្វើការសំភាសន៍នៅមូលដ្ឋាន និងការផ្តល់នូវគម្រោងសង្ខេបនៃទំរង់ការ ការងារនៅមូលដ្ឋាន ។ ប្រធានបទ ទាំងនេះត្រូវបានពិភាក្សាលំអិតនៅក្នុងជំពូកក្រោយ ។

4-1. ទំរង់ TCLT

បញ្ជីខាងក្រោមនឹងត្រូវប្រើប្រាស់នៅពេលចុះសំភាសន៍នៅមូលដ្ឋាន ។ តារាងសំណួរគំរូ និងឯកសារដ៏ទៃទៀតបានរៀបចំក្នុងTCLT និង មានការដកចំលងទំរង់ជាក់ស្តែង និងរួមបញ្ចូល TCLT ទំរង់ 1 (ការចុះបញ្ជីគ្រួសារនៅក្នុងភូមិ)ក្នុងសំភារៈសិក្សារបស់អ្នក។ នេះគឺជាទំរង់មួយដែលអ្នកនឹង ត្រូវចុះបញ្ជីអាគារលំនៅដ្ឋាន និងគ្រួសារនៅក្នុងភូមិតំណាង។ អ្នកត្រូវរាយការណ៍ផងដែរនូវពត៌មានផ្សេងៗទៀត ដែលទាក់ទងនឹងអគារនិងគ្រួសារ ។ ការជ្រើសរើសគ្រួសារតំណាងនឹងត្រូវបានបង្ហាញក្នុងបង្គោល (12 )នៃបញ្ជី ។ នៅក្នុងជំពូកនេះពណ៌នានៃក្រុមទំរង់ TCLT ដើម្បីប្រើប្រាស់ក្នុងពេលសំភាសន៍និងផ្តល់នូវគំរោងដ៏សង្ខេបមួយនៃផ្នែកទាំងអស់នេះ ហើយត្រូវបានពិភាក្សានិងលំអិតថែមទៀតក្នុងជំពូកក្រោយៗ ។

TCLT ទំរង់ **២** (បញ្ជីសំណួរសំរាប់គ្រួសារ ) ។

នេះគឺជាតារាងសំណួរគ្រឹះនៃ TCLT ដែលអ្នកត្រូវប្រើវាសំរាប់ការសំភាសន៍ និងរាយការណ៍ពត៌មានអំពីគ្រួសារតំណាងមួយ ។ តារាងសំណួរនេះត្រូវប្រមូលពត៌មានដូចតទៅ :

+ ប្រមូលពត៌មានអំពីលក្ខណៈប្រជាសាស្ត្រ

+ ប្រមូលពត៌មានអំពីការប្រើប្រាស់ថ្នាំជក់

+ ប្រមូលពត៌មានអំពីការយល់ដឹងឥរិយាបទនៃការជក់បារី ការឈប់ជក់បារី, ការផ្អាក់ និងការជក់បារី ឡើងវិញ និងស្ថានភាពរស់នៅ ។

TCLT 2005 និងដំណើរការចំបង ផែនទីហើយត្រូវរៀបចំផងដែរនូវ TCLT ទំរង់ ១ ។

4-ការជ្រើសរើសគ្រួសារគំរូ : ជ្រើសរើសយក 11 គ្រួសារពីភូមិទីកន្លែងសំភាសន៍ក្នុងផ្នែកទីប្រជុំជន 15 គ្រួសារនៅជនបទ ។

5-ការសំភាសន៍ :

សំភាសន៍មេគ្រួសារ ប្តីឬប្រពន្ធរបស់មេគ្រួសារ / សមាជិកផ្សេងទៀតដែល អាចផ្តល់ចំលើយបានក្នុង គ្រួសារ ហើយបំពេញបាននៅសំណួរ 2 សំរាប់គ្រប់ 11 ឬ 15 គ្រួសារតំណាងក្នុងភូមិតំណាង / ផ្នែក ។

## ជំពូក 5

## ទស្សនៈ និង និយមន័យសំខាន់ៗ

ដើម្បីធ្វើអោយទិន្នន័យមានភាពច្បាស់លាស់ត្រូវពឹងផ្អែកទៅលើទស្សនៈ និងនិយមន័យមួយជាមូលដ្ឋាន សំរាប់ប្រើប្រាស់ក្នុងការអង្កេត TCLT 2005 ដែលដឹកនាំដោយវិជ្ជាស្ថានជាតិស្ថិតិ ។ ការអង្កេតនេះបានយកគំរូតាមនិយមន័យ និងទស្សនៈអន្តរជាតិដែលរៀបចំដោយអង្គការសហប្រជាជាតិហើយបានធ្វើការផ្លាស់ប្តូរដើម្បី អោយសមស្របទៅនឹងស្ថានភាពក្នុងប្រទេស ។ ទស្សនៈ និងនិយមន័យដូចគ្នានេះក៏បានយក មកប្រើប្រាស់ផងដែរសំរាប់ TCLT 2005 ។

ជំពូកនេះបានពន្យល់នូវទស្សនៈ និងលក្ខខណ្ឌសំខាន់ៗមួយចំនួនដែលបានយកមកប្រើប្រាស់ក្នុងតារាងសំណួរទាំងឡាយនៃ TCLT -2005 ។

### លំនៅដ្ឋាន

លំនៅដ្ឋានមួយ គឺជារចនាសម្ព័ន្ធមួយដែលដាក់ដោយឡែក ហើយនៅលើទីកន្លែង ឯករាជ្យមួយនៃទីកន្លែងរស់នៅ ។ វាត្រូវបានកសាងឡើង ឬ រៀបចំអោយទៅជាទីកន្លែងដែលសំរាប់មនុស្សរស់នៅ ដូចជាអាគារ ពាណិជ្ជកម្ម ឧស្សាហកម្ម និងកសិកម្ម ឬជាជំរកធម្មជាតិ និងជាជំរកមនុស្សធ្វើ ដូចជារូងភ្នំ ទូក ទូរថភ្លើង ឬឡានដែលគេបោះបង់ចោលរូងក្រោមដី និងរចនាសម្ព័ន្ធប្រហាក់ប្រហែលដទៃទៀត ដែលប្រើប្រាស់សំរាប់ ជាទីកន្លែងរស់នៅ ។

### ក្រុមគ្រួសារ

ក្រុមគ្រួសារមួយ គឺជាមនុស្សមួយក្រុម (ឬក៏មនុស្សតែម្នាក់) ដែលជានិច្ចកាលរស់នៅជាមួយគ្នាហូបចុក រួមគ្នាប្រើប្រាស់ចង្ក្រាន ឬចំរិកាទិញម្ហូបរួមជាមួយគ្នា ។ មនុស្សទាំងអស់នោះអាចជាសាច់ញាតិជាមួយគ្នា ឬមិនមែនសាច់ញាតិរួមគ្នា អ្នកបំរើ ឬ និយោជិកផ្សេងៗដែលស្នាក់នៅជាមួយនិយោជក ។

សិស្ស អ្នកជួលបន្ទប់ និងនិយោជក ដែលរស់នៅដោយមានការចាត់ចែងរៀបចំម្ហូបអាហារហូបរួមគ្នា ជាមួយគ្រួសារត្រូវបានចាត់ចូលជាសមាជិកគ្រួសារ ក្នុងករណីពួកគេបានមករស់ជាមួយគ្រួសារនេះមានរយៈពេលច្រើនជាងមួយឆ្នាំ ឬក៏ពួកគេគ្មានកន្លែងស្នាក់នៅផ្សេងទៀតទេ ។ទោះបីជាយ៉ាងណាក៏ដោយ បើសិនជាមានអ្នកជួលបន្ទប់របស់ក្រុម គ្រួសារមួយស្នាក់នៅដោយមាន គ្នា5នាក់ ឬលើស ពួកគេនេះមិនចាត់ចូលជា សមាជិកក្រុមគ្រួសាររបស់គ្រួសារជាម្ចាស់បន្ទប់នោះឡើយ ។ ពួកគេទាំងនេះត្រូវចាត់ចូលជាអ្នករស់នៅក្នុងបន្ទប់ ឬផ្ទះជួលរបស់គ្រួសារនោះ ។ ការជួលបន្ទប់ ឬ ផ្ទះស្នាក់នៅរួមគ្នាពី 5 នាក់ ឡើងទៅត្រូវចាត់ទុកជា គ្រួសារស្ថាប័ន ។ គ្រួសារស្ថាប័ន គឺជាក្រុមមនុស្សមិនមែនជាសាច់ញាតិចាប់ពី 5 នាក់ឡើងទៅរស់នៅរួមជាមួយគ្នា ។ ឧទាហរណ៍ ផ្សេងៗ ដូចជា បន្ទាយទាហាន ពន្ធនាគារ សិស្សរស់នៅជាក្រុម ។ល។ គ្រួសារស្ថាប័នមិនចាត់ចូលក្នុងការអង្កេត TCLT –2005 ទេ ។ គ្រួសារជនបរទេសត្រូវបានរួមបញ្ចូលក្នុងការអង្កេតនេះ ។

## មេគ្រួសារ

មេគ្រួសារ គឺជាសមាជិកគ្រួសារពេញវ័យម្នាក់ដែលក្រុមគ្រួសារបានទទួលស្គាល់ និងចាត់ទុកថា ជាមេគ្រួសារ ។

## សមាជិកជាប្រចាំរបស់ក្រុមគ្រួសារ

សមាជិកជាប្រចាំម្នាក់របស់គ្រួសារ គឺជាមនុស្សណាមួយដែលតែងតែរស់នៅក្នុងក្រុមគ្រួសារហើយមានការចាត់ចែងហូបចុកជាមួយគ្នាយ៉ាងហោចណាស់រយៈពេលមួយឆ្នាំ ឬក៏មនុស្សណាមួយដែលគ្មានកន្លែងស្នាក់នៅដ៏ទៃទៀត។ ដូច្នេះសិស្សភាគច្រើនដែលទៅរៀននៅសាលាឆ្ងាយពីផ្ទះត្រូវបានចាត់ទុកជាសមាជិករបស់គ្រួសារធម្មតាមិនត្រូវចាត់ទុកគេជាសមាជិករបស់គ្រួសារដែលមានទីតាំងក្នុងសាលារបស់គេឡើយលើកលែងតែពួកគេស្នាក់នៅក្នុងសាលារយៈពេលលើសពីមួយឆ្នាំ ។ ទោះបីយ៉ាងណាក៏ដោយ មនុស្សម្នាក់ទើបតែបានផ្លាស់ប្តូរទីកន្លែងថ្មីៗ ឧទាហរណ៍តិចជាងមួយឆ្នាំកន្លងមកត្រូវចាត់ទុកជាសមាជិករបស់គ្រួសារដែលគាត់កំពុងស្នាក់នៅ បើសិនជាគាត់គ្មានផែនការនឹងត្រឡប់ទៅនៅជាមួយគ្រួសារចាស់របស់គាត់វិញទេក្នុងរយៈពេលមួយឆ្នាំ។ ដូចគ្នានេះដែរមនុស្សម្នាក់ដែលបានផ្លាស់ទីកន្លែងចេញពីគ្រួសាររបស់គេក្នុងពេលថ្មីៗ ដោយមានគំរោងថា នឹងមិនវិលត្រឡប់ទៅវិញទេនោះ ក៏ត្រូវចាត់ចូលជាសមាជិករបស់គ្រួសារដែលគេទើបតែទៅរស់នៅជាមួយនោះដែរ ។

## ពិការភាព

ការខ្វះសមត្ថភាពឬនៃការរារាំង ដែលមិនអាចចូលរួមឬធ្វើសកម្មភាពរបស់មនុស្សត្រូវចាត់ទុកថាពិការ ។ វាបង្ហាញ ពីលក្ខខណ្ឌដែលមានកំរិតកំណត់ ឬរារាំងមិនឱ្យចូលរួមធ្វើសកម្មភាពដោយសារមូលហេតុមិនអាចធ្វើទៅកើត ។ ការអង្កេតត្រូវប្រមូលពតិមានចំពោះមនុស្សដែលមានបញ្ហាចំបងជាមួយនឹងសារពាង្គកាយសតិបញ្ញា ឬឥរិយាបថដែលរារាំងគេមិនឱ្យចូលរួមក្នុងការងារ ការសិក្សា ឬជីវភាពសង្គមធម្មតាដែលមានលក្ខណះជា អចិន្ត្រៃយ៍ ឬមានរយៈពេលយូរ ប៉ុន្តែមិនមែនជាជំងឺបណ្តោះអាសន្នឡើយ ។

**អង្គការសុខភាពពិភពលោកបានអោយនិយមន័យថា :**

ភាពទន់ខ្សោយ គឺបាត់បង់នៅអ្វីមួយ ឬភាពមិនប្រក្រតីនៃប្រព័ន្ធ ឬមុខងារផ្នែកប្រព័ន្ធចិត្តសាស្ត្រ សរីរៈវិទ្យា ឬកាយវិទ្យា ។ ពិការភាពគឺជាការរារាំង ឬកង្វះនូវសមត្ថភាពបំពេញសកម្មភាពអ្វីមួយ(ដែលកើតចេញពីការអន់ខ្សោយ) ទៅតាមលក្ខណៈត្រឹមត្រូវ និងសមស្របតាមប្រក្រតីភាពរបស់មនុស្សម្នាក់ៗ ។

សង្គមខ្មែរយល់ថា :

**ពិការភាព គឺជាការបាត់បង់នូវវិញ្ញាណណាមួយ ឬច្រើន**

តើមានន័យយ៉ាងដូចម្តេច ? នៅសហគមន៍របស់អ្នក អ្នកតែងបានឃើញមនុស្សខ្លះមានការពិបាកអ្វីមួយដែលមនុស្សដ៏ទៃពុំធ្លាប់មាន ។ ជាឧទាហរណ៍ អ្នកតែងបានឃើញមនុស្សខ្លះមានការពិបាកក្នុងការមើលខ្លះពិបាកស្តាប់ ពិបាកក្នុងការ

និយាយទាក់ទងគ្នា ឬចល័តទៅណាមិនដូចមនុស្សដ៏ទៃ ។ មនុស្សខ្លះបង្ហាញនូវអត្តចរិក ចំឡែក ឬដៃ និង ជើងបាត់បង់នូវញ្ញាណ ។ ភាពពិបាកទាំងនេះគេហៅថា ពិការភាព ។

| ប្រភេទពិការភាព | និយមន័យ | លក្ខណៈពិការភាព |
|---|---|---|
| ពិបាកក្នុងការមើល | អ្នកទាំងឡាយណាដែលមានលទ្ធភាពសំឡឹង មើលចុះខ្សោយ ឬមិនអាចមើលឃើញវត្ថុ ។ | ឧទាហរណ៏ៈងងឹតភ្នែកម្ខាងឬទាំងសងខាង.ស្វិតសសៃបាតភ្នែក.ភ្នែកល្វៀនមើលមិនឃើញ ខ្សោយសាច់ដុំភ្នែក សំឡាកកញ្ចក់ភ្នែក. សម្ពាធ ទឹកក្នុងភ្នែក. រលាកសសៃបាតភ្នែក. ងងឹតតពូជ |
| ពិបាកក្នុងការស្តាប់ | អ្នកទាំងឡាយណាដែលមានលទ្ធភាពស្តាប់ចុះខ្សោយ (ពីកំណើតរបួសឬដោយសារមេរោគ)និងមនុស្ស ចាស់ | ឧទាហរណ៏ : មនុស្សថ្លង់. ធ្លាយក្រដាសត្រចៀក ត្រចៀកអត់រន្ធ |
| ពិបាកក្នុងការនិយាយ | អ្នកទាំឡាយណាដែលមានការលំបាកក្នុងការ និយាយ និយាយមិនច្បាស់ឬអត់និយាយរួច ទាល់តែសោះ ឬអ្នកដ៏ទៃទៀត ពិបាកស្តាប់ ។ | ឧទាហរណ៏ៈអ្នកនិយាយត្រឡាន់(អណ្តាតធំ)/ត្រដិត .ឆែបពិដានមាត់(ក្រឡើត)-ក្រងូរ. គ. ធ្មេញលើក្រោម ជាប់គ្នា ។ |
| ពិបាកក្នុងការធ្វើចលនា | អ្នកទាំងឡាយណា ដែលមានលទ្ធភាព ធ្វើចលនា បំលាស់ទីដោយលំបាក | ឧទាហរណ៏ៈដាច់ដៃដាច់ជើង ស្វិតដៃជើង ខ្សោយសាច់ដុំ គាំងសន្លាក់សាច់ដុំតឹងខ្លាំង ខូចគ្រឿងបញ្ជាចលនាខួរក្បាល ជើងខ្វេ ជើងកែក ជើងខើច ស្លាប់មួយចំហៀង/កំណាត់ខ្លួន/ស្លាប់អវៈយវៈទាំងបួនទន់សរសៃឆ្អឹងខ្នងវៀចភ្លាត់ត្រគាកបាក់ឆ្អឹង រលាកសន្លាក់ របេងឆ្អឹង គមខ្នង (កោងទៅមុខ និងកោងទៅក្រោយ ) |
| ពិបាកខាងកាយវិញ្ញាណ | អ្នកទាំងឡាយណាដែលបាត់បង់ការដឹងដោយកាយវិញ្ញាណ | ឧទាហរណ៏ៈអ្នកពិការដោយសារឃ្លង់(កំរិតធ្ងន់)អ្នកស្ពឹកដៃជើង ស្លាប់មួយកំណាត់ឬចំហៀងខ្លួនឬអវៈយវៈទាំងបួន កង្វះជីវជាតិ(អាចហើមស្បែក) |
| ពិបាកខាងផ្លូវចិត្ត | អ្នកទាំងឡាយណាដែលមាន អកប្បកិរិយា មិនប្រក្រតីដែលកើតឡើងជាប្រចាំ | ឧទាហរណ៏ : អ្នកដែលដើរអត់សំលៀកបំពាក់. អ្នកដែលនិយាយ/ សើច/ ច្រៀងរាំ/លេងតែម្នាក់ឯង ខុសពីប្រក្រតី ស្ងឹងស្មាត ដេរគេដេរឯង វែបឬប្រព្រឹត្តអំពើហឹង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ ជំងឺមន្ទិល សង្ស័យ វិកលចរិត ឆ្កួតសតិអារម្មណ៏ តានតឹងផ្លូវចិត្ត ជំងឺធ្លាក់ទឹកចិត្ត ថប់អារម្មណ៏ |
| ពិបាកក្នុងការរៀនសូត្រ | អ្នកទាំងឡាយណា ដែលមាន លទ្ធភាព ចងចាំ ខ្សោយ ភ្លេចច្រើន | ឧទាហរណ៏ : ដោនស៊ីនដ្រូម អ្នកដែលមានប្រាជ្ញា លូតលាស់យឺត អ្នករៀនខ្សោយ/ ការចងចាំនៅមានកំរិត ជំងឺផ្លូវចិត្តក្មេង(ឡប់សតិ) |
| អ្នកដែលមានប្រកាច់ | អ្នកទាំងឡាយណា ដែលមានការ ប្រកាច់ដោយញឹកញាប់ដោយមូលហេតុអ្វីមួយ | ឧទាហរណ៏ៈអ្នកដែលមានជំងឺឆ្កួតជ្រូកប្រកាច់ដោយសារលើសឈាម ឬខ្វះឈាម.....។ |
| ពិការផ្សេងៗ | អ្នកទាំងឡាយណាដែលមានការលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ។ | ឧទាហរណ៏ៈអ្នកដែលមានមុខមាត់ខូចទ្រង់ទ្រាយ/អាក្រក់អ្នកដែលមានជំងឺរាំរៃ.មនុស្សតឿ/ក្រិន.អ្នកមានមេរោគអេដស៏ក្មេងមានក្បាលធំ.ផ្លែលើស្បែក (កំរិតខ្លាំង ) |

## ជំងឺ

សំរាប់គោលបំណងនៃការអង្កេតនេះ សុខភាពរយៈពេលខ្លី ឬ រយៈពេលវែង ដូចជាជំងឺ របួស ឬ បញ្ហាទាក់ទងទៅនឹងផ្ទៃពោះ (មានគភ៌) ត្រូវចាត់ទុកថាជាអ្នកជំងឺ ។

## អក្ខរកម្ម

អក្ខរកម្ម គឺជាសមត្ថភាពដែលអាចចេះអាន និង សរសេរនូវលិខិតងាយៗ ។ អ្នកដែលចាត់ទុកជាអ្នកចេះអក្សរ គឺអ្នក ដែលអាចអាន និងសរសេរនូវលិខិតងាយៗ ជាភាសាណាមួយ ឬ គ្រាមភាសា ។ អ្នកដែលមានសមត្ថភាពចេះតែអានឈ្មោះរបស់ខ្លួន ឬ លេខ ឬ ក៏អាចចេះតែអាន ប៉ុន្តែមិនចេះសរសេរ ឬ ផ្ទុយមកវិញនោះ មិនចាត់ទុកជាអ្នកចេះអានអក្សរឡើយ ។

## ការងារ

ការងារ គឺជាសកម្មភាពសេដ្ឋកិច្ច ដែលមនុស្សបានធ្វើដើម្បីទទួលប្រាក់ឈ្នួល ប្រាក់ចំណេញ ឬបង្កើនចំណូលគ្រួសារ ។ ការងាររួមមាន ការងារដែលមានប្រាក់បៀវត្សរ៍ ឬប្រាក់ឈ្នួល ឬការងារកសិដ្ឋាន ឬ ជំនួញការងារសំរាប់សកម្មភាពសេដ្ឋកិច្ចគ្រួសារ (ដូចជាការកែឆ្នៃ ម្ហូបអារហារ ឬ ចិញ្ចឹមសត្វ ) ដោយមិនយក ប្រាក់កំរៃការងារជាកូនជាងដើម្បីយកចំណេះ ឬ ជំនាញ ដោយមិនទទួលប្រាក់ឈ្នួល និង ការផលិតស្រូវ ឬ បន្លែដែលសំរាប់ប្រើប្រាស់ក្នុងក្រុមគ្រួសារ ។ រាប់បញ្ចូលផងដែរ ចំពោះអ្នកមានការងារធ្វើទោះជាគាត់ឈប់ជាបណ្តោះអាសន្នដោយមូលហេតុវិស្សមកាល កូដកម្ម ឬជំងឺ ។ ការផលិតនូវអចលនៈទ្រព្យសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនដូចជា ការ សាងសង់ ឬជួលជុលផ្ទះ ក៏ចាត់ទុកថាការងារដែរ ។

## អ្នកចូលរួមក្នុងកំលាំងពលកម្ម ឬ សកម្មភាពសេដ្ឋកិច្ច

អ្នកចូលរួមក្នុងកំលាំងពលកម្ម ឬ សកម្មភាពសេដ្ឋកិច្ច គឺជាអ្នកមានការងារធ្វើ ឬ អាចធ្វើការក្នុងការផលិតទំនិញ និងសេវាកម្មក្នុងប្រទេស ។ ពួកគេអាចជាអ្នកមានការងារធ្វើ ឬ មិនមានការងារធ្វើ ។

## អ្នកមានការងារធ្វើ

អ្នកមានការងារធ្វើ គឺជាអ្នកដែលចូលរួមក្នុងកំលាំងពលកម្ម ដែលអាចរាយការណ៍ថាបានធ្វើការងារ ឬ ជំនួញទោះបីជាមិនបានធ្វើការក្នុងរយៈពេលជាសប្តាហ៍ក៏ដោយ ។ អ្នកមានការងារធ្វើ គឺជាអ្នកបានធ្វើគ្រប់ការងារទាំងអស់សូម្បីតែមួយម៉ោងក្នុងរយៈពេលមួយសប្តាហ៍កន្លងមកក៏ដោយ ។ អ្នកដែលចាត់ទុកថាមានការងារធ្វើប្រសិនបើអ្នកទាំងនោះមានការងារ ឬជំនួញទោះបីមិនបានធ្វើការក្នុងរយៈពេលមួយសប្តាហ៍កន្លងមកដោយសារមូលហេតុឈប់ជាបណ្តោះអាសន្នដោយសារជំងឺ របួស វិស្សមកាល ឬ ឈប់សំរាកផ្សេងៗ ដោយសារអាកាសធាតុមិនល្អ កូដកម្ម ឬមូលហេតុ ដ៏ទៃទៀត ។

## អ្នកគ្មានការងារធ្វើ

អ្នកគ្មានការងារធ្វើ គឺជាអ្នកដែលនៅក្នុងកំលាំងពលកម្ម ហើយមិនបានធ្វើការ ឬ គ្មានការងារធ្វើ ឬ គ្មានជំនួញធ្វើក្នុងរយៈពេលមួយកន្លងមកសប្តាហ៍ ប៉ុន្តែបានរាយការណ៍ថាអាចធ្វើការងារបាន និងកំពុងស្វែងរកការងារធ្វើក៏ចាត់ទុកជាអ្នកគ្មានការងារធ្វើផងដែរ ។ ចំពោះអ្នកគ្មានការងារធ្វើឬគ្មានជំនួញធ្វើប៉ុន្តែបានរាយការណ៍ ថាអាចរកការងារបាន

ហើយមិនស្វែងរកការងារធ្វើដោយសារពួក គេជឿជាក់ថាគ្មានការងារធ្វើ ឬ ដោយសារមាន ជំងឺ ឬ របួសដោយបណ្តោះអាសន្ន អាកាសធាតុមិនល្អ រង់ចាំលទ្ធផលដាក់ពាក្យសុំការងារ ឬ រង់ចាំការសំភាសន៍ ដើម្បីចូលធ្វើការ ។

## ខ្លួនទីពឹងខ្លួន

គឺជាអ្នកដែលដំណើរការនូវសកម្មភាពសេដ្ឋកិច្ចផ្ទាល់ខ្លួនរឺម្ចាស់ការនៅក្នុងវិជ្ជាជីវៈឬពាណិជ្ជកម្មនិងការជួលដោយគ្មានកម្មករ ។

## មុខរបរ

មុខរបរ គឺជាប្រភេទការងារ ពាណិជ្ជកម្ម ឬ វិជ្ជាជីវៈ ដែលធ្វើដោយបុគ្គលក្នុងរយៈពេលមួយកំណត់ បើគាត់មិនធ្វើការ ប៉ុន្តែមានការងារ នោះមុខរបរគឺជាប្រភេទនៃការងារដែលគាត់រាយការណ៍អំពីការងារ ។

## មុខរបរចំបង

បើគាត់មានមុខរបរលើសពីមួយ ហើយមានមុខរបរមួយ ដែលគាត់យល់ឃើញថាវាសំខាន់ជាងគេដោយផ្អែកទៅតាមពេលវេលាដែលបានចំណាយចំណូលដែលរកបាន និងតាមផ្លូវច្បាប់ និងស្ថានភាពសង្គមនោះគឺជាមុខរបរចំបង ។

## មុខរបរបន្ទាប់បន្សំ

មុខរបរបន្ទាប់បន្សំ គឺជាការងារដែលគាត់បានធ្វើដើម្បីប្រាក់ឈ្នួល ឬ ប្រាក់បៀវត្សរ៍ ប្រាក់ចំណេញ ឬ បង្កើនចំណូលគ្រួសារ ហើយដែលគាត់យល់ឃើញថាវាជាមុខរបរសំខាន់បន្ទាប់ក្នុងចំណោមមុខរបរទាំងអស់ ដោយមិនរាប់ទាំងមុខរបរចំបង ។

## សកម្មភាពសេដ្ឋកិច្ច

សកម្មភាពសេដ្ឋកិច្ច គឺជាប្រភេទការងារដែលធ្វើ ( ផលិតទំនិញ និង សេវាកម្ម ) ដោយស្ថាប័ន ឬ សហគ្រាស ឬកន្លែងធ្វើការដទៃទៀត ដែលគាត់ធ្វើការ ។

## ការចំណាយរបស់ក្រុមគ្រួសារ

ការចំណាយរបស់ក្រុមគ្រួសារ គឺជាចំណាយ ដែលបង្កើតឡើងដោយក្រុមគ្រួសារសុទ្ធសាធសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។ គ្រឿងសង្ហារឹម និងឧបករណ៍សំភារៈប្រើប្រាស់បានយូរ ( ដូចជា តុ និង កៅអី រថយន្តម៉ូតូ និង សំភារៈប្រើប្រាស់ដទៃទៀត ) ដែលបានទិញក្នុងរយៈពេលមួយកំណត់សំរាប់ប្រើប្រាស់ក្នុងក្រុមគ្រួសារត្រូវចាត់ ទុកជាការប្រើប្រាស់របស់ក្រុមគ្រួសារ ។

## ការប្រើប្រាស់របស់ក្រុមគ្រួសារ

ការប្រើប្រាស់របស់ក្រុមគ្រួសាររួមមាន :

ក-ការចំណាយរបស់ក្រុមគ្រួសារ ។

ខ-តំលៃទំនិញ និងសេវាកម្ម ដែលទទួលបានជាអំណោយ ។

គ-តំលៃទំនិញ និងសេវាកម្មដែលប្រើប្រាស់យកមកពីផលិតផលនៃសកម្មភាពកសិកម្ម និងមិនមែនកសិកម្ម របស់គ្រួសារ ។

ឃ-តំលៃប៉ាន់ស្មាន នៃថ្លៃជួលផ្ទះដែលនៅដោយមិនបាច់បង់លុយ និងផ្ទះនៅដោយក្រុមគ្រួសារ ។

ង-តំលៃប៉ាន់ស្មានទំនិញ ឬសេវាកម្មដែលទទួលបានជាប្រាក់បន្ថែម ឬប្រាក់បន្ទាប់បន្សំ ពីនិយោជក ឬ ផ្នែកខ្លះនៃប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួលពីការងាររបស់សមាជិកគ្រួសារក្នុងរយៈពេលមួយកំណត់ដែលត្រូវបានយកមកប្រើប្រាស់ក្នុងរយៈពេលមួយកំណត់ ។

**មុខទំនិញប្រើប្រាស់បានយូរ** ឬ មូលធនដែលជាធម្មតាប្រើប្រាស់លើសពីមួយឆ្នាំជាកម្មសិទ្ធរបស់ក្រុម គ្រួសារ ហើយប្រើប្រាស់សំរាប់ក្នុងគោលបំណងជំនួញ ឬ ប្រើប្រាស់ក្នុងក្រុមគ្រួសាររួមមាន ដីធ្លី និងអគារត្រូវចាត់ ទុកជាទ្រព្យសកម្ម ។

**សាលារៀន** : សាលារួមបញ្ចូល អ្នកដែលរៀននៅមតេយ្យ, បឋមសិក្សា, មធ្យមសិក្សា, សិក្សាបច្ចេកទេស ឬសាលា វិជ្ជាជីវៈ, វិទ្យាល័យ ឬ សកលវិទ្យាល័យ ។

**ការសិក្សា**

ការសិក្សារួមមានការចូលរៀននៅមត្តេយ្យសាលាបឋមសិក្សាអនុវិទ្យាល័យវិទ្យាល័យសាលាបណ្តុះបណ្តាល បច្ចេកទេស វិជ្ជាជីវៈ មហាវិទ្យាល័យ ឬសកលវិទ្យាល័យ ។

**ប្រាក់ឈ្នួល**

ប្រាក់ឈ្នួល រួមមានចំណូលដែលទទួលបានជាសាច់ប្រាក់ ប្រាក់ទឹកតែ ប្រាក់កំរៃជើងសារ ដែលជាមួយផ្នែកនៃប្រាក់ចំណូលប្រាក់ លើសម៉ោង និងតំលៃប៉ាន់ស្មាននៃប្រាក់ចំណូលជាវត្ថុឬជារបស់ ដូចជាអាហារឬ ផ្ទះ សំលៀកបំពាក់ដែលផ្តល់ឱ្យដោយនិយោជកដោយពុំគិតថ្លៃ ។

# ជំពូក 6

## បញ្ជីសំរង់គ្រួសារនៅក្នុងភូមិ ( TCLT ទំរង់ 1)

នៅក្នុងជំពូកនេះ រៀបរាប់លំអិតអំពីរបៀបគូសផែនទី និងណែនាំ សំរាប់ការបំពេញតារាងចុះបញ្ជី គ្រួសារ និងការជ្រើសរើសគ្រួសារគំរូនៅក្នុងភូមិ TCLT នៅទំរង់ 1 ( តារាង ចុះបញ្ជីគ្រួសារ ) របស់ភូមិគំរូ ។ ជាធម្មតាអ្នកត្រួតពិនិត្យត្រូវទៅតាមដានជាមួយនឹងអ្នកសំភាសន៍ នៅពេលដែលអ្នកសំភាសន៍ចុះទៅភូមិលើកដំបូងហើយជួយទំនាក់ទំនង ប្រធានឃុំ និងប្រធានភូមិ ។ មុនពេលធ្វើការចុះបញ្ជីគ្រួសារ អ្នកសំភាសន៍ដែលបានចាត់តាំងអោយទទួលធ្វើការនៅក្នុងភូមិតំណាង មួយត្រូវបានផ្តល់ជូនជាមុននូវផែនទីរបស់ភូមិដែលក្នុងនោះមានបែងចែកនូវចំនួនតំបន់អង្កេត (EA) ។ បន្ទាប់មកត្រូវធ្វើការចុះបញ្ជីនូវគ្រប់អគារលំនៅដ្ឋាន និងគ្រួសារទាំងអស់ទៅក្នុង TCLT តារាងសំណួរ 1 ។

### 1- ដំណើរការគូរផែនទី

ភូមិតំណាងបានកំណត់ដោយផ្អែកទៅលើបញ្ជីឯកសារជំរឿនប្រជាជននៅឆ្នាំ 1998 ។ ភូមិគំរូដែលបានជ្រើសរើស គឺតាមរយៈការប្រើប្រាស់កម្មវិធីកុំព្យូទ័រ ។ អ្នកសំភាសន៍នឹងត្រូវបានផ្តល់ជូននូវផែនទីភូមិដែលមាន បង្ហាញពីចំនួន EAs ទាំងអស់របស់ភូមិ និង EA ដែលត្រូវជ្រើសរើសសំរាប់ចុះបញ្ជីគ្រួសារ និងតារាងបញ្ជីភូមិគំរូ ។ ទោះបីយ៉ាងណា អ្នកសំភាសន៍ត្រូវជួបនឹងសហការជាមួយប្រធានភូមិ ប្រធានឃុំ ឬមនុស្សតំណាងណាម្នាក់របស់ ភូមិ ដើម្បីសាកសួរពតិមានលំអិតបន្ថែមអំពីភូមិតំណាងនេះ មុននឹងដំណើការបន្តលើការគូរផែនទីលំអិត ។

មុននឹងដំណើរការចុះបញ្ជីអាគារ លំនៅដ្ឋាន និងគ្រួសារនៅក្នុងភូមិតំណាង / តំបន់អង្កេត ***អ្នកសំភាសន៍ត្រូវរៀបចំផែនទីលំអិតរបស់ភូមិ / តំបន់អង្កេត*** ដោយមានបង្ហាញច្បាស់ពីព្រំទ្រល់ និងរូបភាពជាទូទៅព្រមទាំងសណ្ឋានផ្ទៃដី ដូចជា ផ្លូវ កូនភ្នំ ទន្លេ ។ល។ ផែនទីនេះមានសារៈសំខាន់ណាស់សំរាប់ពេលដំណើរការ ចុះបញ្ជី ។

សូមធ្វើការណែនាំខាងក្រោមដើម្បីរៀបចំគូរផែនទីលំអិត :

ក. សូមដើរជុំវិញភូមិ/តំបន់អង្កេតដែលបានប្រគល់អោយអ្នកហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនអ្នកផ្ទាល់ ។ បន្ទាប់មករៀបចំគំរោង ឬផែនទីលំអិតរបស់ភូមិ /តំបន់អង្កេតដែលបង្ហាញពីភូមិ សាស្ត្រលំអិត ។

ខ. សូមចាប់ផ្តើមចេញពីកន្លែងកាច់ជ្រុងណាមួយ ឬក៏ពីចំណុចសមស្របណាមួយហើយ ដើរជុំវិញភូមិ / តំបន់អង្កេតតាមប្រព័ន្ធទិសដៅទ្រនិចនាឡិកាហើយគូររូបអាគារ និងរចនាសម្ព័ន្ធប្រហាក់ប្រហែលនៅលើផែនទីលំអិតដោយប្រើប្រាស់និមិត្តសញ្ញាដែលបានផ្តល់អោយនៅក្នុងផែនទីភូមិ ។

គ.នៅលើផែនទីលំអិត សូមគូសរង្វង់មូលតំណាងអោយអាគារ ។ អាគាទីមួយដែលអ្នកបានចាប់ផ្តើមចេញដំណើរសូមគូសរង្វង់មូលនិងអក្សរ S នៅជុំវិញលេខ 1 ព្រមទាំងសញ្ញាព្រួញសំរាប់បង្ហាញទិសដៅដែលអ្នកត្រូវដើរចុះបញ្ជី ក្នុងតំបន់អង្កេត ។ នៅក្នុងរង្វង់ សូមសរសេរលេខរៀងអាគារហើយនៅខាងក្រោមរង្វង់សូម សរសេរលេខរៀង

គ្រួសារនៅក្នុងរង្វង់ក្រចកដែលរស់នៅក្នុងអាគារនេះ ។ បើសិនជាមានច្រើនគ្រួសាររស់នៅក្នុងអាគារតែមួយសូមចុះតាមលេខរៀងតាមលំដាប់ជួររបស់គ្រួសារ របស់ទាំងនោះ ។

ឧទាហរណ៍ : បើសិនជាអគារទីមួយដែលបានគូសនៅលើផែនទី មាន ៣គ្រួសាររស់នៅអ្នកត្រូវសរសេរ ដូចខាងក្រោម:




នៅទីនេះ លេខ 1 ដែលនៅក្នុងរង្វង់មូល គឺជាលេខរៀងលំដាប់អគារ ហើយ ១-៣ នៅក្នុងរង្វង់ក្រចក គឺជាលេខរៀងលំដាប់គ្រួសារដែលរស់នៅក្នុងអគារនោះ ។ដង់ស៊ីតេប្រជាជននៅក្នុងភូមិឬតំបន់អង្កេតយើងមិនចាំបាច់គូរអគារទាំងអស់នៅលើផែនទីទេ ចៀសវាងការរាយប៉ាយច្រើន ។ អ្នកគ្រាន់តែគូរអគារទីមួយ អាគារទីពីអាគារទីបីដែលបានចុះបញ្ជី ហើយបន្ទាប់មកទៀត រំលងទៅអគារទីប្រាំមួយ រឺអគារទីប្រាំបីជាតំណាង។ បើសិនជាអាចធ្វើទៅបានសូមបន្តធ្វើការចុះបញ្ជីតាមទិសដៅដដែលរហូតដល់គ្រប់គ្រួសារទាំងអស់ដូចក្នុងទិសដៅដែលបានចុះមកពីដំបូង។ ពេលណាដែលទិសដៅដែលយើងបានដើរចុះបញ្ជីនោះត្រូវប្តូរសូមគូសបង្ហាញសញ្ញាព្រួញថ្មីមួយទៀត ។

សូមចុះពិនិត្យផ្ទាល់ដល់គ្រប់អាគារ ឬរចនាសម្ព័ន្ធក្នុងតំបន់អង្កេត ដើម្បីអោយដឹងច្បាស់ថាមានប៉ុន្មានគ្រួសាររស់នៅក្នុងតំបន់អង្កេតដែលយើងធ្វើការចុះបញ្ជី។ ត្រូវយកចិត្តទុកដាក់អំពីការិយាល័យ/អគារពាណិជ្ជកម្មហើយនិងទីតាំងសំណង់មិនត្រូវផាត់ចោលគ្រួសារដែលរស់នៅក្នុងនោះទេ ។

សូមមើលការណែនាំខាងក្រោម អំពីការចុះបញ្ជីអគារ លំនៅដ្ឋាន និងគ្រួសារក្នុងភូមិ/ តំបន់អង្កេត តំណាងក្នុង TCLT ទំរង់ 1 ។

**2-របៀបបំពេញ TCLT** ទំរង់ 1 ( ការចុះបញ្ជីគួសារ)

ការចុះបញ្ជីឬការត្រួតពិនិត្យសាកសួរគ្រួសារត្រូវបានដំណើរការជាមួយគ្នានឹងការរៀបចំគូរផែនទីលំអិត ។ ពេលអ្នកសំភាសន៍ពិនិត្យឃើញថាមានគ្រួសារមួយ ឬ ច្រើនរស់នៅក្នុងអគារតែមួយ ឬក៏រចនា សម្ព័ន្ធតែមួយត្រូវបង្ហាញទីតាំងអគារនោះអោយច្បាស់នៅលើផែនទីដូចក្នុងសេចក្តីណែនាំបានរៀបរាប់ពីខាងលើ។ អ្នកសំភាសន៍ត្រូវចុះលេខរៀងអគារ លេខរៀងលំនៅដ្ឋាន លេខរៀងគ្រួសារ និងពត៌មានផ្សេងទៀតដែលត្រូវការនៅក្នុង TCLT ទំរង់ 1 ។

សេចក្តីណែនាំលំអិតអំពីរបៀបបំពេញទំរង់ 1 មានដូចខាងក្រោម :

## I.ពត៌មានសំគាល់

ផ្នែកនេះ មាននៅលើក្របមុខរបស់តារាងចុះបញ្ជីគ្រួសារបានប្រើប្រាស់សំរាប់ភូមិ/ផ្នែកមួយ(PSU) ។ វាជាការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យដើម្បីបញ្ជាក់អោយបានច្បាស់លាស់ថា ផ្នែកពត៌មានសំគាល់នៅលើក្របកំរងសំណួរបានបំពេញត្រឹមត្រូវ មុននឹងប្រគល់ទំរង់នេះអោយអ្នកសំភាសន៍ ។ ការពន្យល់សង្ខេបនៃកំណត់ត្រា ពត៌មានផ្សេងៗដូចខាងក្រោម :

(1) **ខេត្ត /ក្រុង :** សរសេរឈ្មោះខេត្ត / ក្រុងរបស់ភូមិតំណាង (PSU ) នៅទីចំហដែលមានស្រាប់ខាងក្រោយ ពាក្យ "ខេត្ត /ក្រុង" ។ សូមចុះលេខកូដ ខេត្ត /ក្រុង 2 ខ្ទង់ក្នុងប្រអប់លេខកូដដែលបាន ផ្តល់ឱ្យ ។

(2 ) **ស្រុក /ខ័ណ្ឌ :** សរសេរឈ្មោះស្រុក /ខ័ណ្ឌរបស់ភូមិតំណាង (PSU) នៅទីចំហដែលមានស្រាប់ហើយចុះលេខកូដ ស្រុក /ខ័ណ្ឌ 2 ខ្ទង់ក្នុងប្រអប់ដែលបានផ្តល់ឱ្យ ។

(3 ) **ឃុំ /សង្កាត់ :** សរសេរឈ្មោះឃុំ/សង្កាត់របស់ភូមិតំណាង (PSU) នៅបន្ទាត់ចំហដែលមានស្រាប់ហើយចុះលេខកូដឃុំ /សង្កាត់ 2 ខ្ទង់ ក្នុងប្រអប់ដែលបានផ្តល់ឱ្យ ។

( 4 ) **ភូមិ /មណ្ឌលតំណាង :** សរសេរឈ្មោះភូមិ / មណ្ឌលរបស់ភូមិតំណាង (PSU)នៅទីចំហ ដែលមានស្រាប់ហើយចុះលេខកូដភូមិ /មណ្ឌល 2 ខ្ទង់ក្នុងប្រអប់ដែលបានផ្តល់អោយ ។

(5 ) **តំបន់ :** សូមចុះលេខកូដតំបន់ក្នុងប្រអប់ដែលបានផ្តល់អោយ ។

(6) **ទីប្រជុំជន / ជនបទ :** សូមចុះលេខកូដ 1 សំរាប់ទីប្រជុំជន ហើយលេខកូដ 2 សំរាប់ជនបទនៅក្នុងប្រអប់ដែលបានផ្តល់អោយ ដោយប្រើតាមពតិមានចំណាត់ថ្នាក់ដែលបានផ្តល់អោយអ្នក ។

( 7 ) **លេខភូមិដែលបានជ្រើសរើស :** សូមចុះលេខរៀងភូមិក្នុងប្រអប់ដែលបានផ្តល់អោយ ។

(8 ) **ចំនួនគ្រួសារសរុបរាយការណ៍ដោយប្រធានភូមិ :** សូមចុះចំនួនគ្រួសារសរុបដែលបានរាយការណ៍ដោយ មេភូមិក្នុងប្រអប់ដែលបានផ្តល់អោយ ។

**II. ពតិមានសំភាសន៍**

1. **កាលបរិច្ឆេទនៃការចុះបញ្ជី :** សូមសរសេរលេខ ថ្ងៃ ខែ ឆ្នាំ តាមរយៈពេលប្រតិបត្តិការនៅពេលចុះបញ្ជីក្នុងភូមិ/ផ្នែកនៅក្នុងប្រអប់នីមួយៗ ។ ពីរប្រអប់ចំហដំបូង សូមសរសេរលេខថ្ងៃទីដែលបានចាប់ផ្តើមប្រតិបត្តិការចុះបញ្ជីពីរប្រអប់ចំហបន្ទាប់សូមសរសេរលេខខែ និងពីរប្រអប់ចំហចុងក្រោយ សូមសរសេរលេខឆ្នាំ ។ សូមសរសេរលេខ ថ្ងៃ ខែ ឆ្នាំ ដែលបានបញ្ចប់ប្រតិបត្តិការចុះបញ្ជីក្នុងភូមិ/ផ្នែកនៅក្នុងប្រអប់នីមួយៗ ។ឧទាហរណ៍ : បើចាប់ផ្តើមប្រតិបត្តិការចុះបញ្ជីនៅថ្ងៃទី 01 ខែ មិថុនា 2003 ហើយបានបញ្ចប់នៅថ្ងៃទី 0២ ខែ មិថុនា ២00៣ សូមសរសេរដូចខាងក្រោមនេះ :

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ថ្ងៃ | 0 | 1 | ខែ | 0 | 6 | ឆ្នាំ | 0 | 3 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ថ្ងៃ | 0 | 2 | ខែ | 0 | 6 | ឆ្នាំ | 0 | 3 |

2- **ឈ្មោះនិងហត្ថលេខាអ្នកសំភាសន៍ ៈ** កាលណាប្រតិបត្តិការចុះបញ្ជីក្នុងភូមិ / PSU ត្រូវបានបញ្ចប់សូមសរសេរឈ្មោះអ្នកសំភាសន៍នៅលើប្រអប់ចំហដែលមានដាក់ " ឈ្មោះ " និងចុះហត្ថលេខាលើប្រអប់ចំហដែលមានដាក់ " ហត្ថលេខា" នៅខាងក្រោមឈ្មោះរបស់អ្នក ។ សូមចុះកាលបរិច្ឆេទនៃហត្ថលេខា ។

3- **កាលបរិច្ឆេទនៃការត្រួតពិនិត្យ** ៈ សូមសរសេរលេខ ថ្ងៃ ខែ ឆ្នាំ តាមរយៈពេលត្រួតពិនិត្យដូចខាងលើនៅពេលដែលតារាងចុះបញ្ជីសំរាប់ភូមិ /តំបន់អង្កេតត្រូវបានពិនិត្យឡើងវិញដោយអ្នកត្រួតពិនិត្យ ។

4-**ឈ្មោះនិងហត្ថលេខាអ្នកត្រួតពិនិត្យ** ៈ អ្នកត្រួតពិនិត្យ ត្រូវត្រួតពិនិត្យអោយបានសព្វគ្រប់ដល់បញ្ជីគ្រួសារដែលបានប្រគល់អោយអ្នកដោយអ្នកសំភាសន៍ ។ អ្នកត្រួតពិនិត្យមើល 10 អគារដំបូងនៅក្នុងបញ្ជីដើម្បីឱ្យដឹងថាការចុះបញ្ជីធ្វើតាមបែបបទត្រឹមត្រូវ ហើយប្រាកដថាគ្មានគ្រួសារណាមួយត្រូវបានរំលងចោលឡើយ ។ បន្ទាប់ពីអ្នកត្រួតពិនិត្យពិនិត្យឡើងវិញដល់តារាងចុះបញ្ជីសំរាប់ភូមិ/តំបន់អង្កេតបានត្រឹមត្រូវ រួចមកសូមសរសេរឈ្មោះរបស់អ្នកនៅលើប្រអប់ចំហដែលមានដាក់ "ឈ្មោះ" និងចុះហត្ថលេខាលើប្រអប់ចំហដែលមានដាក់ "ហត្ថលេខា"នៅខាងក្រោមឈ្មោះរបស់អ្នក ។ សូមចុះកាលបរិច្ឆេទនៃហត្ថលេខា ។

5-**កំណត់សំគាល់** ៈសូមកត់ត្រានូវស្ថានភាពណាមួយដែលមិនធម្មតាក្នុងពេលចុះបញ្ជីហើយដែលស្ថានភាពនោះទាក់ទងជាមួយអ្នកសំភាសន៍ ។ កំណត់សំគាល់ទាំងនេះមានសារៈសំខាន់ណាស់សំរាប់វាយតំលៃនូវលទ្ធផលនៃការប្រតិបត្តិ ។

**III.ពត៌មានកែច្នៃទិន្នន័យ** មិនត្រូវបំពេញឡើយ ។

**IV.ពត៌មានអំពីក្រុមគ្រួសារ**

ផ្នែកនេះត្រូវបំពេញដោយអ្នកសំភាសន៍ ឬអ្នកទទួលខុសត្រូវដល់ការចុះបញ្ជីក្រុមគ្រួសារក្នុងភូមិ / ផ្នែកតំណាង ។ តារាងនីមួយៗមានចំនួន 15 បន្ទាត់សំរាប់ 15 គ្រួសារជាអតិបរមា ។ តារាងនេះក៏មានបន្ទាត់ទី 16 សំរាប់សរុបរបាយការណ៍នៃបង្គោល 7. 8 និង 9 ។

អ្នកនឹងត្រូវបានផ្តល់ឱ្យនូវចំនួនតារាងគ្រប់គ្រាន់សំរាប់ចុះបញ្ជីក្រុមគ្រួសារទាំងអស់ក្នុងភូមិ / តំបន់អង្កេតតំណាង។ ទំរង់មានលើសមានទុកនៅអ្នកត្រួតពិនិត្យ/សំរាប់អ្នកសំភាសន៍ប្រើប្រាស់ក្នុងករណីដែលត្រូវការ ។ គ្រប់ទំរង់ទាំងអស់សំរាប់ចុះបញ្ជីគ្រួសារក្នុងភូមិ / តំបន់អង្កេតដំណាងត្រូវប្រគល់ទៅអោយអ្នកត្រួតពិនិត្យ/ការិយាល័យកណ្តាលវិញបន្ទាប់ពីដំណើរការចុះបញ្ជីរួចហើយនូវផែនទីទាំងអស់ និងបញ្ជីសំណួរ ដែលបំពេញហើយ ។

**ទំព័រទី.....នៃ.....ទំព័រ** ៈ អ្នកត្រូវចុះលេខលើតារាងចុះបញ្ជីតរៀងគ្នាតាមលំដាប់លំដោយ ។ បើអ្នកបានប្រើប្រាស់ អស់ 10 ទំព័រសំរាប់ភូមិ /តំបន់អង្កេតមួយ ឧទាហរណ៏ អ្នកត្រូវតែសរសេរនៅលើទំព័រទីមួយ "ទំព័រទីមួយនៃ 10 ទំព័រ" ហើយនៅទំព័រទីពីរ" ទំព័រ2 នៃ 10 ទំព័រ" ហើយធ្វើដូចគ្នារហូតដល់ទំព័រចុងក្រោយ ។

សូមកត់សំគាល់ថា នៅបន្ទាត់ចំហទី 2 បានបង្ហាញចំនួនសរុបនៃទំព័រទាំងអស់ដែលបានប្រើប្រាស់ក្នុងការចុះបញ្ជីក្រុមគ្រួសារទាំងអស់ក្នុងភូមិ/តំបន់អង្កេតមួយ។ ផ្នែកនេះត្រូវបំពេញតែនៅពេលដែលការចុះបញ្ជីត្រូវបានបញ្ចប់។ សូមចាំអោយបានច្បាស់ថាគ្រប់ទំព័រទាំងអស់ត្រូវបានចុះលេខហើយចំនួនលេខដូចៗគ្នានៅបន្ទាត់ចំហទី2 ។

សូមចងចាំផងដែរថានៅទំព័រចុងក្រោយបង្អស់ គឺមានចំនួនលេខដូចគ្នាក្នុងបន្ទាត់ចំហទាំងពីរ ។ សូមពិនិត្យ ហើយរាប់ចំនួនទំព័រដែលបានប្រើប្រាស់អោយបានច្បាស់លាស់ ដោយមិនអោយសន្លឹកណាមួយគ្មានចុះលេខឡើយ ។ សូម ត្រួតពិនិត្យចំនួនទំព័រដែលបានប្រើប្រាស់ដើម្បីចៀសវាងការបាត់បង់ ។

នៅលើទំព័រនីមួយៗ សូមសរសេរលេខកូដ ខេត្ត ស្រុក ។ល។ នៅក្នុងប្រអប់ដែលបានផ្តល់ឱ្យនៅផ្នែកខាងលើ នៅក្នុងប្រអប់2 ចុងក្រោយសូមសរសេរចំនួនតំបន់អង្កេត និងលេខតំបន់អង្កេតមួយដែលបានផ្តល់ជូនដោយការិយាល័យ កណ្តាលនៃវិទ្យាស្ថានជាតិស្ថិតិ ។ ឧទាហរណ៍ ភូមិមួយបានបែងចែកជា 5 តំបន់អង្កេតហើយ តំបន់អង្កេតលេខ 3 ត្រូវបាន ជ្រើសរើស សូមសរសេរលេខ 5 នៅក្នុងប្រអប់ទីមួយ និងលេខ 3 នៅក្នុងប្រអប់ទី 2 ( នៃប្រអប់ 2 ចុងក្រោយ ) ។ ចំពោះភូមិដែលគ្មានបែងចែក សូមសរសេរលេខ 1 ក្នុងប្រអប់ទាំងពីរ ។

**បង្គោល ១ លេខបន្ទាត់ :** លេខបន្ទាត់ត្រូវសរសេរពីរខ្ទង់ហើយតាមលំដាប់រៀងគ្នាបន្ទាត់ ឬជួរផ្តេកនីមួយៗដែល បានប្រើប្រាស់ក្នុងផ្នែកពតិមានក្រុមគ្រួសារ ។

**បង្គោល ២ លេខរៀងអគារ** :លេខរៀងអគារត្រូវសរសេរលេខសំគាល់បីខ្ទង់ហើយតាមលំដាប់រៀងគ្នាសំរាប់ចុះបញ្ជី អគារនៅក្នុងភូមិ/តំបន់អង្កេត ។ ការចុះបញ្ជីអគារនីមួយៗក្នុងភូមិ/តំបន់អង្កេតត្រូវកំណត់លេខរៀង "001 "អគារ ទីពីរត្រូវកំណត់លេខរៀង "002 "ហើយធ្វើដូចៗគ្នារហូតដល់ការចុះបញ្ជីបានគ្រប់អគារទាំងអស់ក្នុងភូមិ/ផ្នែក ។ លេខ រៀងដែលត្រូវបានកំណត់សំរាប់ការចុះបញ្ជីអគារក្រោយគេបង្អស់ស្មើ នឹងចំនួនសរុបអគារដែលមាននៅក្នុង ភូមិ/តំបន់ អង្កេត ។ បើមានច្រើនជាងមួយគ្រួសាររស់នៅក្នុងអគារតែមួយនោះលេខរៀងអគាររបស់ក្រុមគ្រួសារ ទាំងនេះដូចគ្នា តែមួយ ដោយអ្នកមិនចាំបាច់សរសេរលេខរៀងអគារទៀតទេគ្រាន់តែប្រើសញ្ញា "– "សំរាប់ក្រុមគ្រួសារទីពីរ...ទីបី.... ក្នុងអគារដដែល នេះ ។

**បង្គោល ៣:លេខរៀងលំនៅដ្ឋាន៖** សំរាប់គោលបំណងនៃការអង្កេតនេះលំនៅដ្ឋានត្រូវបានកំណត់ដូចខាងក្រោម :

លំនៅដ្ឋានមួយ គឺជារចនាសម្ព័ន្ធមួយដែលនៅដាច់ដោយឡែកហើយនៅលើទីកន្លែងឯករាជ្យមួយនៃទីកន្លែង រស់នៅ ។ វាត្រូវបានកសាងឡើង ឬ រៀបចំអោយនៅជាទីកន្លែងដែលសំរាប់មនុស្សរស់នៅដូចជាអគារ ពាណិជ្ជកម្ម ឧស្សាហកម្ម និងកសិកម្ម ឬជាជំរកធម្មជាតិ និងជាជំរកមនុស្សធ្វើ ដូចជារូងភ្នំ ទូក ទូររថភ្លើងឬឡានដែល គេបោះបង់ចោល រូងក្រោមដី និងរចនាសម្ព័ន្ធប្រហាក់ប្រហែលដទៃទៀតដែលប្រើប្រាស់សំរាប់ជាកន្លែងរស់នៅ ។

លេខរៀងលំនៅដ្ឋាន ជាលេខសំគាល់បីខ្ទង់តាមលំដាប់រៀងគ្នា ដែលសំរាប់កំណត់ឱ្យលំនៅដ្ឋាននីមួយៗ ក្នុងភូមិ/តំបន់ អង្កេត ។ ដូច្នេះលេខរៀងលំនៅដ្ឋានដែលបានកំណត់ឱ្យលំនៅដ្ឋានក្រោយគេបង្អស់ក្នុង PSU នឹង ត្រូវស្មើនឹងចំនួន សរុបលំនៅដ្ឋាន PSU ។

បើមានលំនៅដ្ឋានច្រើនក្នុងអគារមួយ ត្រូវចុះបញ្ជីលំនៅដ្ឋាននីមួយៗដោយឡែកពីគ្នាដោយចាប់ផ្តើមពីជាន់ ក្រោមហើយចុះលំនៅដ្ឋានដទៃទៀតដែលមាននៅជាន់ដូចគ្នាមុននឹងឡើងទៅជាន់ខ្ពស់បន្ទាប់ទៀត ។ត្រូវកំណត់ឱ្យបានច្បា

សំលាស់ថាគ្រប់លំនៅដ្ឋានទាំងអស់ត្រូវបានចុះបញ្ជីទោះបីជាមានឬគ្មានមនុស្សរស់នៅក៏ដោយ ។ ត្រូវកំណត់លេខរៀងលំនៅដ្ឋានខុសៗគ្នាសំរាប់លំនៅដ្ឋានផ្សេងៗគ្នាក្នុងអគារ ។ ត្រូវចងចាំថាគ្រប់លំនៅដ្ឋានទាំងអស់ក្នុងអគារមួយត្រូវបានចុះបញ្ជីរួចហើយមុននឹងបន្តទៅអគារមួយទៀត ។

ក្រុមគ្រួសារដែលរស់នៅ ក្នុងអគារពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម ក៏ត្រូវកំណត់ជាលំនៅដ្ឋានដែរព្រោះគេបានរស់នៅមួយផ្នែកក្នុងអគារនោះ ។ ប៉ុន្តែបើអគារគ្មានក្រុមគ្រួសារណាមួយរស់នៅសូមសរសេរ " 999 "ក្នុងបង្គោលនេះដើម្បីបង្ហាញថាអគារនេះពិតជាប្រើប្រាស់សំរាប់ពាណិជ្ជកម្ម ឧស្សាហកម្ម ការិយាល័យ ហើយគ្មានលំនៅដ្ឋានក្នុងទីនោះទេ ។ សូមកត់សំគាល់ថា ក្នុងស្ថានភាពខុសប្លែកពីធម្មតា លំនៅដ្ឋាន អាចជា ទូក ឬរូងភ្នំ ឬបន្ទប់ថភ្លើងដែលបោះបង់ចោល ។

**បង្គោល ៤ : លេខរៀងគ្រួសារ**

- លេខរៀងគ្រួសារជាលេខសំគាល់បីខ្ទង់តាមលំដាប់រៀងគ្នាដែលសំរាប់កំណត់ឱ្យ គ្រួសារនីមួយៗក្នុង PSU (សូមមើលនិយមន័យនៃក្រុមគ្រួសារដែលមានក្នុងជំពូក 5 )។ ការចុះបញ្ជីក្រុម គ្រួសារទី 1 ត្រូវកំណត់លេខរៀងគ្រួសារ" 001 " ក្រុមគ្រួសារទី 2 ត្រូវកំណត់លេខរៀង " 002 " ហើយធ្វើដូចគ្នារហូតដល់ការចុះបញ្ជីបានគ្រប់គ្រួសារទាំងអស់ក្នុងភូមិ / តំបន់អង្កេត ។ លេខរៀងក្រុមគ្រួសារដែលបានចុះបញ្ជីសំរាប់ក្រុមគ្រួសារក្រោយគេបង្អស់ស្មើនឹងចំនួនសរុបគ្រួសារដែលមាននៅក្នុងភូមិគំរូ/តំបន់អង្កេត ។

មុននឹងចុះបញ្ជីក្រុមគ្រួសារណាមួយ មុនដំបូងអ្នកសំភាសន៍ត្រូវអោយដឹងប្រាកដនូវចំនួនក្រុមគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋានសិន ។ អ្នកត្រូវសួរទៅមនុស្សណាម្នាក់ថា" តើមានប៉ុន្មានក្រុមគ្រួសាររស់នៅក្នុងលំនៅដ្ឋាន នេះ ?"។ បន្ទាប់មកអ្នកត្រូវសួរទៀតថា "តើមានអ្នកហូបបាយរួមគ្នាទេ ? "។ ក្នុងករណីដែលមានក្រុមគ្រួសារច្រើនរស់នៅក្នុងលំនៅដ្ឋានតែមួយសូមចុះបញ្ជីក្រុមគ្រួសារចំបង ឬក្រុមគ្រួសារដែលទទួលខុសត្រូវសំខាន់ដល់លំនៅដ្ឋាន ដូចជាម្ចាស់លំនៅដ្ឋានអ្នកជួលឱ្យឬអ្នកជួលសំខាន់ជាមុនសិន ។ ក្រុមគ្រួសារដទៃទៀតត្រូវចុះបញ្ជីដោយឡែក ហើយកំណត់លេខរៀងក្រុមគ្រួសារផ្សេងៗពីគ្នា ។ ត្រូវចងចាំថាគ្រប់ក្រុមគ្រួសារទាំងអស់ដែលរស់នៅ ក្នុងលំនៅដ្ឋានតែមួយត្រូវចុះបញ្ជីឱ្យអស់មុននឹងបន្តទៅចុះបញ្ជីក្រុមគ្រួសារនៅលំនៅដ្ឋានមួយទៀត ។

បើគ្មានមនុស្សរស់នៅ /ក្រុមគ្រួសាររស់នៅក្នុងលំនៅដ្ឋានទេ សូមសរសេរ " 999 "ក្នុងបង្គោល 3 ។ ដូចគ្នាដែរត្រូវសរសេរ" 999" ក្នុងបង្គោល 4 បើចំលើយក្នុងបង្គោល 3 មាន" 999"(គឺគ្មានលំនៅដ្ឋាន ក្នុងអគារ)។

ក្នុងពេលប្រតិបត្តិការចុះបញ្ជីគ្រួសារ អ្នកត្រូវសួរគ្រប់គ្រួសារដែលត្រូវចុះបញ្ជីថា តើគ្រួសាររបស់អ្នកនឹងត្រូវផ្លាស់ទីលំនៅ រឺអវត្តមាន ក្នុងរយៈពេលនៃការធ្វើអង្កេតដែរនេះទេ ? ។ បើមានគ្រួសារណាមួយនឹងត្រូវផ្លាស់ទីលំនៅ រឺអវត្តមាន ក្នុងរយៈពេលនៃការធ្វើអង្កេតនេះ ត្រូវសរសេរ " ៧៧៧ " ក្នុងបង្គោល 4 ជំនួសវិញដើម្បី

បង្ហាញថាគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋាននោះនឹងត្រូវផ្លាស់ទីលំនៅ រឺ អវត្តមាន ក្នុងពេលណាមួយនៃការធ្វើ អង្កេត ប៉ុន្តែត្រូវសរសេរលេខរៀងអោយលំនៅដ្ឋាន ។

មនុស្សរស់នៅក្នុងសណ្ឋាគារ សយនដ្ឋាន ឬទីកន្លែងប្រហាក់ប្រហែល ដូចជាកន្លែងរស់នៅស្ថាប័នមិនគិតជាក្រុមគ្រួសារឡើយ ។ ដូចច្នេះលំនៅដ្ឋាននេះគ្មានកំណត់លេខរៀងក្រុមគ្រួសារឡើយ ។ ត្រូវសរសេរ " 888 " ក្នុងបង្គោល 4 ជំនួសវិញដើម្បីបង្ហាញថាលំនៅដ្ឋានជាកន្លែងរស់នៅស្ថាប័ន ប៉ុន្តែត្រូវសរសេរលេខរៀងអោយ លំនៅដ្ឋាននោះជាយ៉ាងណាក្តីវាអាចមានក្រុមគ្រួសាររស់នៅក្នុងបរិវេណទីកន្លែងរស់នៅស្ថាប័នដែរ ។

**បង្គោល ៥ : ឈ្មោះមេគ្រួសារ**

មេគ្រួសារគឺសំដៅចំពោះសមាជិកក្រុមគ្រួសារ ដែលត្រូវបានទទួលស្គាល់នឹងយល់ព្រមដោយសមាជិកក្រុមគ្រួសារដទៃទៀតថាជាមេគ្រួសារ ។ ក្រុមគ្រួសារជាច្រើនតែងយល់ព្រម និងទទួលស្គាល់ ថា ឪពុកជាមេគ្រួសារ ។ ប៉ុន្តែប្រការនេះមិនគួឱ្យពិបាកពេកទេ ហើយក៏មិនត្រូវសន្មត់ ឬប៉ាន់ស្មានឡើយ ។ ដូច្នេះ សំខាន់គឺគ្រាន់តែសួរអ្នកឆ្លើយថា តើអ្នកណាជាមេគ្រួសារ ។

សូមដាក់ឈ្មោះមេគ្រួសារ ដោយសរសេរឈ្មោះនាមត្រកូល ហើយបន្ទាប់មក នាមខ្លួន ។

**បង្គោល ៦ : អាស័យដ្ឋានក្រុមគ្រួសារ**

សូមសរសេរលេខអគារដែលបានកំណត់ដោយរដ្ឋាភិបាល (មិនមែនលេខរៀងអគារដែលកំណត់ដោយអ្នកសំភាសន៍នៅក្នុងបង្គោល 2 ឡើយ ) ឈ្មោះ និងលេខផ្លូវ ។ ក្នុងករណីជាច្រើន វាត្រូវដូចគ្នាទៅនឹងអាស័យដ្ឋានប្រៃសណីយ៍ប័ត្រ ។ នៅជនបទជាកន្លែងគ្មានលេខផ្លូវ ឬលេខផ្ទះសូមកត់ចូល នូវអាស័យដ្ឋាន ប្រៃសណីយ៍ប័ត្រ ឬពត៌មានណាមួយដែលបញ្ជាក់សំគាល់ដល់អគារ ឬទីកន្លែង ។

**បង្គោល ៧-៩ :ចំនួនសមាជិកគ្រួសារ**

ដោយយោងតាមនិយមន័យនៃក្រុមគ្រួសារនៅជំពូក 5 នៃអត្ថបទណែនាំនេះ សូមសរសេរក្នុងបង្គោល 7 នូវចំនួនសរុបនៃមនុស្សដែលរស់នៅជាប្រចាំក្នុងក្រុមគ្រួសារ ។

ចំនួននេះត្រូវស្មើនឹងចំនួនសរុបដែលមាននៅក្នុងបង្គោល 8 និង បង្គោល 9 ។ បើមិនស៊ីគ្នាត្រូវរក កំហុសរបស់វាហើយចាំបាច់ត្រូវធ្វើការកែសំរួលឱ្យបានត្រឹមត្រូវឡើងវិញ ។

**បង្គោល ៨ : សមាជិកគ្រួសារជាបុរស**

សូមសរសេរចំនួនសរុបនៃសមាជិកគ្រួសារ ដែលជាបុរស ។

**បង្គោល ៩ : សមាជិកគ្រួសារជាស្រ្តី**

សូមសរសេរចំនួនសរុបនៃសមាជិកគ្រួសារ ដែលជាស្រ្តី ។

សរុបទំព័រនៃបង្គោល 7-9 នឹងត្រូវធ្វើនៅការិយាល័យ ។

**បង្គោល១០១១**:សកម្មភាពសេដ្ឋកិច្ចជាមូលដ្ឋានរបស់អគារ/ក្រុមគ្រួសារសកម្មភាពសេដ្ឋកិច្ចជាមូលដ្ឋានសំដៅទៅលើការអនុវត្តន៍នូវសកម្មភាពដែលសំខាន់បំផុតក្នុងអគារឬក្នុងបរិវេណរស់នៅសំរាប់ការផលិតសេដ្ឋកិច្ចទំនិញ ឬសេវាកម្ម។ សកម្មភាពសេដ្ឋកិច្ចទាំងនេះ អាចអនុវត្តន៍ដោយក្រុមគ្រួសារក្នុងអាគារមួយដែលមិនមែនជាទីកន្លែងរស់នៅ រឺក្នុងលំនៅដ្ឋានមួយ និងលើដី ។ បើមានសកម្មភាពសេដ្ឋកិច្ចច្រើនជាមួយក្នុងអគារ ឬទីកន្លែងតែមួយ សូមជ្រើសរើសសកម្មភាពណាដែលផ្តល់ចំណូលខ្ពស់ជាងគេបង្អស់ ។

ចំពោះអគារដែលគ្មានក្រុមគ្រួសារណាមួយរស់នៅ សូមកត់ត្រានូវសកម្មភាពសេដ្ឋកិច្ចសំខាន់បំផុតដែលបានអនុវត្តន៍ក្នុងអគារ /ទីកន្លែងនោះ ។

ឧទាហរណ៍ : ចំលើយអាចជា ឱសថ ហាងអ៊ុតសក់ ហាងលក់ទំនិញគ្រប់មុខ កសិដ្ឋាន ដាំស្រូវ ដាំបន្លែ ហាងលក់ដូរសំលៀកបំពាក់ ។

**បង្គោល ១១ :លេខកូដ**-លេខកូដរបស់សកម្មភាពសេដ្ឋកិច្ចជាមូលដ្ឋាននឹងត្រូវដាក់បញ្ចូលនៅឯការិយាល័យនៅក្នុងជំហានកែច្នៃទិន្នន័យ ។

**បង្គោល ១២ : លេខយោងសំណាក**-បង្គោលនេះ ដូចគ្នាទៅនឹងបង្គោល 4 លេខរៀងក្រុមគ្រួសារ ប៉ុន្តែមិនត្រូវចុះលេខយោងសំណាកឡើយបើក្នុងបង្គោល 4 មានលេខ ៧៧៧ ឬ 888 ឬក៏ 999 ។ បង្គោលនេះត្រូវបំពេញដោយអ្នកត្រួតពិនិត្យបន្ទាប់ពីប្រតិបត្តិការចុះបញ្ជីក្នុងភូមិ / ផ្នែកត្រូវបានបញ្ចប់ ។

សេចក្តីណែនាំរបៀបប្រើប្រាស់ដើម្បីជ្រើសរើសលេខសំគាល់តំណាងមាននៅក្នុងផ្នែក 4 ខាងក្រោម ( របៀបជ្រើសរើសគ្រួសារតំណាង ) ។

**បង្គោល១៣ : កំណត់សំគាល់**-បង្គោលនេះត្រូវបញ្ជាក់ដោយលេខកូដសំរាប់មនុស្សនៅក្នុងគ្រួសារដែលមានមុខងារដូចបានផ្តល់ឱ្យខាងក្រោម ដោយសរសេរលេខកូដក្នុងបង្គោលនេះ ។

1. មេភូមិ
2. អ្នកធ្វើការផ្នែកសុខាភិបាល ឬឱសថការី
3. នាយកសាលា ឬគ្រូបង្រៀន
4. ម្ចាស់ហាងទំនិញឬអ្នកលក់នៅផ្សារ

សូមសរសេរលេខកូដអោយបានសមស្របក្នុងបង្គោលនេះចំពោះក្រុមគ្រួសារណាដែលមានសមាជិកគ្រួសារធ្វើការដូចខាងលើ ។

## 3 . របៀបជ្រើសរើសគ្រួសារតំណាង

### ការពិពណ៌នាទូទៅនៃទំរង់បែបបទជ្រើសរើស

វាជាការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យ ដើម្បីសំគាល់នូវគ្រួសារតំណាងដែលនឹងត្រូវឆ្លើយនូវសំណួរ ក្នុងទំរង់ 3 នៃការអង្កេត( TCLT 2005 )គ្រួសារកម្ពុជា (បញ្ជីសំណួរសំរាប់គ្រួសារ ) និង ទំរង់ទី 4 (បញ្ជីសំណួរអំពីចំណូលនិងការងារ ) ។

ចំនួន 11 គ្រួសារតំណាងនៅតំបន់ទីប្រជុំជន និង 15 គ្រួសារតំណាងនៅតំបន់ជនបទត្រូវបានជ្រើសរើសពីភូមនីមួយៗ ។ នៅពេលដែលការចុះបញ្ជីក្រុមគ្រួសារក្នុងភូមិ / តំបន់តំណាងត្រូវបានបញ្ចប់អ្នកត្រួតពិនិត្យត្រូវកំណត់តាមលំដាប់លំដោយដល់គ្រួសារនីមួយៗនៃទំរង់ទី 1 នូវលេខសំគាល់សំណាកគំរូដែលត្រូវចុះនៅក្នុង បង្គោល" លេខយោងសំណាក "（បង្គោល 12）។

លេខយោងសំណាកមានលេខ 3 ខ្ទង់ដែលចាប់ផ្តើមពី "001 "សំរាប់គ្រួសារទីមួយ ក្នុងបញ្ជី "002 " សំរាប់គ្រួសារបន្ទាប់និងធ្វើរបៀបដូចគ្នាជាបន្តបន្ទាប់រហូតដល់គ្រប់គ្រួសារទាំងអស់ដែលត្រូវបានកំណត់ចំនួន។ អ្នកត្រួតពិនិត្យត្រូវចងចាំថា លេខត្រូវបានកំណត់តាមលំដាប់រៀងគ្នាហើយគ្មានលេខណាមួយត្រូវភ្លេចឬខុសឡើយ ។ម្យ៉ាងទៀតក៏ត្រូវបញ្ជាក់ឱ្យច្បាស់ដែរថា គ្រួសារត្រូវបានកំណត់លេខសំគាល់គំរូតែមួយមានន័យថាគ្មានពីរគ្រួសារ ឬច្រើនគ្រួសារត្រូវបានកំណត់លេខយោងសំណាកដូចគ្នាឡើយ ។

នៅពេលដែលការកំណត់លេខយោងសំណាកត្រូវបានធ្វើរួចហើយអ្នកត្រួតពិនិត្យត្រូវត្រៀមជាស្រេចដើម្បីបន្តការជ្រើសរើសក្រុមគ្រួសារដំណាង ។ ការជ្រើសរើសនឹងត្រូវបានអនុវត្តន៍តាមវិធីប្រព័ន្ធជ្រើសរើសគំរូ ។ ជំហាន ខាងក្រោមនេះនឹងណែនាំអ្នកត្រួតពិនិត្យក្នុងការជ្រើសរើសសំណាកគំរូឱ្យបានល្អប្រសើរ :

1- កំណត់ចំនួនគ្រួសារសរុបក្នុងបញ្ជីគ្រួសារ（ក្នុងភូមិ / តំបន់ ）។ ចំនួននេះស្មើនឹងលេខយោងសំណាកខ្ពស់បំផុតក្នុងបង្គោល 12 ។

២- កំណត់ចន្លោះគំលាតគំរូ ដែលត្រូវប្រើប្រាស់ ។

សូមសរសេរ · ជាចំនួនគ្រសារដែលបានចុះបញ្ជីនៅក្នុងទំរង់ទី 1 ក្នុងភូមិ/តំបន់តំណាង ។ ចន្លោះ គំលាតគំរូ ត្រូវបានគណនាដូចខាងក្រោម :

I = M / 11 សំរាប់តំបន់ទីប្រជុំជន និង I = M / 15 សំរាប់តំបន់ជនបទ

សូមកត់សំគាល់ថា I ត្រូវបានគណនាដាច់ដោយឡែកពីគ្នាសំរាប់ភូមិ /តំបន់អង្កេតនីមួយៗ ។ អ្នកត្រូវប្រើប្រាស់ចំនួនគ្រួសារជាក់ស្តែងដែលមាននៅក្នុងបញ្ជី ហើយដែលមិនមែនជាចំនួនគ្រួសារដែលផ្តល់ឱ្យអ្នកមុនពេលអ្នកធ្វើការចុះបញ្ជីនោះទេ ។ តួចែកគឺ 11 ព្រោះ 11 គ្រួសារត្រូវបានជ្រើសរើសនៅតំបន់ ទីប្រជុំជន និងតួចែកគឺ 15 ព្រោះគ្រួសារត្រូវបានជ្រើសរើសនៅតំបន់ជនបទ ។

ឧទាហរណ៍ : ឧបមាថាភូមិមួយ / តំបន់អង្កេតមួយមាន ចំនួនគ្រួសារប៉ាន់ស្មាន ១២០ គ្រួសារប៉ុន្តែពេលដំណើរការ ចុះបញ្ជីជាក់ស្តែងឃើញថា មានចំនួនគ្រួសារពិតប្រាកដគឺ ១៣០ គ្រួសារ ។

ដូច្នេះ = 130

តំបន់ទីប្រជុំជន

I = M /10 = 130 / 11 =11.80

តំបន់ជនបទ

I = M / 15 = 130 / 15 = 8.6

3- ជ្រើសរើសលេខចៃដន្យចាប់ផ្តើមដំបូង

លេខចាប់ផ្តើមដោយចៃដន្យនេះ ត្រូវជ្រើសរើសពីគ្រប់លេខទាំងអស់ដែលមាននៅចន្លោះ ពី 1 ដល់ M ។ ក្នុងឧទាហរណ៍ទីមួយ បើ M= 130 អ្នកត្រួតពិនិត្យត្រូវយកតារាងលេខចៃដន្យ ក្នុងឧបសម្ព័ន្ធ ខ ជ្រើសរើស យកលេខ 3 ខ្ទង់ពីជួរដែលបានកំណត់ដូចខាងក្រោម ហើយរកលេខណា ដែលមាន 3 ខ្ទង់ដំបូង ដោយចៃដន្យដែរ ។

(របៀបជ្រើសរើស: បើលេខភូមិមាន ១២០២៤ ត្រូវយកតែលេខពីរខ្ទង់ខាងចុង គឺលេខ ២៤ ហើយប្រើប្រាស់បន្ទាត់ទី 24 ។ បើលេខភូមិមាន ០១០១៥ត្រូវយកតែលេខពីរខ្ទង់ខាងចុង គឺលេខ ១៥ ប្រើប្រាស់បន្ទាត់ទី ១៥ (បន្តទៅបន្ទាត់បន្ទាប់បើចាំបាច់) ។ ឧបមាថា អ្នកជ្រើសរើសយកលេខ 112 ដែលជាលេខ 3 ខ្ទង់ចៃដន្យដំបូងនៅចន្លោះ 1 និង 162 ។ ចំនួននេះហៅថា លេខចាប់ផ្តើមដោយចៃដន្យ ដែលកំណត់ដោយ ( ។

ដូច្នេះ R = 112

(បើ M មាន 2 ខ្ទង់ អ្នកសំភាសន៍ត្រូវមើលលេខ 2 ខ្ទង់ក្នុងតារាងលេខចៃដន្យ ។ ឧទាហរណ៍ បើ M = ៩៥ អ្នកសំភាសន៍ត្រូវមើលលេខពីរខ្ទង់ ហើយរកចំនួនលេខពីរខ្ទង់ចៃដន្យដំបូង ដែលចាប់ 01 ទៅដល់ 95 ។ លេខនោះគឺជាលេខចៃដន្យដំបូង ()) ។

4- ការជ្រើសរើសគ្រួសារតំណាងតាមប្រព័ន្ធរង្វង់ដោយប្រើតួលេខចាប់ផ្តើមចៃដន្យ ។

ឧទាហរណ៍ ខាងលើយើងត្រូវជ្រើសរើសយកគ្រួសារតំណាងតាមលេខយោងសំណាក ( SRN ) ដែលមានលេខចាប់ផ្តើមដោយ ចៃដន្យស្មើ នឹង 112 និងគ្រប់គំលាតចន្លោះ 11.8 រឺ 8.6 ដែលបានមកពី I = 16.20 ។ យើងចាប់ផ្តើមរើសយក 11 គ្រួសារនៅតំបន់ទីប្រជុំជន រឺ គ្រួសារ15 នៅតំបន់ជនបទ នេះជាការជ្រើសរើសគ្រួសារតំណាងដែលមានលេខយោង សំណាក ។

**<u>សំរាប់ទីប្រជុំជន</u>**

112, 112 + 11.8 = 123.8, 128.8 + 11.8 = 135.6-130=5.6, 5.6+11.8=17.4 ,17.4+11.8,29.2,29.2+11.8=41,41+11.8=52.8,52.8+11.8=64.6,64.6+11.8=76.4,76.4+11.8=88.2,88.2+11.8=100

សូមកត់សំគាល់ថា ត្រូវបូកបន្ថែម 16.20 ជាបន្តបន្ទាប់ យើងបានគ្រួសារទី 176.80 ហើយត្រូវយក 176.80 ដកនឹង 162 យើងបានគ្រួសារទី 14.80 ។ បន្ទាប់ពីរើសបានគ្រួសារគំរូទាំងអស់នោះរួចរាល់

ហើយយើងត្រូវសំរួលយកលេខគត់ ដូច្នេះយើងបាន:

គ្រួសារទី 1: 112 → 112

គ្រួសារទី 2: 123.8 → 123

គ្រួសារទី 3: 5.6 → 005

គ្រួសារទី 4: 17.4 → 017

គ្រួសារទី 5: 29.2 → 029

គ្រួសារទី 6: 41 → 041

គ្រួសារទី 7: 52.8 → 052

គ្រួសារទី 8: 64.6 → 064

គ្រួសារទី 9: 76.4 → 076

គ្រួសារទី 10: 88.2 → 088

គ្រួសារទី 11: 100 → 100

ត្រូវប្រើបញ្ជីគ្រួសារដើម្បីជ្រើសយកតាមរបៀបរង្វង់ យើងបានគ្រួសារទី 112 ជាគ្រួសារដំណាក់ទី 1 គ្រួសារទី 123 ជាគ្រួសារដំណាងទី 2 ។ ល ។ ដូច្នេះគ្រួសារតំណាងដែលធ្វើតាមលេខចាប់ផ្តើមដោយចៃដន្យ មានលេខយោងសំណាក :

112,123,005,017,029,041,052,064,076,088/ និង 100

5- គូសរង្វង់លើលេខយោងសំណាក 1 ( SRN ) របស់គ្រប់គ្រួសារទាំងអស់ដែលបានជ្រើសរើស ក្នុង បង្គោល 12 នៃ TCLT តារាង 1 ។

វិធីសាស្រ្តនឹងបញ្ជាក់អោយកាន់តែច្បាស់តាមឧទាហរណ៍ដូចខាងក្រោម :

4.ឧទាហរណ៍បន្ថែមអំពីការជ្រើសរើសសំណាក ( គ្រួសារគំរូ រឺគ្រួសារតំណាង)

ឧទាហរណ៍ : ឧបមាថានៅក្នុងភូមិមួយនៅក្នុង **តំបន់ជនបទ** មានមួយតំបន់អង្កេត រឺច្រើនតំបន់អង្កេត ។ ដូច្នេះយើងជ្រើសរើសយកតែតំបន់អង្កេតណាមួយដែលបានផ្តល់ជូនដោយការិយាល័យកណ្តាល(វិទ្យាស្ថានជាតិស្ថិតិ) ឧបមាថា ក្រោយពេលចុះបញ្ជីគ្រួសារក្នុងភូមិ រឺ តំបន់អង្កេតណាមួយនៃតារាង ១ ហើយមានគ្រួសារជាក់ស្តែង ទាំងអស់ ១៣០ គ្រួសារ ។

ដូច្នេះ M = 130

ចន្លោះគំលាតសំណាកគំរូ មាន :

- I = M / 15 = 130 / 15 = 8.6

យើងត្រូវជ្រើសរើសយកលេខចាប់ផ្តើមដំបូងដោយចៃដន្យ **R** ដែលនៅចន្លោះពី 1 និង 130 ។ ឧបមាថាលេខភូមិគឺលេខ 01005 ។ ដូច្នេះយើងត្រូវយកតែលេខពីរខ្ទង់ខាងចុង គឺលេខ ០៥ ត្រូវប្រើបន្ទាត់ ទី ៥

ក្នុងតារាងលេខចៃដន្យ ដើម្បីរកលេខចៃដន្យ ។ យើងមើលលេខបីខ្ទង់ ពីបន្ទាត់ទី ៥ ។ យើងនឹងឃើញ លេខ 3 ខ្ទង់នៅក្នុងបន្ទាត់នោះ ដូចខាងក្រោម :

629, 109, 241, 298, 738, 658, 562, 167, 829, 993,…….

( យើងត្រូវមើលដោយចាប់ផ្តើមពីឆ្វេងដូចដែលយើងមើលសៀវភៅដែរ ) ។ លេខ 3 ខ្ទង់ដំបូង នៅចន្លោះ 1 ដល់ 130 គឺ 109 ។ ដូច្នេះលេខចាប់ផ្តើមដោយចៃដន្យគឺ :

**R** = ១០៩ ( គ្រួសារគំរូចៃដន្យដំបូង)

ដូច្នេះដើម្បីរកគ្រួសារទីពីរយើងត្រូវយក 109( គ្រួសារទី1) បូកនឹង 9.90 (ចន្លោះឃ្លាត) និងបូកបន្តបន្ទាប់រហូតដល់បាន 20 គ្រួសារ ។

ដូច្នេះយើងបាន :

គ្រួសារទី 1= R = 109 គ្រួសារទី 2 = 109+8.6 = 117.6

គ្រួសារទី 3 = 117.6+8.6 = 126.2 គ្រួសារទី 4 = 126.2+8.6 –130=4.8

គ្រួសារទី 5 = 4.8+8.6 = 13.4 គ្រួសារទី 6 = 13.4+8.6 = 22

គ្រួសារទី 7 = 22+8.6 = 30.6 គ្រួសារទី 8 = 30.6+8.6 = 39.2

គ្រួសារទី 9 = 39.2 + 8.6 = 47.8 គ្រួសារទី 10 = 47.8 + 8.6 = 56.4

គ្រួសារទី 11 = 56.4 + 8.6 = 65 គ្រួសារទី 12 = 65 + 8.6 = 73.6

គ្រួសារទី 13 = 73.6 + 8.6 = 82.2 គ្រួសារទី 14 = 82.2 + 8.6 = 90.8

គ្រួសារទី 15 = 90.8 + 8.6 = 99.4

**យើងបានៈ**

| | |
|---|---|
| គ្រួសារទី 1 = 109 → 109 | គ្រួសារទី 11 = 65 → 65 |
| គ្រួសារទី 2 = 117.6 → 117 | គ្រួសារទី 12 = 73.6 → 73 |
| គ្រួសារទី 3 = 126.20 → 126 | គ្រួសារទី 13 = 82.2 → 82 |
| គ្រួសារទី 4 = 4.8 → 4 | គ្រួសារទី 14 = 90.8 → 90 |
| គ្រួសារទី 5 = 13.4 → 13 | គ្រួសារទី 15 = 99.4 → 99 |
| គ្រួសារទី 6 = 22 → 22 | |
| គ្រួសារទី 7 = 30.6 → 30 | |
| គ្រួសារទី 8 = 39.2 → 39 | |

គ្រួសារទី 9 =  47.8 $\rightarrow$ 47

គ្រួសារទី 10 =  56.4 $\rightarrow$ 56

ដូច្នេះគ្រួសារតំណាង មានលេខយោងសំណាកគឺ :
109, 117,126,4,13,22,30,39,47,56,65,73,82,90  99

សូមកត់សំគាល់ថា នៅពេលដែលលេខយោងសំណាក ( SRN ) ច្រើនជាង 198 យើងត្រូវយកចំនួន ដែលលើស (198.10) ដកនឹង 198 ។

# ជំពូក 7

## កំរងសំណួរគ្រួសារ

## ( LCLT តារាងសំណួរទំរង់ 2 )

កំរងសំណួរនេះ រួមមាន ៩ ផ្នែក(ទំរង២)នឹងត្រូវសាកសួរចំពោះគ្រួសារនៅក្នុងកំឡុងពេលធ្វើសំភាសន៍ : ផ្នែកទាំងនោះរួមមានដូចខាងក្រោម :

I ទំព័រមុខ

II សំនួរប្រជាសាស្ត្រ:

III ការប្រើប្រាស់ថ្នាំជក់

IV ចំណេះដឹងនិងឥរិយាបទអំពីការប្រើប្រាស់ថ្នាំជក់

V ការជក់បារីមិនផ្ទាល់

VI ការឈប់ជក់បារី

VII របៀបរបបនៃការរស់នៅ

VIII ប្រផ្សព្វផ្សាយពិតមាន

IX សំនួរបន្ថែម

សំនួរគ្រួសារត្រូវបានសាកសួរចំពោះមេគ្រួសារ ឬប្តីប្រពន្ធរបស់មេគ្រួសារប្រសិនបើពួកគេទាំងនោះ អវត្តមាន (ឧ. អវត្តមាននៅពេលធ្វើអង្កេត) សំនួរត្រូវបានសាក សួរទៅលើមនុស្សពេញវ័យផ្សេងទៀតដែលជា សមាជិកគ្រួសារ និងជាអ្នកដឹងរឿងច្រើននៅក្នុងគ្រួសារផងដែរ ។

ផ្នែកទី II សំនួរប្រជាសាស្ត្រ:ត្រូវបានសាកសួរទៅលើមេគ្រួសារ ឬប្តីប្រពន្ធនៃមេគ្រួសារឬក៏សមាជិកម្នាក់ៗនៅក្នុងគ្រួសារដោយផ្ទាល់ ។

ផ្នែកទី III ការប្រើប្រាស់ថ្នាំជក់ត្រូវបានសាកសួរសមាជិកគ្រួសារនិមួយៗដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ផ្នែកទី IV ចំណេះដឹងនិងឥរិយាបទអំពីការប្រើប្រាស់ថ្នាំជក់ត្រូវបានសាកសួរចំពោះសមាជិកដែលមានអាយុ១៨ ឆ្នាំឡើងទៅ ដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ផ្នែកទី V ការជក់បារីមិនផ្ទាល់ ត្រូវបានសាកសួរសមាជិកគ្រួសារនិមួយៗដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ផ្នែកទី VI ការឈប់ជក់បារីត្រូវបានសាកសួរសមាជិកគ្រួសារនិមួយៗដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ផ្នែកទី VII របៀបរបបនៃការរស់នៅត្រូវបានសាកសួរសមាជិកគ្រួសារនិមួយៗដែលមានអាយុ ១៨ ឆ្នាំឡើងទៅ ដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ផ្នែកទី VIII ប្រផ្សព្វផ្សាយពិតមានត្រូវបានសាកសួរសមាជិកគ្រួសារនិមួយៗដែលមានអាយុ ១៨ ឆ្នាំឡើងទៅដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ផ្នែកទី IX សំនួរបន្ថែមត្រូវបានសាកសួរសមាជិកគ្រួសារនិមួយៗដែលមានអាយុ ១៨ ឆ្នាំឡើងទៅដែលមានវត្តមានក្នុងពេលធ្វើអង្កេតដោយផ្ទាល់ ។

ការបង្ហាញដោយលំអិតនៅក្នុងផ្នែកនិមួយៗ

ផ្នែកទី I ទំព័រមុខ

អ្នកសំភាសន៍ត្រូវបំពេញពិតមាននៅក្នុងផ្នែក **ក** នៅលើតារាងសំនួរទំព័រមុខមុនពេលធ្វើសំភាសន៍ ។ នៅក្នុងពិតមានដែលមាននៅក្នុងទំព័រមុខនឹងត្រូវបានអោយពីវិជ្ជាស្ថានជាតិស្ថិតិ ។

ខេត្ត,ក្រុង( ឈ្មោះនិងកូដ)

ស្រុក,ខណ្ឌ( ឈ្មោះនិងកូដ)

ឃុំ,សង្កាត់ ( ឈ្មោះនិងកូដ)

ភូមិគំរូ,មណ្ឌល( ឈ្មោះនិងកូដ)

លេខតំបន់

ផ្នែក( ទីប្រជុំជន = ១, ជនបទ = ២)

ចំនួនគំរូគ្រួសារ

មន្ត្រីសំភាសន៍នឹងត្រូវបំពេញគ្រប់សំនួរទាំងអស់នៅក្នុងផ្នែក **ខ** នៅផ្នែកទំព័រមុខនៃតារាងសំនួរក្នុងពេលធ្វើសំភាសន៍

ឈ្មោះមេគ្រួសារ

អាសយដ្ឋាននៃគ្រួសារគំរូ

ការបរិច្ឆេទចាប់ផ្តើមធ្វើសំភាសន៍

ការបរិច្ឆេទសំភាសន៍

ឈ្មោះមន្ត្រីសំភាសន៍

លេខកូដរបស់មន្ត្រីសំភាសន៍( ២ ឬ៣ខ្ទង់)

ហត្ថលេខាមន្ត្រីសំភាសន៍( បញ្ជាក់ថាគេបានបំពេញរួចរាល់នៅក្នុងការធ្វើអង្កេត)

លេខក្រុម ( ពីរខ្ទង់)

ត្រួតពិនិត្យអំពីការបំពេញតារាងសំនួរ មន្ត្រីត្រួតពិនិត្យនឹងបំពេញបន្ថែមនៅរាល់សំនួរទាំងអស់នៅក្នុង ផ្នែក **គ** នៃទំព័រមុខ ។

ឈ្មោះមន្ត្រីត្រួតពិនិត្យ

លេខកូដរបស់មន្ត្រីត្រួតពិនិត្យ(ពីរខ្ទង់)

ការបរិច្ឆេទពិនិត្យដោយមន្ត្រីត្រួតពិនិត្យ

ការបរិច្ឆេទនៃការសំភាសន៍ឡើងវិញ ( ប្រសិនបើចាំបាច់)

ហត្ថលេខាមន្ត្រីសំភាសន៍

ការសំភាសន៍ឡើងវិញនៅក្នុងករណីទាំងនោះនឹងត្រូវបំពេញនៅក្នុងផ្នែក **ឃ** នៃទំព័រមុខពេលដែលធ្វើសំភាសន៍ឡើងវិញបានរួចរាល់

អ្នកកែដៃនឹងអ្នកបញ្ចូលទិន្នន័យនឹងទទួល/ដំណើរការរៀបចំ/បញ្ចូលទិន្នន័យដោយមានការអនុញ្ញាត្តិពីមន្ត្រីថ្នាក់លើ ។

## ផ្នែកទី II សំនួរប្រជាសាស្ត្រ

អ្នកឆ្លើយៈ មន្ត្រីសំភាសន៍ត្រូវទាក់ទងមេគ្រួសារដើម្បីបំពេញនៅក្នុងផ្នែកនេះ (ពីសំនួរ ទី ១ -២០ ) ។ ប្រសិនបើគេមិននៅផ្ទះយើងព្យាយាមទំនាក់ទំនងជាមួយប្តីប្រពន្ធ ។ប្រសិនបើគេទាំងពីរមិននៅយើងត្រូវតែទាក់ទងជាមួយមនុស្សពេញវ័យផ្សេងទៀតនៅក្នុងគ្រួសារ ។

### សួររាល់សមាជិកក្នុងគ្រួសារទាំងអស់ដែលមានអាយុ ១៨ឆ្នាំឡើង

**បង្គោលទី១** គឺជាការកត់ត្រាដំបូងនឹងលេខរៀង ឬក៏លេខកូដ នៃសមាជិកគ្រួសារម្នាក់ៗ ។ លេខរៀងបញ្ជាក់នឹងត្រូវប្រើប្រាស់ក្នុងកត់ត្រាចំលើយចំពោះសំនួរមួយចំនួនតាមរយៈសំនួរសំខាន់ៗរបស់គ្រួសារ ។ ដែលមានសារៈសំខាន់បំផុតចំពោះការកត់ត្រាដែលមានលេខកូដសំរាប់ម្នាក់ៗតាមរយៈសំនួរសំខាន់ៗពេលចាំបាច់ ។

**បង្គោលទី២** មន្ត្រីសំភាសន៍ត្រូវសួរទៅដល់អ្នកឆ្លើយពីសមាជិកម្នាក់ៗដោយផ្ទាល់ មនុស្សដែលត្រូវរាប់បញ្ចូលក្នុងគ្រួសារ ប្រសិនបើគេបានរស់នៅក្នុងគ្រួសារនោះ ឬក៏អវត្តមានតិចជាង ១២ខែ ។ អាស្រ័យហេតុនេះលេខរៀងគ្រួសារ( នៅក្នុងកូឡោន ១ )នឹងឈ្មោះសមាជិក( នៅក្នុងកូឡោន ២)និង ចុះក្នុងបញ្ជីសមាជិកគ្រួសារអចិន្ត្រៃយ៍នៅក្នុងគ្រួសារ ។ សួរទៅគេថា " តើមានសមាជិកប៉ុន្មាននាក់នៅក្នុងគ្រួសារនេះ?" រួចហើយចុះបញ្ជីសមាជិកនិមួយៗនៅក្នុងបង្គោលទី ២ ដោយធ្វើការកត់ត្រា ពីមេគ្រួសារចុះមក ( ប្តី ប្រពន្ធ កូន ចៅ តាមលំដាប់លំដោយ ។ល ។)

នៅពេលដែល មន្ត្រីសំភាសន៍បានចុះបញ្ជីរួចរាល់ហើយនោះ គេនឹងបន្តចុះនៅក្នុងបង្គោល ១ ទៅ ២០ របស់សមាជិកម្នាក់ៗដោយផ្ទាល់ ។ សួរសំនួរនៅបង្គោល ១ ទៅ ២០ របស់អ្នកទីមួយ និង ពេលរួចមកត្រូវអ្នកបន្តបន្ទាប់រហូតដល់អស់សមាជិក ។

**បង្គោល ៣:** ចុះលេខកូដភេទ" ១" សំរាប់ភេទប្រុស និង"២" សំរាប់ ភេទស្រី

**បង្គោល ៤ ក-គ:** ព្យាយាមសួរបញ្ជាក់ពីថ្ងៃខែឆ្នាំកំណើតពិតប្រាកដរបស់សមាជិកម្នាក់ៗ ។ ប្រសិនគេមិនដឹងពីថ្ងៃខែឆ្នាំ ត្រូវសួរឆ្នាំសត្វទាំង១២របស់ប្រក្រតីទិនខ្មែរ ។ តារាងបង្វែអាយុត្រូវបានចែកជូនដល់មន្ត្រីសំភាសនិដើម្បីគណនាអាយុពិតប្រាកដពីប្រក្រតីទិនខ្មែរទៅប្រក្រតីទិនលោកខាងលិច ។ សរសេរ" ៩៨" ប្រសិនបើមិនដឹងថ្ងៃនិងខែ សរសេរ "៩៩៩៨" ប្រសិនបើមិនដឹងឆ្នាំណា ។

**បង្គោល ៥:** សរសេរអាយុឆ្នាំពេញ ហើយសរសេរ "៩៦" ប្រសិនបើគេមានអាយុ ៩៦ រឺច្រើនជាង ប្រសិនបើអ្នកត្រូវសំភាសន៍ពិបាកឆ្លើយនូវសំនួរដែលទាក់ទងទៅនឹងអាយុរបស់គេព្យាយាមប៉ាន់ស្មានអាយុរបស់គេប្រសិនបើមិនអាចប៉ាន់ស្មានអាយុរបស់គេបាន ត្រូវចុះ "៩៨" ។

**បង្គោល ៦:** ចំពោះសំនួរជនជាតិត្រូវសួរសមាជិកទាំងអស់របស់គ្រួសារ ។

កូដជនជាតិមានដូចខាងក្រោម

ខ្មែរ, ចាម, ជនជាតិផ្សេងនៅក្នុងប្រទេស( ឧ. ភ្នង នៅក្នុងខេត្តមណ្ឌលគីរី) , ចិន, វៀតណាម, ថៃ, ឡាវ ផ្សេងៗ( បញ្ជាក់ចំពោះពីសញ្ជាតិបរទេសដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា

**បង្គោល ៧:** សំនួរអំពីសាសនា ត្រូវសួរសមាជិកទាំងអស់របស់គ្រួសារ ។

កូដសាសនាមានដូចខាងក្រោម

ពុទ្ធសាសនា, អ៊ីស្លាមសាសនា, គ្រឹះសាសនា, សាសនាផ្សេងទៀត( បញ្ជាក់) , គ្មានសាសនា

**បង្គោល ៨:** ស្ថានភាពអាពាហ៍ពិពាហ៍ត្រូវសួរតែសមាជិកគ្រួសារដែលមានអាយុ ១៨ ឆ្នាំឡើង ។ ចំពោះអ្នកដែលពោះ/មេម៉ាយ ឬលែងលះគ្នាប៉ុន្តែបានរៀបការហើយក៏ត្រូវចុះថារៀបការហើយ ។

កូដស្ថានភាពអាពាហ៍ពិពាហ៍មានដូចខាងក្រោម

នៅលីវ

រៀបការហើយ

រស់នៅជាមួយគ្នា

ពោះម៉ាយ/មេម៉ាយ

លែងលះគ្នា

បែកគ្នា

## សាកសួរពិតមានសមាជិកគ្រួសារដែលមានអាយុ៥ឆ្នាំឡើងទៅ

**បង្គោល ៩:** រាល់សំនួរទាំងអស់សួរសមាជិកគ្រួសារតែអ្នកដែលមានអាយុ១៨ឆ្នាំឡើងទៅ សួរទៅអ្នកដែលចេះអាននិងសរសេរ (ឃ្លាងាយៗ) គ្រប់ភាសាទាំងអស់សរសេរកូដលេខ "**១** "ឆ្លើយថា បាទ/ចាស និងកូដ "**២** " ទេ ។ ចំពោះអ្នកដែលចេះអាន ឬសរសេរឃ្លាងាយៗទោះបីជាគេមិនអាចអាន ឬសរសេរបានដោយសារការភ្លេចភ្លាំង ឬដោយសារជំងឺ (ឧ. ពិការភ្នែក)។ ក៏ត្រូវបានចុះលេខកូដ "១"ចំពោះអ្នកពិការភ្នែកចេះអាននឹងសរសេរដោយសារស្ទាប ។

**បង្គោល ១០:** សួរអ្នកដែលបានធ្លាប់ចូលរៀន ។ អ្នកបានរៀនរួមបញ្ចូលគ្រប់ប្រភេទនៃសាលារៀនគ្រប់ពេលពេលវេលាក្នុងជីវិតរបស់ពួកគេ(សំរាប់រយៈពេលយ៉ាងតិចមួយឆ្នាំ) ។ សូមចុះលេខកូដដូចខាងក្រោម

សរសេរកូដលេខ ១ = បាទ(ធ្លាប់បានចូលរៀន)

សរសេរកូដលេខ ២ = ទេ(មិនធ្លាប់បានចូលរៀន)(នៅក្នុងបង្គោល ១៤ក)

**បង្គោល ១១:** សួរគេអំពីកំរិតខ្ពស់បំផុតដែលពួកគេបានបញ្ចប់ជាស្ថាពរ ។

***សំគាល់* 1 :** ប្រសិនបើបុគ្គលនោះជាកុមារ ដែលបច្ចុប្បន្នកំពុងតែសិក្សានៅក្នុងសាលារៀន នោះកំរិតខ្ពស់បំផុត ដែលគាត់បានបំពេញដោយជោគជ័យនោះគឺ ជាថ្នាក់ចុងក្រោយដែលសិស្សនោះបានបញ្ចប់កាលពីឆ្នាំមុន ។ បើសិស្សនោះបច្ចុប្បន្នកំពុងរៀននៅថ្នាក់ទី 4 នោះកំរិតចុងក្រោយដែលគេទទួលបានជោគជ័យគឺថ្នាក់ទី 3 ។

លើសពីនេះ ចំពោះកុមារណាដែលប្រលងធ្លាក់កាលពីឆ្នាំសិក្សាចាស់ នោះកំរិតខ្ពស់បំផុតដែលសិស្សនោះបានបញ្ចប់ដោយជោគជ័យ គឺអាចមានរយៈពេលច្រើនជាង 1ឆ្នាំកន្លងមក ។

ចំណាំ: មុនពេល ១៩៧៥ ថ្នាក់ទី១២ គឺជាថ្នាក់ទាបបំផុត នឹងថ្នាក់ទី ១ គឺថ្នាក់ខ្ពស់បំផុត ។ មន្ត្រីសំភាសន៍ត្រូវពិភាក្សាជាមួយបញ្ហានេះតាមលំដាប់លំដោយដើម្បីកំណត់ឆ្នាំសិក្សាអោយបានត្រឹមត្រូវ ។

**បង្គោល ១២:** សួរអ្នកដែលកំពុងសិក្សា មានន័យថាចូលរួមសិក្សានៅក្នុងកំឡុងពេលឆមាស រឺ ឆ្នាំសិក្សា។ ចំណាំថាប្រសិនបើមនុស្សម្នាក់សំរាកលំហែកាយក៏ចាត់ទុកថាអ្នកនោះកំពុងសិក្សាដែរ ។ សូមចុះលេខកូដដូចខាងក្រោម

សរសេរលេខកូដ ១ = បាទ/ចាស

សរសេរលេខកូដ ២ = ទេ (រំលងទៅបង្គោល ១៤ ក)

**បង្គោល ១៣:** ត្រូវសួរពីកំរិតថ្នាក់ដែលគេកំពុងសិក្សា ។

៩៩ = មិនដែលចូលរៀនសោះ

00 = ថ្នាក់ដំបូង ឬមតេយ្យ

0១ = ថ្នាក់ទី ១

០២ = ថ្នាក់ទី ២

០៣ = ថ្នាក់ទី ៣

០៤ = ថ្នាក់ទី ៤

០៥ = ថ្នាក់ទី ៥

០៦ = ថ្នាក់ទី ៦

០៧ = ថ្នាក់ទី ៧

០៨ = ថ្នាក់ទី ៨

០៩ = ថ្នាក់ទី ៩

១០ = ថ្នាក់ទី ១០

១១ = ថ្នាក់ទី ១១

១២ = ថ្នាក់ទី ១២

១៣ = វិញ្ញាបនបត្រ័មធ្យមសិក្សាទុតិយភូមិ

១៤ = សញ្ញាបត្រ័ /វិញ្ញាបនប័ត្រមធ្យមសិក្សាបច្ចេកទេស ឬវិជ្ជាជីវៈ/តំរង់ទិសបុរេមធ្យមសិក្សា

១៥ = សញ្ញាបត្រ័/វិញ្ញាបនប័ត្រមធ្យមសិក្សាបច្ចេកទេស ឬវិជ្ជាជីវៈ/តំរង់ទិសក្រោយមធ្យម សិក្សា

១៦ = មិនទាន់បញ្ចប់ថ្នាក់សកលវិទ្យាល័យ/មហាវិទ្យាល័យ

១៧ = បញ្ចប់ថ្នាក់សកលវិទ្យាល័យ/មហាវិទ្យាល័យ

១៨ = ថ្នាក់ក្រោយឧត្តមសិក្សា

១៩ = ដទៃទៀត ( សូមបញ្ជាក់ )

## សួរសមាជិកគ្រួសារដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ

**បង្គោល ១៤កៈ** សួរមនុស្សដែលមានវត្តមាននៅផ្ទះក្នុងរយៈពេលធ្វើអង្កេត ។ សូមចុះលេខកូដដូចខាង ក្រោមៈ

សរសេរកូដលេខ ១ = បាទ វត្តមានក្នុងរយៈពេលធ្វើអង្កេត

សរសេរកូដលេខ ២ = ទេ អវត្តមានក្នុងរយៈពេលធ្វើអង្កេត

**បង្គោល ១៤ខៈ** សួរពីហេតុផលអ្នកដែលអវត្តមានក្នុងរយៈពេលធ្វើអង្កេត ។ សូមចុះលេខកូដហេតុផល ត្រឹមត្រូវ ដូចខាង ក្រោមៈ

សរសេរកូដលេខ ១ = សិក្សាឆ្ងាយពីផ្ទះ

សរសេរកូដលេខ ២ = ធ្វើការឆ្ងាយពីផ្ទះ

សរសេរកូដលេខ ៣ = រកការងារធ្វើឆ្ងាយពីផ្ទះ

សរសេរកូដលេខ ៤ = សួរសុខទុកបងប្អូនឆ្ងាយពីផ្ទះ

សរសេរកូដលេខ ៥ = ទៅលំហែកាយឆ្ងាយពីផ្ទះ

សរសេរកូដលេខ ៦ = ទៅព្យាបាលជំងឺឆ្ងាយពីផ្ទះ

សរសេរកូដលេខ ៧ = បេសកកម្មឆ្ងាយពីផ្ទះ

សរសេរកូដលេខ ៨ = ស្នាក់នៅឆ្ងាយពីផ្ទះដោយសារអសន្តិសុខ

សរសេរកូដលេខ ៩ = ទៅបរទេស

សរសេរកូដលេខ ១០ = ផ្សេងទៀត( សូមបញ្ជាក់)

**សកម្មភាពសេដ្ឋកិច្ច ក្នុងរយៈពេលមួយខែកន្លងមក**

**សួរសមាជិកគ្រួសារទាំងអស់អាយុចាប់ពី ១៨ ឆ្នាំឡើងអំពីមុខរបរចំបង**

**បង្គោល ១៥:** សួរពួកគេថាតើលោក/អ្នកមានធ្វើការងារដែរឬទេ ?សូម្បីតែមួយម៉ោង( ប្រសិនបើមិន ធ្វើការមានការងារធ្វើមួយ) ចំពោះមុខរបរចំបងរយៈពេលខែមុន ។ កំពុងធ្វើការ ឬអ្នកមានការងារធ្វើមានន័យថាមនុស្សម្នាក់មានការងារធ្វើ កសិដ្ឋានផ្នែកឯកជន ឬ រដ្ឋ ដើមទុនដោយខ្លួនឯង ឬក៏អាជីកម្មរបស់នរណាម្នាក់ទៀតនៅក្នុងគ្រួសារផ្ទាល់ខ្លួន ។ល។) ។ សូមចុះលេខកូដដូចខាង ក្រោម:

សរសេរកូដលេខ ១ = បាទ (ធ្វើការងារណាមួយ ឬមានមុខរបរណាមួយកាលពីមួយខែកន្លងមក។)

សរសេរកូដលេខ ២ = ទេ (មិនធ្វើការងារណាមួយ ឬ គ្មានមុខរបរណាមួយកាលពីមួយខែកន្លងមក ។)( រំលងទៅបង្គោល ២ សំនួរ ២០ នៃផ្នែកបន្ទាប់)

**ចំណាំ : បើសិនអ្នកធ្វើការ ឬមុខរបរតែមួយក្នុងខែមុនចាត់ទុកថាជាមុខរបរចំបង ។**

**បង្គោល ១៦ក.ខ:** មុខរបរចំបង ត្រូវសួរមុខរបរចំបងរបស់អ្នកដែលមានមុខរបរនៅខែមុន ។ សរសេរពិពណ៌នានៅក្នុងបង្គោល១៦ក ។ សរសេរពិពណ៌នាអោយបានច្បាស់នូវការងារដែលជននោះបានធ្វើ។ ឧ.មិនត្រូវសរសេរ "កម្មរោងចក្រ" ប៉ុន្តែត្រូវសរសេរអ្វីដែលអ្នកនោះធ្វើក្នុងរោងចក្រដូចជាអ្នកបញ្ជារម៉ាស៊ីន ដេរប៉ាក់ ឬជាងជួសជុលម៉ាស៊ីន ។ ប្រសិនបើអ្នកនោះមានមុខរបរប៉ុន្តែមិនបានធ្វើការដោយសារតែកាព្យួរការងារសំរាកលំហែកាយ ឬក៏ដោយសាជំងឺ សរសេរមុខរបរណាដែលគេអាចសង្ឃឹមថាគេវិលត្រឡប់ទៅធ្វើការវិញ ។ ការពិពណ៌នាត្រូវតែលំអិតហ្មត់ចត់ ដូច្នេះកូដនៃមុខរបរក៏ចុះនៅក្នុងបង្គោល ១៦ខ សំរាប់ការិយាល័យរបស់វិជ្ជាស្ថាន ជាតិស្ថិតិ ។ ចំណាំថាអ្នកសុំទាន និងអ្នករកស៊ីផ្លូវភេទគឺជាមុខរបរ ។

**ចំណាំ : ដោយថ្នាំជក់គឺជាចំនុចសំខាន់របស់អង្កេត មន្ត្រីសំភាសន៍នឹងកំណត់អ្វី១ថាតើ គោលបំណងនៃអ្នកដាំថ្នាំជក់ (គឺជាមុខរបរចំបង)កូដរបស់អ្នកដាំថ្នាំជក់ត្រូវបានចុះដោយការិយាល័យវិជ្ជាស្ថានជាតិស្ថិតិ។**

**បង្គោល ១៦គ.ឃ:** ពណ៌នាអំពីវិស័យ ឬប្រភេទនៃសកម្មភាពសេដ្ឋកិច្ចដែលទាក់ទងនិងធម្មជាតិរបស់ការងារខែមុន ( ដូចជាកសិកម្ម កម្មន្តសាល សំណង់ ពាណិជ្ជកម្ម ឬសេវាកម្ម ។ល។) តាមគ្រឹះស្ថាន ឬកន្លែងធ្វើការ ឬសហគ្រាសដែលអ្នកនោះបានធ្វើ ។ ពណ៌នាត្រូវតែមានការលំអិតហើយហ្មត់ចត់ ដូច្នេះកូដវិស័យត្រូវបានចុះក្នុងបង្គោល ១៦ ឃ ចុះដោយការិយាល័យវិជ្ជាស្ថានជាតិស្ថិតិ។

**បង្គោល ១៦ង:** សួរអ្នកដែលមានការងារធ្វើចំពោះមុខរបរចំបងរយៈពេលខែមុន ។ លេខកូដស្ថានភាពការងារដូចខាងក្រោម:

០១ = និយោជិកដែលទទួលប្រាក់កំរៃ/ប្រាក់ឈ្នួល

០២ = និយោជក

០៣ = ការងារទុនផ្ទាល់ខ្លួន ,ការងារខ្លួនឯង

០៤ = ធ្វើការងារអោយគ្រួសារ ( មិនបានទទួលប្រាក់កំរៃ)

០៥ = ផ្សេងៗ ( បញ្ជាក់)

**បង្គោល ១៦ច:** សួរប្រភេទការងាររបស់អ្នកបានធ្វើក្នុងមុខរបរចំបងរយៈពេលមួយខែកន្លងមក

លេខកូដប្រភេទការងារដូចខាងក្រោម:

សរសេរកូដលេខ ០១ = រដ្ឋាភិបាល

សរសេរកូដលេខ០២ = សហគ្រាសរដ្ឋ

សរសេរកូដលេខ០៣ = សហគ្រាសឯកជន

សរសេរកូដលេខ០៤ = ក្រុមហ៊ុនសហកម្មសិទ្ធិ

សរសេរកូដលេខ០៥ = រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ

សរសេរកូដលេខ០៦ = អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

សរសេរកូដលេខ០៧ = កសិដ្ឋានផ្ទាល់ខ្លួន

សរសេរកូដលេខ០៨ = មិនមែនកសិដ្ឋានផ្ទាល់ខ្លួន

សរសេរកូដលេខ០៩ = អ្នកបំរើក្នុងគ្រួសារ

សរសេរកូដលេខ១០ = ផ្សេងៗ( បញ្ជាក់)

**បង្គោល១៧ក-ខ :**សាកសួរចំនូលប្រចាំខែ ចំពោះអ្នកមានប្រាក់ឈ្នួល។ សរសេរជាមធ្យមប្រាក់ឈ្នួល/ប្រាក់ខែជាសាច់ប្រាក់នៅក្នុងបង្គោល**១៧ក** និងជារបស់ នៅក្នុងបង្គោល**១៧ខ** ចំពោះមុខរបរចំបង។ សរសេរ " ៩៨ " ពេលដែលមិនអាចបំពេញបាន ។ ចំពោះអ្នកធ្វើការអោយដោយមិនយកប្រាក់ចំណូលត្រូវកត់ត្រាថាមិនអាចបំពេញ បាន "៩៨ " ។

សួរចំណូលប្រចាំខែអ្នកប្រើប្រាស់ទុនផ្ទាល់ខ្លួនដែលទាក់ទងទៅនឹងសកម្មភាពកសិកម្មមានការដាំដុះ ចិញ្ចឹម សត្វ នេសាទ និង ការចិញ្ចឹមត្រី ។ល។ សកម្មភាពអាជីវកម្ម និងសេវាផ្សេងៗចំពោះមុខរបរចំបង។ ប្រសិនបើគេមិនអាចបែងចែកចំណូលប្រចាំខែបានត្រូវសួរប៉ាន់ស្មានប្រចាំថ្ងៃ សប្តាហ៍ឬក៏ប្រចាំឆ្នាំ រួចហើយត្រូវប្រើប្រាស់រូបមន្តដូចខាងក្រោម :

១-ប៉ាន់ស្មានប្រាក់ចំណូលប្រចាំខែ = ប៉ាន់ស្មានចំណូលប្រចាំថ្ងៃ គុណនឹង ៣០ ថ្ងៃ

២-ប៉ាន់ស្មានប្រាក់ចំណូលប្រចាំខែ = ប៉ាន់ស្មានក្នុងមួយសប្តាហ៍ គុណនឹង ៤ សប្តាហ៍

៣-ប៉ាន់ស្មានប្រាក់ចំណូលប្រចាំខែ = ប៉ាន់ស្មានចំណូលប្រចាំឆ្នាំ ចែកនឹង ១២ ខែ

**ចំណាំ : រូបមន្តនេះ ជាមូលដ្ឋានអនុវត្តន៏ ចំពោះកសិករធ្វើការតាមតំរូវការ ឬក៏អាជីវកម្មផ្សេងទៀត និងសកម្មភាពសេវាកម្មរបស់មុខរបរចំបង។ ចំណូលជារបស់ឬក៏កសិផល។ល។ យើងត្រូវតែបង្វែរទៅជាប្រាក់រៀលដោយយកតំលៃលើទីផ្សារបច្ចុប្បន្ន។**

## សកម្មភាពសេដ្ឋកិច្ច ក្នុងរយៈពេលមួយខែកន្លងមក
## សួរសមាជិកគ្រួសារទាំងអស់អាយុចាប់ពី ១៨ ឆ្នាំឡើងអំពីមុខរបរបន្ទាប់បន្សំ

**បង្គោល ១៨ :** សួរអ្នកធ្វើការទាំងឡាយសូម្បីតែមួយម៉ោង (ប្រសិនបើគេមិនធ្វើការប៉ុន្តែគេមានការងារធ្វើ)ចំពោះមុខរបរបន្ទាប់បន្សំក្នុងរយៈពេលខែមុន។ កំពុងធ្វើការឬក៏មានការងារធ្វើមានន័យថាអ្នកនោះមានការងារធ្វើជាផ្នែកកសិដ្ឋាន ផ្នែកឯកជនឬក៏រដ្ឋ ប្រើប្រាស់ទុនផ្ទាល់ខ្លួនឬក៏កម្មសិទ្ធរបស់អ្នកផ្សេងទៀតដែលមាននៅក្នុងគ្រួសារ។ល។ ត្រូវចុះលេខកូដដូចខាងក្រោម :

សរសេរកូដលេខ ១ = បាទ (ធ្វើការងារណាមួយ ឬមានមុខរបរណាមួយកាលពីមួយខែកន្លងមក។)

សរសេរកូដលេខ ២ = ទេ (មិនធ្វើការងារណាមួយ ឬ គ្មានមុខរបរណាមួយកាលពីមួយខែកន្លងមក។)(រំលងទៅបង្គោល ២ សំនួរ ២០)

**បង្គោល១៩ក-ខ:**មុខរបរបន្ទាប់បន្សំ : សួរមុខរបរបន្ទាប់បន្សំរបស់គេរយៈពេលខែមុនសរសេរពិពណ៌នានៅក្នុងបង្គោល ១៩ក ។ សរសេរពិពណ៌នាអោយបានច្បាស់នូវការងារដែលជននោះបានធ្វើ។ ឧ. មិនត្រូវ សរសេរ "កម្មរោងចក្រ" ប៉ុន្តែត្រូវសរសេរអ្វីដែលអ្នកនោះធ្វើក្នុងរោងចក្រដូចជាអ្នកបញ្ជារម៉ាស៊ីន ដេរប៉ាក់ ឬជាងជួសជុលម៉ាស៊ីន ។ ប្រសិនបើអ្នកនោះ មានមុខរបរប៉ុន្តែមិនបានធ្វើការ ដោយសារតែការព្យួរការងារសំរាក លំហែកាយ ឬក៏ដោយសាជំងឺ សរសេរមុខរបរណាដែលគេអាចសង្ឃឹមថាគេវិលត្រឡប់ទៅធ្វើការវិញ ។ ការ ពិពណ៌នាត្រូវតែលំអិតហ្មត់ចត់ ដូច្នេះកូដនៃមុខរបរក៏ចុះនៅក្នុងបង្គោល ១៩ខ សំរាប់ការិយាល័យរបស់វិជ្ជាស្ថាន ជាតិស្ថិតិ ។ ចំណាំថាអ្នកសុំទាន និងអ្នករកស៊ីផ្លូវភេទគឺជាមុខរបរ ។

**ចំណាំ : ដោយថ្នាំជក់គឺជាចំនុចសំខាន់របស់អង្កេត មន្ត្រីសំភាសន៏នឹងកំណត់អ្វីៗថាតើ គោលបំណងនៃអ្នកដាំថ្នាំជក់ (គឺជាមុខរបរចំបង)កូដរបស់អ្នកដាំថ្នាំជក់ត្រូវបានចុះដោយការិយាល័យវិជ្ជាស្ថានជាតិស្ថិតិ។**

**បង្គោល ១៩គ-ឃ :**មុខរបរបន្ទាប់បន្សំ :ត្រូវសួរមុខរបរបន្ទាប់បន្សំរបស់អ្នកដែលមានមុខរបរនៅខែមុន។ សរសេរ ពិពណ៌នានៅក្នុងបង្គោល២៤ក ។ សរសេរពិពណ៌នាអោយបានច្បាស់នូវការងារដែលជននោះបានធ្វើ។ ឧ.មិនត្រូវសរសេរ"កម្មរោងចក្រ"ប៉ុន្តែត្រូវសរសេរអ្វីដែលអ្នកនោះធ្វើក្នុងរោងចក្រដូចជាអ្នកបញ្ជារម៉ាស៊ីនដេរប៉ាក់ ឬជាងជួសជុលម៉ាស៊ីន ។ ប្រសិនបើអ្នកនោះមានមុខរបរប៉ុន្តែមិនបានធ្វើការដោយសារតែការព្យួរការងារសំរាក លំហែកាយឬក៏ដោយសាជំងឺសរសេរមុខរបរណាដែលគេអាចសង្ឃឹមថាគេវិលត្រឡប់ទៅធ្វើការវិញ ។ការពិពណ៌នាត្រូវតែលំអិតហ្មត់ចត់ ដូច្នេះកូដនៃមុខរបរក៏ចុះនៅក្នុងបង្គោល ១៩ឃ សំរាប់ការិយាល័យរបស់វិទ្យាស្ថានជាតិស្ថិតិ ។

**បង្គោល១៩ង :** សួរអ្នកដែលមានការងារធ្វើចំពោះមុខរបរបន្ទាប់បន្សំរយៈពេលមួយខែកន្លងមក។ លេខកូដស្ថានភាព ការងារដូចខាងក្រោម:

០១ = និយោជិកដែលទទួលប្រាក់កំរៃ/ប្រាក់ឈ្នួល

០២ = និយោជក

០៣ = ការងារទុនផ្ទាល់ខ្លួន ,ការងារខ្លួនឯង

០៤ = ធ្វើការងារអោយគ្រួសារ ( មិនបានទទួលប្រាក់កំរៃ)

០៥ = ផ្សេងៗ ( បញ្ជាក់)

**បង្គោល ១៩ច :** សួរប្រភេទការងាររបស់អ្នកបានធ្វើក្នុងមុខរបរបន្ទាប់បន្សំរយៈពេលមួយខែកន្លងមក ។

លេខកូដប្រភេទការងារដូចខាងក្រោម:

សរសេរកូដលេខ ០១ = រដ្ឋាភិបាល

សរសេរកូដលេខ០២ = សហគ្រាសរដ្ឋ

សរសេរកូដលេខ០៣ = សហគ្រាសឯកជន

សរសេរកូដលេខ០៤ = ក្រុមហ៊ុនសហកម្មសិទ្ធិ

សរសេរកូដលេខ០៥ = រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ

សរសេរកូដលេខ០៦ = អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

សរសេរកូដលេខ០៧ = កសិដ្ឋានផ្ទាល់ខ្លួន

សរសេរកូដលេខ០៨ = មិនមែនកសិដ្ឋានផ្ទាល់ខ្លួន

សរសេរកូដលេខ០៩ = អ្នកបំរើក្នុងគ្រួសារ

សរសេរកូដលេខ១០ = ផ្សេងៗ( បញ្ជាក់)

**បង្គោល២០ក-ខ :**សាកសួរចំនូលប្រចាំខែ ចំពោះអ្នកមានប្រាក់ឈ្នួល។ សរសេរជាមធ្យមប្រាក់ឈ្នួល/ប្រាក់ខែជាសាច់ប្រាក់នៅក្នុងបង្គោល**២០ក** និងជារបស់ នៅក្នុងបង្គោល**២០ខ** ចំពោះមុខរបរបន្ទាប់បន្សំ។ សរសេរ " ៩៨ "

ពេលដែលមិនអាចបំពេញបាន ។ ចំពោះអ្នកធ្វើការអោយដោយមិនយកប្រាក់ចំណូលត្រូវកត់ត្រាថាមិនអាចបំពេញ បាន "៩៨" ។

សួរចំណូលប្រចាំខែអ្នកប្រើប្រាស់ទុនផ្ទាល់ខ្លួនដែលទាក់ទងទៅនឹងសកម្មភាពកសិកម្មមានការដាំដុះ ចិញ្ចឹម សត្វ នេសាទ និង ការចិញ្ចឹមត្រី ។ល។ សកម្មភាពអាជីវកម្ម និងសេវាផ្សេងៗចំពោះមុខរបរបន្ទាប់បន្សំ។ ប្រសិនបើគេមិនអាចបែងចែកចំណូលប្រចាំខែបានត្រូវសួរប៉ាន់ស្មានប្រចាំថ្ងៃ សប្តាហ៍ឬក៏ប្រចាំឆ្នាំ រួចហើយត្រូវប្រើប្រាស់រូបមន្តដូចខាងក្រោម :

១-ប៉ាន់ស្មានប្រាក់ចំណូលប្រចាំខែ = ប៉ាន់ស្មានចំណូលប្រចាំថ្ងៃ គុណនឹង ៣០ ថ្ងៃ

២-ប៉ាន់ស្មានប្រាក់ចំណូលប្រចាំខែ = ប៉ាន់ស្មានក្នុងមួយសប្តាហ៍ គុណនឹង ៤ សប្តាហ៍

៣-ប៉ាន់ស្មានប្រាក់ចំណូលប្រចាំខែ = ប៉ាន់ស្មានចំណូលប្រចាំឆ្នាំ ចែកនឹង ១២ ខែ

**ចំណាំ : រូបមន្តនេះ ជាមូលដ្ឋានអនុវត្ត ចំពោះកសិករធ្វើការតាមតំរូវការ ឬក៏អាជីវកម្មផ្សេងទៀត និង សកម្មភាពសេវាកម្មរបស់មុខរបរបន្ទាប់បន្សំ ។ ចំណូលជារបស់ឬក៏កសិផល ។ល ។យើងត្រូវតែបង្វែរទៅជាប្រាក់រៀលដោយយកតំលៃលើទីផ្សារបច្ចុប្បន្ន ។**

ផ្នែកទី : ការប្រើប្រាស់ថ្នាំជក់

**III.ក ពត៌មានពីបារី**

សួរសមាជិកទាំងអស់នៅក្នុងគ្រួសារដែលមានអាយុ ១៨ឆ្នាំឡើងទៅនឹងមានវត្តមាននៅក្នុងពេលធ្វើ អង្កេត ។

**បង្គោល ១ :** មន្ត្រីសំភាសន៍ត្រូវចុះកត់ត្រាសំគាល់របស់សមាជិកគ្រួសារដែលមានអាយុ១៨ឆ្នាំឡើងទៅជាអ្នកវត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត។ លេខសំគាល់របស់សមាជិកគ្រួសារត្រូវចំលងចេញពីបញ្ជីក្នុងផ្នែកសំណួរប្រជាសាស្រ្តទំព័រទី ២ ប៉ុណ្ណោះប្រសិនបើបង្គោល ១៤ ក = ១ (វត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត)

**បង្គោល ២ (សំនួរ ២០):** សួរអ្នកដែលបានជក់យ៉ាងតិចណាស់ ១០០ដើមនៅក្នុងជីវិតរបស់គេ ។

សរសេរកូដលេខ ១ = បាទ /ចាស

សរសេរកូដលេខ ២ = ទេ

**បង្គោល ៣ (សំនួរ ២១ ):** អ្នកធ្លាប់ជក់បារីក្នុងរយៈពេលយ៉ាងតិច៦ខែនៅក្នុងជីវិតរបស់អ្នក ។

សរសេរកូដលេខ ១ = បាទ /ចាស

សរសេរកូដលេខ ២ = ទេ

**បង្គោល ៤ (សំនួរ២២ ):** សួរអ្នកជក់បារីនៅពេលបច្ចុប្បន្ន

សរសេរកូដលេខ ១ = បាទ/ចាស

សរសេរកូដលេខ ២ = ទេ ( បើទេ រំលងទៅផ្នែកបន្ទាប់ )

**បង្គោល ៥** (សំនួរ២៣): ត្រូវថាតើក្នុងរយៈពេល៣០ថ្ងៃកន្លង មកនោះលោកអ្នកមានពិសារបារីដែល ឬទេ ? សរសេរលេខកូដចំនួនថ្ងៃដូចខាងក្រោម :

១= ១ថ្ងៃ

២= ២ - ៥ថ្ងៃ

៣=៦ - ៩ថ្ងៃ

៤ =១០-១៩ថ្ងៃ

៥ =២០-២៩ថ្ងៃ

៦ =៣០ថ្ងៃ

៩ = មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល ៦ (សំនួរ២៤):** ក្នុងកំឡុងពេល ៣០ថ្ងៃតើអ្នកជក់បារីប៉ុន្មានថ្ងៃ សរសេរចំនួនថ្ងៃរបស់អ្នកជក់៣០ថ្ងៃកន្លងមក។ សរសេរ " ៩៩ " បើមិនដឹង/បដិសេធមិនព្រមឆ្លើយ។ លើសពីនេះទៅទៀតត្រូវបញ្ជាក់ពីស្ថានភាពជក់១ហឺត១ដើមឬក៏ច្រើនជាងនេះក៏ដោយ។

**បង្គោល ៧ (សំនួរ២៥):** នៅក្នុងកំឡុងពេល ៣០ថ្ងៃតើអ្នកជក់បារីជាមធ្យមប៉ុន្មានដើមក្នុង១ថ្ងៃ

១= តិចជាង១ដើមក្នុង១ថ្ងៃ

២= ១ ដើមក្នុង១ថ្ងៃ

៣=២-៥ ដើមក្នុង១ថ្ងៃ

៤ =៦-១៥ដើមក្នុង១ថ្ងៃ

៥ =១៦-២៥ដើមក្នុង១ថ្ងៃ

៦ =២៦-៣៥ដើមក្នុង១ថ្ងៃ (ប្រហែល១កញ្ចប់កន្លះ)

៧= ច្រើនជាង៣៥ដើមក្នុង១ថ្ងៃ (ប្រហែលយ៉ាងតិច២កញ្ចប់កន្លះ)

៩ = មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល ៨ (សំនួរ២៦):** នៅក្នុងកំឡុងពេលជក់បារី ៣០ថ្ងៃ តើលោក/អ្នកជក់បារីមូរដៃដែរឬទេ ?

ចុះលេខកូដនៅខាងក្រោម :

សរសេរកូដលេខ ១ = បាទ

សរសេរកូដលេខ ២ = ទេ (បើទេបន្តទៅបង្គោលទី១០)

សរសេរកូដលេខ ៩ =មិនដឹង/បដិសេធមិនព្រមឆ្លើយ (បន្តទៅបង្គោលទី១០)

**បង្គោល ៩ (សំនួរ២៧):**នៅថ្ងៃដែលអ្នកជក់បារីកំឡុងពេល ៣០ថ្ងៃកន្លងមកនេះ តើអ្នកជក់បារីមូរនឹងអ្វីដែលញឹកញាប់ជាងគេ។

ចុះលេខកូដនៅខាងក្រោម :

១= ក្រដាស់

២=ស្លឹកចេក

៣=ស្លឹកថ្នាំជក់

៤=ស្លឹកសង្កែ

៩=មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល ១០ (សំនួរ២៨):** នៅថ្ងៃដែលអ្នកជក់បារីកំឡុងពេល ៣០ថ្ងៃកន្លងមកនេះ តើអ្នកជក់បារីកញ្ចប់ដែរឬទេ ?

សរសេរកូដលេខ ១ = បាទ/ចាស់

សរសេរកូដលេខ ២ = ទេ (បើទេរំលងបង្គោល១៤)

សរសេរកូដលេខ ៩ =មិនដឹង/បដិសេធមិនព្រមឆ្លើយ (រំលងទៅបង្គោល១៤)

**បង្គោល ១១ (សំនួរ២៩):** ប្រភេទបារីកញ្ចប់ដែលអ្នកបានជក់ ៣០ថ្ងៃកន្លងមក (សូមបង្ហាញពីផ្លាកសញ្ញារបស់កញ្ចប់បារី ។

ចុះលេខកូដនៅខាងក្រោម :

១=ប្រភេទស្រាល

២=ប្រភេទរសជាតិពេញលក្ខណៈ

៣=ប្រភេទជាតិម៉ង់តុល

៩=មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល១២(សំនួរ៣០):**នៅក្នុងកំឡុងពេលជក់បារី៣០ថ្ងៃតើម៉ាកអ្វីដែលលោក/អ្នកបានជក់ បង្ហាញកាតរូបភាពលេខ១ ហើយដាក់លេខកូដតាមរូបភាពនោះ។

ចុះ ៩៩៩=មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល១៣(សំនួរ៣១):** នៅក្នុងកំឡុងពេលជក់បារី៣០ថ្ងៃតើបារីកញ្ចប់ដែលលោក/អ្នកបានជក់មួយដើមថ្លៃប៉ុន្មានរៀល ។ សរសេរតំលៃជារៀល

**បង្គោល១៣ក(សំនួរ៣១ក):** តើអ្នកទិញបារីកញ្ចប់ ដូចម្តេច? ចុះលេខកូដដូចខាងក្រោមនេះ

១=ទិញបារីរាយ (មានន័យថា អ្នកទិញបារីមួយដើមក្នុងពេលម្តង គឺមិនទិញជាកញ្ចប់ ឬថង់ឡើយ)

២=ទិញកញ្ចប់ (មានន័យថា អ្នកទិញបារីជាកញ្ចប់ ឬកញ្ចប់ផ្សេងទៀត ឧទាហរណ៍ កញ្ចប់ផ្លាស្ទិកដែលមានបារី ២០ ដើម)

៣=រាយផង កញ្ចប់ផង (ទិញទាំងប្រភេទខាងលើ)

៩ = មិនដឹង ឬបដិសេធមិនឆ្លើយ

នៅក្នុងកំឡុងពេលជក់បារី៣០ថ្ងៃតើបារីកញ្ចប់ដែលលោក/អ្នកបានជក់មួយដើមថ្លៃ ប៉ុន្មានរៀល ។ សរសេរតំលៃជារៀល

**សំនួរ (៣២-៣៥): ចំណាយលើការជក់បារី**

**បង្គោល១៤ (សំនួរ៣២):** តើបារីកញ្ចប់ដែលលោក/អ្នកបានលុយជាសរុបប៉ុន្មានក្នុងមួយសប្តាហ៍កន្លង មកនេះ ( សរសេរជាតំលៃរៀល )។ មន្ត្រីសំភាសន៍ត្រូវពិនិត្យត្រង់ចំណាយលើបារី នៅសប្តាហ៍កន្លងទៅនៅត្រង់សំនួរ៣៣ , ៣៤ និង ៣៥ ដើម្បីបូកសរុបអោយស្មើរក្នុងបង្គោល១៤ (សំនួរ៣២)

**ចំណាំ : បង្គោល ១៤ (សំនួរ ៣២) = បង្គោល ១៥ (សំនួរ ៣៣) + បង្គោល ១៦ (សំនួរ ៣៤ + បង្គោល ១៧ (សំនួរ ៣៥)**

**បង្គោល ១៥ (សំនួរ៣៣):** ត្រូវសួរចំណាយសរុបនៃការទិញបារី ដាក់តំលៃជាប្រាក់រៀល ។ សរសេរលេខ "០០" ប្រសិនបើមិនបានទិញបារីពីសប្តាហ៍កន្លងទៅ។

**ចំណាំ : ប្រសិនជាអ្នកជក់បារីប្រើប្រាស់បារីបានទិញទុកមុនសប្តាហ៍កន្លងទៅ សូមព្យាយាមប៉ាន់ស្មាន ចំណាយទៅលើបារីដូចដែលគាត់បានជក់ក្នុងសប្តាហ៍កន្លងទៅ។**

**បង្គោល ១៦ (សំនួរ ៣៤)** ត្រូវសួរចំណាយសរុបនៃការដោះដូរបារី ដាក់តំលៃជារៀល ។ សរសេរលេខ "០០" ប្រសិនបើមិនបានដោះដូរបារីពីសប្តាហ៍កន្លងទៅ ។

**ចំណាំ : ប្រសិនបើអ្នកជក់បារីប្រើប្រាស់បារីដែលបានដោះដូរមុនសប្តាហ៍កន្លងទៅ សូមព្យាយាមប៉ាន់ស្មាន ចំណាយទៅលើបារីដោះដូរដូចដែលគាត់បានជក់ក្នុងសប្តាហ៍កន្លងទៅ។**

**បង្គោល ១៧ (សំនួរ ៣៥):** ត្រូវសួរចំនួនបារីដែលបានពីអំណោយដាក់តំលៃជាប្រាក់រៀល ។សរសេរលេខ"០០" ប្រសិនបើពុំបានទទួលបារីជាអំណោយកាលពីសប្តាហ៍កន្លងទៅ ។

**ចំណាំ : ប្រសិនជាអ្នកជក់បារីប្រើប្រាស់បារីដែលបានពីអំណោយមុនសប្តាហ៍កន្លងទៅ សូមព្យាយាមប៉ាន់ស្មាន ចំណាយទៅលើបារីដូចដែលគាត់បានជក់ក្នុងសប្តាហ៍កន្លងទៅ។**

**បង្គោល ១៨ (សំនួរ ៣៦):** ត្រូវសួរទីកន្លែងដែលគេទទួលបានបារី សរសេរលេខកូដដូចខាងក្រោម

១ =ទិញកន្លែងហាង

២=ការដោះដូរគ្នា

៣ = ខ្ញុំដាំសំរាប់ជក់ខ្លួនឯង

៤ = ជាអំណោយ

៩ =មិនដឹង/បដិសេធមិនព្រមឆ្លើយ

**III. ខ ថ្នាំជក់សំរាប់ចុក**

**សួរសមាជិកទាំងអស់ក្នុងគ្រួសារមានអាយុ ១៨ឆ្នាំឡើងនឹងមានវត្តមាននៅក្នុងពេលធ្វើអង្កេត**

**បង្គោល ១** មន្ត្រីសំភាសន៍ត្រូវចុះកត់ត្រាសំគាល់របស់សមាជិកគ្រួសារដែលមានអាយុ១៨ឆ្នាំឡើងទៅជាអ្នកវត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត។ លេខសំគាល់របស់សមាជិកគ្រួសារត្រូវចំលងចេញពីបញ្ជីក្នុងផ្នែកសំណួរប្រជាសាស្ត្រទំព័រទី ២ ប៉ុណ្ណោះប្រសិនបើបង្គោល ១៤ ក= ១ (វត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត)

**បង្គោល ២ (សំនួរ ៣៧)**: សួរអ្នកដែលបានចុកថ្នាំយ៉ាងតិចណាស់ ៦ខែនៅក្នុងជីវិតរបស់គេ ។

សរសេរកូដលេខ ១ = បាទ/ចាស

សរសេរកូដលេខ ២ = ទេ

**បង្គោល ៣ សំនួរ ៣៨ )**: សួរអ្នកចុកថ្នាំនៅពេលបច្ចុប្បន្ន

សរសេរកូដលេខ ១ = បាទ/ចាស

សរសេរកូដលេខ ២ = ទេ (បើទេ ទៅផ្នែកបន្ទាប់ )

**បង្គោល ៤ (សំនួរ ៣៩ )**: ត្រូវសួរថាតើក្នុងរយៈពេល៣០ថ្ងៃកន្លងមកនោះអ្នកមានចុកថ្នាំដែរ ឬទេ ? សរសេរលេខកូដចំនួនថ្ងៃដូចខាងក្រោម :

១ = ១ថ្ងៃ

២ = ២ - ៥ថ្ងៃ

៣ =៦ - ៩ថ្ងៃ

៤ = ១០-១៩ថ្ងៃ

៥ = ២០-២៩ថ្ងៃ

៦ = ៣០ថ្ងៃ

៩ = មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល ៥ (សំនួរ ៤០)**: ក្នុងកំឡុងពេល ៣០ថ្ងៃតើអ្នកចុកថ្នាំប៉ុន្មានថ្ងៃចុះចំនួនថ្ងៃរបស់អ្នកចុក ថ្នាំក្នុងរយៈពេល ៣០ថ្ងៃកន្លងមក។ សរសេរ " ៩៩ " បើមិនដឹង/បដិសេធមិនព្រមឆ្លើយ។

**បង្គោល ៦ (សំនួរ ៤១)**: នៅក្នុងកំឡុងពេល ៣០ថ្ងៃតើអ្នកចុកថ្នាំជាមធ្យមប៉ុន្មានដងក្នុង១ថ្ងៃ ។ចុះចំនួនដងនៃការចុកថ្នាំប្រចាំថ្ងៃ

**បង្គោល ៧ (សំនួរ ៤២)**: សួរអ្នកចុកថ្នាំថា នៅប៉ុន្មានថ្ងៃដែលគាត់ចុកថ្នាំក្នុងកំឡុងពេល៣០ថ្ងៃ កន្លងទៅនេះតើចុកអស់ប៉ុន្មានក្នុងមួយដង ? បង្ហាញកាតរូបភាពលេខ ២(បរិមាណថ្នាំចុក)រួចចុះលេខកូដនៅខាងក្រោម :

១ =  ច្រើនជាងបរិមាណនេះ

២ = ប្រហែលស្មើបរិមាណនេះ

៣= តិចជាងបរិមាណនេះ

**សំនួរ (៤៣-៤៦ ):ការចំណាយទៅលើថ្នាំចុក**

**បង្គោល៨ (សំនួរ ៤៣)** តើអ្នកបានចំណាយលុយជាសរុបប៉ុន្មានក្នុងមួយសប្តាហ៏កន្លង មកនេះ ( សរសេរជាតំលៃរៀល ) ។ មន្ត្រីសំភាសន៏ត្រូវពិនិត្យត្រង់ចំណាយលើថ្នាំចុក នៅសប្តាហ៏កន្លងទៅ នៅត្រង់ សំនួរ ៤៤ - ៤៥ - ៤៦ ដើម្បីបូកសរុបអោយស្មើក្នុងបង្គោល៨ ( សំនួរ ៤៣)

**ចំណាំ : បង្គោល ៨ ( សំនួរ ៤៣ ) = បង្គោល ៩ ( សំនួរ ៤៤ )  + បង្គោល ១០ ( សំនួរ ៤៥ )**

**+ បង្គោល ១១ ( សំនួរ ៤៦ )**

**បង្គោល ៩ ( សំនួរ ៤៤): ត្រូវសួរចំនួនសរុបនៃការទិញថ្នាំចុកដាក់តំលៃជាប្រាក់រៀល ។ សរសេរលេខ "00" ប្រសិនបើគេមិនបានទិញថ្នាំចុកពីសប្តាហ៏មុន ។**

**ចំណាំ : ប្រសិនជាអ្នកចុកថ្នាំប្រើប្រាស់ថ្នាំចុកបានទិញទុកមុនសប្តាហ៏កន្លងទៅ សូមព្យាយាមប៉ាន់ស្មានចំណាយទៅលើថ្នាំចុកដូចដែលគាត់បានចុកក្នុងសប្តាហ៏កន្លងទៅ ។**

**បង្គោល ១០ ( សំនួរ ៤៥ )** ត្រូវសួរចំនួនសរុបនៃការដោះដូរថ្នាំចុក ដាក់តំលៃជាប្រាក់រៀល ។ សរសេរលេខ "00" ប្រសិនបើគេមិនបានដោះដូរថ្នាំចុកពីសប្តាហ៏កន្លងទៅ ។

**ចំណាំ : ប្រសិនបើអ្នកចុកថ្នាំប្រើប្រាស់ថ្នាំចុកដែលបានដោះដូរមុនសប្តាហ៏កន្លងទៅ សូមព្យាយាមប៉ាន់ស្មានចំណាយទៅលើថ្នាំចុកដោះដូរដូចដែលគាត់បានចុកក្នុងសប្តាហ៏កន្លងទៅ ។**

**បង្គោល ១១ ( សំនួរ ៤៦ )** ត្រូវសួរចំនួនសរុបពីការចុកថ្នាំដែលបានពីអំណោយ ដាក់តំលៃជាប្រាក់រៀល ។សរសេរលេខ"00" ប្រសិនបើគេពុំបានអោយថ្នាំចុកជាអំណោយពីសប្តាហ៏កន្លងទៅ ។

**ចំណាំ : ប្រសិនជាអ្នកចុកថ្នាំប្រើប្រាស់ថ្នាំចុកដែលបានពីអំណោយមុនសប្តាហ៏កន្លងទៅ សូមព្យាយាមប៉ាន់ស្មានចំណាយទៅលើថ្នាំចុកដូចដែលគាត់បានចុកក្នុងសប្តាហ៏កន្លងទៅ ។**

**បង្គោល ១២ ( សំនួរ ៤៧ )** ត្រូវសួរទីកន្លែងដែលគេទទួលបានថ្នាំចុក សរសេរលេខកូដដូចខាងក្រោម

១ = ទិញកន្លែងហាង

២ =ការដោះដូរគ្នា

៣ = ខ្ញុំដាំសំរាប់ចុកខ្លួនឯង

៤ = ជាអំណោយ

៩ =មិនដឹង/បដិសេធមិនព្រមឆ្លើយ

### III.គ ជក់ខ្សៀរ

**សួរសមាជិកទាំងអស់នៅក្នុងគ្រួសារអាយុ ១៨ឆ្នាំឡើងនឹងមានវត្តមាននៅក្នុងពេលធ្វើ អង្កេត**

**បង្គោល ១** មន្ត្រីសំភាសន៍ត្រូវចុះកត់ត្រាសំគាល់របស់សមាជិកគ្រួសារដែលមានអាយុ១៨ឆ្នាំឡើងទៅជាអ្នកវត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត។ លេខសំគាល់របស់សមាជិកគ្រួសារត្រូវចំលងចេញពីបញ្ជីក្នុងផ្នែកសំណួរប្រជាសាស្ត្រទំព័រទី ២ ប៉ុណ្ណោះប្រសិនបើបង្គោល ១៤ ក= ១ ( វត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត)

**បង្គោល ២ ( សំនួរ ៤៨):** សួរអ្នកដែលបានជក់ខ្សៀរ យ៉ាងតិចណាស់ ៦ខែនៅក្នុងជីវិតរបស់គេ ។

សរសេរកូដលេខ ១ = បាទ/ចាស

សរសេរកូដលេខ ២ = ទេ

**បង្គោល ៣ ( សំនួរ ៤៩ ):** សួរអ្នកជក់ខ្សៀរ នៅពេលបច្ចុប្បន្ន

សរសេរកូដលេខ ១ = បាទ/ចាស

សរសេរកូដលេខ ២ = ទេ ( បើទេ រំលងទៅផ្នែកបន្ទាប់ )

**បង្គោល ៤ ( សំនួរ ៥០):** ត្រូវថាតើក្នុងរយៈពេល៣០ថ្ងៃកន្លង មកនោះលោកអ្នកមានជក់ខ្សៀរ ដែរ ឬទេ ? សរសេរលេខកូដចំនួនថ្ងៃដូចខាងក្រោម :

១ = ១ថ្ងៃ

២ = ២ - ៥ថ្ងៃ

៣ = ៦ - ៩ថ្ងៃ

៤ = ១០-១៩ថ្ងៃ

៥ = ២០-២៩ថ្ងៃ

៦ = ៣០ថ្ងៃ

៩ = មិនដឹង/បដិសេធមិនព្រមឆ្លើយ

**បង្គោល ៥ ( សំនួរ ៥១):** ក្នុងកំឡុងពេល ៣០ថ្ងៃតើអ្នកជក់ខ្សៀរ ប៉ុន្មានថ្ងៃ សរសេរចំនួនថ្ងៃរបស់អ្នកជក់៣០ថ្ងៃកន្លងមក។ សរសេរ " ៩៩ " បើមិនដឹង/បដិសេធមិនព្រមឆ្លើយ ។

**បង្គោល ៦ ( សំនួរ ៥៣ ):** នៅក្នុងកំឡុងពេល ៣០ថ្ងៃ តើអ្នកជក់ខ្សៀរ ជាមធ្យមប៉ុន្មានខ្សៀរ ក្នុង១ថ្ងៃ ។ បង្ហាញរូបភាពលេខ ៣( រូបភាពខ្សៀរ និងចំនួនថ្នាំដែលគេដាក់ក្នុងខ្សៀរ ) ដើម្បីទំនាក់ទំនងរាល់ពេលដែលគេដាក់ចំនួនថ្នាំទៅក្នុងខ្សៀរ ទទេ រួចហើយចំនួនដងនៃការញាត់ថ្នាំទៅក្នុងខ្សៀរ ។

**បង្គោល ៧ ( សំនួរ ៥៤ ):** នៅក្នុងកំឡុងពេលជក់ខ្សៀរ ៣០ថ្ងៃ កន្លងមកនេះ តើអ្នកបានប្រើ ខ្សៀរ ប្រភេទណា

ចុះ បីលេខកូដនៅខាងក្រោម :

សរសេរកូដលេខ ១ = ខ្សៀរ ទឹក ( ដែលមាននៅក្នុងកាតរូបភាព ៤)

សរសេរកូដលេខ ២ = ប្រភេទ ខ្សៀរ ផ្សេងទៀត( ដែលផ្តល់ជាឧទាហរណ៏ក្នុងកាតរូបភាព ៥ )

សរសេរកូដលេខ ៣ =មិនដឹង/បដិសេធមិនព្រមឆ្លើយ

**ចំណាំ: បើអ្នកជក់មិនប្រើប្រាស់ខ្សៀរទឹកទេ តែប្រើប្រាស់ប្រភេទខ្សៀរផ្សេងៗទៀត ចូរចុះលេខកូដ ២ ។ ចូរចំណាំផងដែរថា រូបភាពខ្សៀរបង្ហាញក្នុងកាតរូបភាពលេខ ៥ គ្រាន់តែជាឧទាហរណ៏នៃប្រភេទខ្សៀរផ្សេងៗទៀត តែប៉ុណ្ណោះ គឺមិនមានន័យថា អ្នកជក់ត្រូវតែប្រើប្រាស់ខ្សៀរណាមួយឡើយ ។**

**សំនួរ ( ៥៦-៦០ ):ចំណាយទៅលើថ្នាំជក់សំរាប់ខ្សៀរ**

**បង្គោល ៨ ( សំនួរ ៥៦ )** តើចណាយថ្នាំជក់សរុបជាលុយប៉ុន្មានក្នុងមួយសប្តាហ៏កន្លង មកនេះ ( សរសេរជាតំលៃរៀល ) ។ មន្ត្រីសំភាសន៏ត្រូវពិនិត្យត្រង់ចំណាយលើថ្នាំជក់សំរាប់ខ្សៀរ នៅសប្តាហ៏កន្លងទៅ នៅត្រង់ សំនួរ ៥៧ សំនួរ៥៨ និង សំនួរ ៥៩ ដើម្បីបូកសរុបអោយស្មើក្នុងបង្គោល៨ ( សំនួរ ៥៦)

**ចំណាំ : បង្គោល ៨ ( សំនួរ ៥៦ ) = បង្គោល ៩ ( សំនួរ ៥៧ ) + បង្គោល ១០ ( សំនួរ ៥៨ ) + បង្គោល ១១ ( សំនួរ ៥៩ )**

**បង្គោល ៩ ( សំនួរ ៥៧):** ត្រូវសួរចំនួនសរុបនៃការទិញថ្នាំជក់សំរាប់ខ្សៀរ ដាក់តំលៃជាប្រាក់រៀល ។ សរសេរលេខ "00" ប្រសិនបើគេមិនបានទិញថ្នាំជក់សំរាប់ខ្សៀរ ពីសប្តាហ៏កន្លងទៅ ។

**ចំណាំ : ប្រសិនជាអ្នកជក់ខ្សៀរ ប្រើប្រាស់ថ្នាំជក់បានទិញទុកមុនសប្តាហ៏កន្លងទៅ សូមព្យាយាមប៉ាន់ស្មាន ចំណាយទៅលើថ្នាំជក់ដូចដែលគាត់បានជក់ខ្សៀរ ក្នុងសប្តាហ៏កន្លងទៅ ។**

**បង្គោល ១០ ( សំនួរ ៥៨ )** ត្រូវសួរចំនួនសរុបនៃថ្នាំជក់សំរាប់ខ្សៀរ ដែលបានដោះដូរហើយដាក់តំលៃជាប្រាក់ រៀល ។ សរសេរលេខ "00" ប្រសិនបើគេមិនបានដោះដូរថ្នាំជក់សំរាប់ខ្សៀរ ពីសប្តាហ៏កន្លងទៅ ។

**ចំណាំ : ប្រសិនបើអ្នកជក់ខ្សៀរ ប្រើប្រាស់ថ្នាំជក់ដែលបានដោះដូរមុនសប្តាហ៏កន្លងទៅ សូមព្យាយាមប៉ាន់ស្មាន ចំណាយទៅលើថ្នាំជក់ដោះដូរដូចដែលគាត់បានជក់ក្នុងសប្តាហ៏កន្លងទៅ ។**

**បង្គោល ១១ ( សំនួរ ៥៩ )** ត្រូវសួរចំនួនថ្នាំជក់សំរាប់ខ្សៀរ ដែលបានពីអំណោយ ដាក់តំលៃជាប្រាក់រៀល ។សរសេរលេខ"00" ប្រសិនបើគេពុំបានអោយថ្នាំជក់សំរាប់ខ្សៀរ ពីសប្តាហ៏មុន ។

**ចំណាំ : ប្រសិនជាអ្នកជក់ខ្សៀរ ប្រើប្រាស់ថ្នាំជក់ដែលបានពីអំណោយមុនសប្តាហ៏កន្លងទៅ សូមព្យាយាម ប៉ាន់ស្មាន ចំណាយទៅលើថ្នាំជក់ដូចដែលគាត់បានជក់ក្នុងសប្តាហ៏កន្លងទៅ ។**

**បង្គោល ១២ ( សំនួរ ៦០ )** ត្រូវសួរទីកន្លែងដែលគេទទួលបានថ្នាំជក់សំរាប់ខ្សៀរ សរសេរលេខកូដ ដូចខាងក្រោម :

១ =ទិញកន្លែងហាង

២=ការដោះដូរគ្នា

៣ = ខ្ញុំដាំសំរាប់ជក់ខ្លួនឯង

៤ = ជាអំណោយ

៩ =មិនដឹង/បដិសេធមិនព្រមឆ្លើយ

**III. ឃ មូលហេតុនៃការចាប់ផ្តើម ឬបន្តប្រើប្រាស់ថ្នាំជក់**

**សួរសមាជិកទាំងអស់ក្នុងគ្រួសារអាយុ ១៨ឆ្នាំឡើងនឹងមានវត្តមាននៅក្នុងពេលធ្វើអង្កេត**

**បង្គោល ១** មន្ត្រីសំភាសន៏ត្រូវចុះកត់ត្រាសំគាល់របស់សមាជិកគ្រួសារដែលមានអាយុ១៨ឆ្នាំឡើងទៅ ជាអ្នកវត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត។ លេខសំគាល់របស់សមាជិកគ្រួសារត្រូវចំលងចេញពីបញ្ជីក្នុងផ្នែក សំណួរប្រជាសាស្ត្រទំព័រទី ២ ប៉ុណ្ណោះប្រសិនបើបង្គោល ១៤ ក= ១ ( វត្តមាននៅក្នុងកំឡុងពេលធ្វើអង្កេត)

**បង្គោល ២ (សំនួរ ៦១):** បង្ហាញពីហេតុផលក្នុងការដែលអ្នកចាប់ផ្តើមប្រើប្រាស់ថ្នាំជក់។ ប្រភេទណាក៏ដោយអាចជាបារី ថ្នាំចុក ឬ ខ្សៀរ ។ប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុពេញ ។ តារាងបង្វែអាយុ មាននៅក្នុងឧបសម្ពន ។ ប្រសិនបើគេចាប់ផ្តើមជក់ពីអាយុតិចជាងមួយឆ្នាំត្រូវដាក់ " អាយុពេញ = ០០" ប្រសិនបើគេមិនជក់បារីត្រូវ ដាក់អាយុពេញ = " ៩៩ " ។

**បង្គោល ៣ ( សំនួរ ៦២ )** ត្រូវសួរអាយុដំបូងដែលគេបានចុកថ្នាំ ។ បង្ហាញពីហេតុផលក្នុងការដែលអ្នកចាប់ផ្តើមប្រើប្រាស់ថ្នាំចុក។ ប្រភេទណាក៏ដោយអាចជាបារី ថ្នាំចុក ឬ ខ្សៀរ ។ ប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុពេញ ។ តារាងបង្វែអាយុមាននៅក្នុងឧបសម្ពន័ ។ ប្រសិនបើគេចាប់ផ្តើមចុកពីអាយុតិចជាងមួយឆ្នាំត្រូវដាក់ " អាយុពេញ = ០០" ប្រសិនបើគេមិនចុកថ្នាំត្រូវ ដាក់អាយុពេញ = " ៩៩ " ។

**បង្គោល ៤ ( សំនួរ ៦៣ )** ត្រូវសួរអាយុដំបូងដែលគេបានជក់ខ្សៀរ ។ បង្ហាញពីហេតុផលក្នុងការដែលអ្នកចាប់ផ្តើមជក់ខ្សៀរ ។ ប្រភេទណាក៏ដោយអាចជាបារី ថ្នាំចុក ឬ ខ្សៀរ ។

ប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុពេញ ។ តារាងបង្វែអាយុមាននៅក្នុងឧបសម្ពន្ធ ។
ប្រសិនបើគេចាប់ផ្តើមជក់ខ្សៀរ ពីអាយុតិចជាងមួយឆ្នាំត្រូវដាក់ " អាយុពេញ = 00" ប្រសិនបើគេមិនជក់ខ្សៀរ ត្រូវដាក់អាយុពេញ = " ៩៩ " ។

**បង្គោល ៥ ( សំនួរ ៦៤ )** ត្រូវសួរអាយុដំបូងដែលគេបានប្រើប្រាស់ថ្នាំជក់ ។ ប្រភេទណា ក៏ដោយ អាចជាបារី ថ្នាំចុក ឬ ខ្សៀរ ។

ប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុពេញ ។ តារាងបង្វែអាយុមាននៅក្នុងឧបសម្ពន័ ។ ប្រសិនបើគេចាប់ផ្តើមជក់ថ្នាំជក់ចាប់ពីអាយុតិចជាងមួយឆ្នាំត្រូវដាក់ " អាយុពេញ = 00" ប្រសិនបើគេមិនជក់ ខ្សៀរ ត្រូវដាក់អាយុពេញ = " ៩៩ " ។

**ចំណាំ:** ត្រូវត្រួតពិនិត្យសមាជិកទាំងអស់នៅក្នុងគ្រួសារដែលមានអាយុ ១៨ឆ្នាំឡើងទៅក៏ត្រូវមាននៅក្នុងផ្នែកនេះ ដើម្បីធ្វើការផ្ទៀងផ្ទាត់មូលហេតុនៃការប្រើប្រាស់ថ្នាំជក់ ។ មន្ត្រីសំភាសន៍ត្រូវប្រៀបធៀបឆ្នាំកំណើតជាមួយសំនួរអាយុពិតប្រាកដដែលមានចំលើយក្នុងផ្នែក IIIឃ ។ សំនួរនេះមិនមែនសំរាប់បញ្ចូលទិន្នន័យទេ ។មន្ត្រីត្រួតពិនិត្យនឹង ចុះទៅដល់កន្លែងធ្វើសំភាសន៍ដើម្បីពិនិត្យចំពោះការបំពេញតារាងសំនួរនិង ធ្វើការសំភាសន៍ឡើងវិញនូវគ្រួសារគំរូមួយ ចំនួនដើម្បីត្រួតពិនិត្យពត៌មានដែលមន្ត្រីសំភាសន៍បានប្រមូលត្រឹមត្រូវដែរឬទេ ។ លើសពីនេះទៀត ធ្វើការត្រួតពិនិត្យពីសំនួរអាយុ មន្ត្រីត្រួតពិនិត្យត្រូវធ្វើការផ្ទៀងផ្ទាត់ ឬ សំភាសន៍ឡើងវិញដោយយកចិត្តទុកដាក់តាមលំដាប់ដើម្បីផ្ទុផ្ទងអំពីអាយុកំណើត និងអាយុដែលចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ ចុកថ្នាំ ជក់ខ្សៀរ ។ តារាងបង្វែអាយុគឺជាគន្លឹះសំរាប់វាស់វែងដើម្បីកំណត់អាយុពេលកើត និង អាយុចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ ។

### III.ង អាយុនៃការចាប់ផ្តើមជក់បារី

តូវសួរសមាជិកទាំងអស់នៅក្នុងគ្រួសារដែលមានអាយុ ១៨ឆ្នាំឡើងទៅនឹងមានវត្តមាននៅក្នុងពេលធ្វើ អង្កេត ។

**បង្គោល ១:** មន្ត្រីសំភាសន៍ត្រូវតែចំឡងលេខសំគាល់សមាជិកគ្រួសារទាំងអស់ដែលមានអាយុ ១៨ ឆ្នាំឡើងទៅហើយជាអ្នកវត្តមាននៅក្នុងពេលធ្វើអង្កេត ។ លេខសំគាល់ត្រូវបានចំឡងពីការត្រួតពិនិត្យថ្នាំជក់ទំព័រទី២តែប៉ុណ្ណោះ ប្រសិនបើបង្គោល ១៤ ក= ១ ( មានវត្តមាននៅក្នុងពេលធ្វើ អង្កេត )

**បង្គោល ២: ( សំនួរ ៦១)** ត្រូវសួរអាយុពេលដែលគេចាប់ផ្តើមជក់បារីលើកទី ១ សូម្បីតែជក់បារីមួយហឺត ឬ មួយដើមឬក៏ច្រើនជាងនេះកដោយ ។ សូមប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុឆ្នាំពេលដែល គេចាប់ផ្តើមជក់ តារាងបង្វែអាយុមាននៅក្នុងឧបសម្ព័ន្ធ ។ ប្រសិនបើការជក់បារីលើកដំបូងតិចជាង ១ឆ្នាំ បញ្ចូលអាយុពេញនៃការចាប់ផ្តើមជក់ គឺស្មើ "00 " ប្រសិនបើគេមិនបានជក់បារីឆ្នាំអាយុពេញគឺ " ៩៩" ។

**បង្គោល ៣: ( សំនួរ ៦២)** ត្រូវសួរអាយុពេលដែលគេចាប់ផ្តើមចុកថ្នាំលើកទី ១ សូម្បី តែមួយ ឆ្នុក្មក៏ច្រើន

ជាងនេះកដោយ ។ សូមប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុឆ្នាំពេញដែល គេចាប់ផ្តើមចុក តារាងបង្វែអាយុមាននៅក្នុងឧបសម្ព័ន្ធ ។ ប្រសិនបើការចុកថ្នាំលើកដំបូងតិចជាង ១ឆ្នាំ បញ្ចូលអាយុពេញនៃការចាប់ផ្តើមចុក គឺស្មើ "០០" ប្រសិនបើគេមិនបានចុកថ្នាំឆ្នាំអាយុពេញគឺ "៩៩" ។

**បង្គោល ៨: ( សំនួរ ៦៣)** ត្រូវសួរអាយុពេលដែលគេចាប់ផ្តើមជក់ខ្សៀរ លើកទី ១ សូម្បីតែជក់មួយហឺត ឬមួយខ្សៀរ ឬក៏ច្រើនជាងនេះកដោយ ។ សូមប្រើប្រាស់តារាងបង្វែអាយុដើម្បីកំណត់អាយុឆ្នាំពេញដែល គេចាប់ផ្តើមជក់ តារាងបង្វែអាយុមាននៅក្នុងឧបសម្ព័ន្ធ ។ ប្រសិនបើការជក់ខ្សៀរ លើកដំបូងតិចជាង ១ឆ្នាំ បញ្ចូលអាយុពេញនៃការចាប់ផ្តើមជក់ គឺស្មើ "០០" ប្រសិនបើគេមិនបានជក់ខ្សៀរ ឆ្នាំអាយុពេញគឺ "៩៩" ។

**បង្គោល៩:(សំនួរ៦៤)** ត្រូវសួរអាយុពេលដែលគេចាប់ផ្តើមប្រើប្រាស់ថ្នាំជក់លើកទ ១នៅរាល់ការប្រើប្រាស់ថ្នាំជក់ដូចជា ជក់បារី ចុកថ្នាំ ជក់ខ្សៀរ ។ សូមប្រើប្រាស់តារាងបង្វែអាយុ ដើម្បីកំណត់អាយុឆ្នាំពេញដែល គេចាប់ផ្តើមជក់ តារាងបង្វែអាយុមាននៅក្នុងឧបសម្ព័ន ។ប្រសិនបើគេប្រើប្រាស់ប្រភេទថ្នាំជក់លើកដំបូងតាមរូបភាពណាក៏ដោយតិចជាង ១ឆ្នាំ បញ្ចូលអាយុពេញនៃការ ចាប់ផ្តើមជក់ គឺស្មើ "០០" ប្រសិនបើគេមិនបានជក់ខ្សៀរ ឆ្នាំអាយុពេញគឺ "៩៩" ។

**ចំណាំ:** ត្រូវត្រួតពិនិត្យសមាជិកទាំងអស់នៅក្នុងគ្រួសារដែលមានអាយុ ១៨ឆ្នាំឡើងទៅក៏ត្រូវមាននៅក្នុងផ្នែកនេះ ដើម្បីធ្វើការផ្ទៀងផ្ទាត់មូលហេតុនៃការប្រើប្រាស់ថ្នាំជក់ ។ សំនួរគឺមិនមែនចំពោះការបញ្ចូលទិន្នន័យ ។មន្ត្រីត្រួតពិនិត្យនឹងចុះទៅដល់កន្លែងធ្វើសំភាសន៏ដើម្បីពិនិត្យចំពោះការបំពេញតារាងសំនួរនិង ធ្វើការសំភាសន៏ឡើងវិញនូវគ្រួសារគំរូមួយចំនួនដើម្បីត្រួតពិនិត្យពត៌មានដែលមន្ត្រីសំភាសន៏បានប្រមូលត្រឹមត្រូវដែរឬទេ ។ លើសពីនេះទៀត ធ្វើការត្រួតពិនិត្យពីសំនួរអាយុ មន្ត្រីត្រួតពិនិត្យត្រូវធ្វើការផ្ទៀងផ្ទាត់ ឬ សំភាសន៏ឡើងវិញដោយយកចិត្តទុកដាក់ តាមលំដាប់ដើម្បីផ្ទួផ្ទងអំពីអាយុកំណើត និងអាយុដែលចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ ចុកថ្នាំ ជក់ខ្សៀរ ។ តារាងបង្វែអាយុគឺជាគន្លឹះសំរាប់វាស់វែងដើម្បីកំណត់អាយុពេលកើត និង អាយុចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ ។

### III.ង ហេតុផលនៃការចាប់ផ្តើម ឬបន្តប្រើប្រាស់ថ្នាំជក់ ( សំរាប់តែអ្នកប្រើប្រាស់ថ្នាំជក់ប៉ុណ្ណោះ)

**សួរសមាជិកទាំងអស់គ្រួសារអាយុ ១៨ឆ្នាំឡើងនឹងមានវត្តមាននៅក្នុងពេលធ្វើអង្កេត ។ សំនួរត្រួតពិនិត្យពិតប្រាកដ និង អ្នកប្រើប្រាស់ថ្នាជក់ក៏ត្រូវបំពេញក្នុងសំនួរ ៦៥ និង ៦៦ ដែរ ។**

សំនួរត្រួតពិនិត្យថ្នាំជក់ត្រូវបានផ្តល់ក្នុងផ្នែកនេះដើម្បីសួររកអ្នកដែលបានប្រើប្រាស់ថ្នាំជក់សារឡើងវិញ ដូចជា ការប្រើប្រាស់ បារី ចុកថ្នាំ ជក់ខ្សៀរ ។ល ។ ក្នុងពេលត្រួតពិនិត្យសំនួរបន្ថែមមន្ត្រីសំភាសន៏ក៏ដូចជាមន្ត្រីត្រួតពិនិត្យ ត្រូវត្រួតពិនិត្យយ៉ាងប្រុងប្រយត្ន័ដើម្បីធ្វើអោយប្រាកដថាអ្នកប្រើប្រាស់ថ្នាំជក់ត្រូវបានបំពេញក្នុងផ្នែកនេះ ។ ដើម្បីធ្វើការនេះបានកាន់តែប្រសើរឡើងមន្ត្រីសំភាសន៍ និង មន្ត្រីត្រួតពិនិត្យត្រូវបញ្ជាក់ថាមានតែអ្នកប្រើប្រាស់ថ្នាំជក់ប៉ុណ្ណោះដែលបានបំពេញក្នុងផ្នែកនេះ ។ សូមចុះលេខកូដដូច ខាងក្រោម ។

សរសេរលេខកូដ ១ = បាទ/ចាស( រំលងទៅង្គោល ២)

សរសេរលេខកូដ ២ = ទេ ( រំលងទៅផ្នែកបន្ទាប់ )

## ហេតុផលនៃការចាប់ផ្តើមប្រើប្រាស់ថ្នាំជក់

**បង្គោល ១ :** មន្ត្រីសំភាសន៍ត្រូវតែចំឡងលេខសំគាល់សមាជិកគ្រួសារទាំងអស់ដែលមានអាយុ ១៨ ឆ្នាំឡើងទៅហើយជាអ្នកវត្តមាននៅក្នុងពេលធ្វើអង្កេត ។

**ប្រង្គោល ២ (សំនួរ ៦៥ ក):** សួរពីហេតុផលក្នុងការ ចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ ហេតុផលដែលទាក់ទងទៅនឹងការសាកល្បង ឬធ្វើការពិសោធន៍ ។ សូមចុះលេខកូដដូច ខាងក្រោម ។

សរសេរលេខកូដ ១ = បាទ/ចាស( មូលហេតុនៃការចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ពីព្រោះធ្វើការសាកល្បង ឬ ពិសោធន៍)

សរសេរលេខកូដ ២ = ទេ ( មូលហេតុនៃការចាប់ផ្តើមប្រើប្រាស់ថ្នាំជក់ពីព្រោះមិនមែនធ្វើការសាកល្បង ឬ ពិសោធន៍ទេ)

សរសេរលេខកូដ ៩ = មិនដឹងឬបដិសេធមិនព្រមឆ្លើយ

